
នាង
ខៀវ.
វណ្ណដារ៉ា
តាំង·វស្សា
កម្រងរឿងពិត នៅ សៀមរាប

អ្នកនិពន្ធ និង បោះពុម្ពផ្សាយ

**ត. ចន្ទ្រា**

# នាងឌៀបវណ្ណដារា

# DIEP-VANNDARA

បោះពុម្ពលើកទីពីរ ចំនួន ២.៥០០ ក្បាល
អ្នកនិពន្ធរក្សាសិទ្ធគ្រប់យ៉ាង

ព.ស. ២៥១៥ គ.ស. ១៩៧១

www.elibraryofcambodia.org

# អារម្ភកថា

មិត្តអ្នកអានជាទីគោរព !

រហូតមកដល់ពេលនេះ, ខ្ញុំបាទជាអ្នកនិពន្ធបានទទួលលិខិតពីមិត្តយុទ្ធជន - យុទ្ធនារី និងមិត្តអ្នកអានជាច្រើនលើសលប់ ដែលផ្ញើមកលើកទឹកចិត្តដោយគាំទ្រនូវជំហានចុងក្រោយរបស់ខ្ញុំបាទ។ សូមជម្រាបថារឿងនាង *ឡៀប វណ្ណដារ៉ា* នេះប្រសូតចេញពីរោងពុម្ពមិនបានដល់មួយសប្ដាហ៍ផង ស្រាប់តែអស់រលីងជាហេតុនាំឲ្យមិនគ្រប់គ្រាន់តាមសេចក្ដីត្រូវការរបស់មិត្តអ្នកអាន ។ មហាកិត្តិយសនេះ, អ្នកនិពន្ធខ្ញុំបាទមិនបាននឹកគិតទុកជាមុនសោះ ហើយដោយមានមិត្តអ្នកអានជាច្រើនទៀតរកជាវអានពុំបាន ក៏ផ្ញើលិខិតមកឲ្យខ្ញុំបាទបោះពុម្ពបន្ថែម, ខ្ញុំបាទក៏បានសម្រេចចិត្តតាមសំណូមពរនេះបោះពុម្ពជាលើកទី ២ ចំនួន ២.៥០០ ក្បាល ដើម្បីឲ្យគ្រប់នឹងសេចក្ដីត្រូវការរបស់មិត្តដែលរកជាវទុកជាឯកសារ ។

ចំពោះសំបុត្រភាគច្រើនទៀតចង់ឲ្យរឿង « នាងឡៀប វណ្ណដារ៉ា » នេះក្លាយទៅជាខ្សែភាពយន្តគ្រាន់ទុកជាឯកសារនោះ, ខ្ញុំបាទអ្នកនិពន្ធមានការចាប់អារម្មណ៍ជាច្រើន ដោយមានផលិតករភាពយន្តខ្លះរួមពិគ្រោះរកមធ្យោបាយ ដើម្បីសាងខ្សែភាពយន្តនេះឡើងបំពេញតាមសេចក្ដីត្រូវការរបស់មិត្ត ។ ក៏ប៉ុន្តែ, ដោយហេតុផលតាមស្រុក

... សូមផ្ញើជូនមិត្តយុវជនទាំងអស់, ជាពិសេសមិត្តកងវរសេនាតូចយុវជនសៀមរាប ជាអ្នករួមអាវុធប្រយុទ្ធហ៊ានអង់អាចជាមួយវីរនារី ឡៀប-វណ្ណដារ៉ា ព្រមទាំងផ្ញើជូនមិត្តយុវជនយើងទាំងឡាយដែលកំពុងឈរមមុខវាយសំពងក្បាលខ្មាំងឈ្លានពានឥតខ្លាចស្លាប់ឡើយ ។ មួយចំណែកទៀត សូមផ្ញើជូនមិត្តយុទ្ធនារីខ្មែរនៅជម្រៅព្រៃសដោយស្មោះស្ម័គ្រ . . .

**ពីអ្នកនិពន្ធ**

www.elibraryofcambodia.org

វគ្គទីមួយ

## ចូលធ្វើកុម្ម៉ង់ដូ

ឆ្នាំ ១៩៧០ . . .

ព្រឹត្តិការណ៍ខ្មោចផ្សា បានធ្វើឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបក្រោកឈរឡើងក្នុងស្មារតីតស៊ូ វាយសំពង់ក្បាលចោរយៀកកុង-យួនខាងជើងទមិឡឈ្លានពាន ឲ្យវិនាសពីទឹកដីកម្ពុជា ។ គ្រប់សមរភូមិនៃដែនដីកម្ពុជា, អ្នកក្លាហានខ្មែរគ្រប់រូបបានតយុទ្ធដោយអង់អាច ដើម្បី ជាតិ-សាសនា និងទឹកដី ...

ខេត្តសៀមរាប, ក៏មិនខ្វះអ្នកក្លាហានដែរ ។ ស្ត្រីខ្មែរទីមួយដែលបានប្តូរជីវិតនៅលើសមរភូមិ គឺកញ្ញា ខៀវ-វណ្ណដារ៉ា ។

ទិវាមួយនោះ, ក្រោយពេលទទួលដំណឹងថា កងកុម្ម៉ង់ដូសិស្សនៃវិទ្យាល័យសៀមរាប ត្រូវការជ្រើសរើសសិស្សស្ម័គ្រចិត្ត ដើម្បីហាត់រៀនវិជ្ជាយុទ្ធសាស្ត្រ, នាងខៀវវណ្ណដារ៉ា បានចូលទៅជួបម្តាយ ដើម្បីសួរយោបល់ដោយវាចាទន់ភ្លន់ ៖

–" ម៉ាក់ ! ម៉ាក់ ! ឥឡូវនេះ កងកុម្ម៉ង់ដូសិស្សវិទ្យាល័យសៀមរាប ត្រូវការជ្រើសរើសពួកសិស្សស្រី ៗ ដែលស្ម័គ្រចិត្ត ឲ្យទៅហាត់រៀនវិជ្ជាយុទ្ធសាស្ត្រ ។ ម៉ាក់អនុញ្ញាតឲ្យមាយ[១] ចូលទៅធ្វើកុម្ម៉ង់ដូនឹងគេទៅ ... "

អ្នកស្រី ប៊ិន-បូបេឡាំង ជាមាតា ឮសម្តីបុត្រីជាក់ស្តែងយ៉ាងនេះ ងើបកក្រមើលមុខកូនដោយចេតនាល្អ ។ តាំងពីដើមមក, អ្នកស្រីយល់ចិត្តគំនិតរបស់កូនស្រីគាត់ណាស់ ទាំងលោកប្រុសជាស្វាមី ក៏មានការទុកចិត្តទុកថ្លើមលើចរិយាសម្បត្តិរបស់កូនដែរ ។ ម្ល៉ោះហើយព្រហ្មវិហារធម៌នៃមាតាបិតាជាធម្មជាតិរបស់ឪពុកម្តាយផងទាំងពួង តែងគ្របសង្កត់ទៅលើចិត្តគាត់កាន់តែខ្លាំងឡើង ។ តាមការពិត, កូនស្រីដែលគាត់ហ៊ានបណ្តែតបណ្តោយយ៉ាងនេះ គឺគាត់បានសម្លឹងឃើញមានការទុកចិត្តទាំងស្រុង ព្រោះនាងមិនដែលធ្វើអ្វីជាសៅហ្មង ឬរលកជន្លឹចំពោះគ្រួសារម្តងឡើយ ។

---

១- ឈ្មោះ «មាយ» នេះ ជាឈ្មោះដែលអ្នកផងហៅនាង ខៀវ-វណ្ណដារ៉ា នាងក្រៅ គឺ ខៀវ-វណ្ណដារ៉ា ហៅ មាយ ។

www.elibraryofcambodia.org

ថ្ងៃនេះ លោក ឡៅ-ស៊ីម រវល់ជាប់កិច្ចការនៅឯការិយាល័យច្រើនមិនបាននៅផ្ទះ ព្រោះគាត់ជានាយការិយាល័យភូមិបាលស្រុកតូក ។ សល់តែអ្នកស្រីនិងកូនឯទៀតនៅចាំផ្ទះ ។

អ្នកស្រីបន្ទីមួយៗ តបទៅនាង ឡៅ វណ្ណដារ៉ា ៖

–" អាមាយកូន, ស្ដាប់ម៉ាក់សិន ! ម៉ាក់គ្មានចិត្តចង់ឃាត់កូនមិនឲ្យបំពេញគោលបំណងល្អរបស់កូនទេ, ប្រសើរណាស់ ដែលកូនចេះឈឺឆ្អាលយកចិត្តទុកដាក់ចំពោះជាតិ, ប៉ុន្តែ .... ,

អ្នកស្រីងើបក្រសែនេត្រសាជាថ្មី សម្លឹងមុខបុត្រីដែលកំពុងស្ដាប់សំដីគាត់យ៉ាងយកចិត្តទុកដាក់ ។ គាត់បន្ត ៖

–" ប៉ុន្តែមាយកូន ឯងជាស្រីមិនមែនដូចគេប្រុសៗ ទេ, ឧបមាមានហេតុការណ៍អីមិនស្រួលកើតឡើង កូនមិនអាចប្រយុទ្ធជាមួយពួកវាឈ្នះបានឡើយៗ កុំអីប្អូនកូន ?"

–" មិនដឹងជាខ្លាចអីទេម៉ាក់ ! " នាងពោលឡើងទាំងម៉ឺងម៉ាត់, "ធម្មតា បើយើងគ្មានសេចក្ដីក្លាហានទេ ចាត់ទុកដូចជាស្លាប់មុនស្រេចទៅហើយ មិនបាច់ប្រយុទ្ធទេ ។ ម៉ាក់មើល ! មិត្តខ្ញុំខ្លះសុទ្ធតែជាកូនសក្ដិបីសក្ដិបួន មានទ្រព្យសម្បត្តិស្មើមហាចក្រ, គេនៅតែមិនស្ដាយជីវិត សុខចិត្តចូលធ្វើកុម្មង់ដូចម្រើជាតិការពារទឹកដី ។ ណ្ហើយម៉ាក់ បើកូនស្លាប់សុខចិត្តស្លាប់ដោយកាំភ្លើងនៅដៃទៅចុះ មិនឲ្យខ្មាំងវាចូលមកចាប់ដោយស្រួលៗ ឬបាញ់សម្លាប់យ៉ាងព្រៃផ្សៃទទេៗ ទេណាំម៉ាក់ ! "

ក្រោមលោកសម្ដីដ៏មានខ្លឹមសារនេះ បញ្ជាក់ឲ្យអ្នកស្រីជាម្ដាយឃើញកាន់តែច្បាស់នូវទឹកចិត្តមុះមុតរបស់កូនស្រីគាត់ អ្នកស្រីបែរឡាំងឃាត់កូនសាជាថ្មី ៖

–" ម៉ាក់យល់ចិត្តមាយហើយ, ម៉ាក់សូមសរសើរដោយស្មោះ ។ តែម៉ាក់ឃាត់កូនក៏ពីព្រោះម៉ាក់មិនចង់ឃើញកូនរងគ្រោះ ដោយអំពើព្រៃផ្សៃបែបណាមួយពីខ្មាំងសត្រូវប៉ុណ្ណោះ ! "

–" គឺតែចំពោះមកពីយើងអត់អាវុធនៅដៃហ្នឹងហើយ ដែលឲ្យខ្មាំងមើលងាយបាន បើសម្រាប់រូបកូនវិញក្នុងពេលស្រុកយើងកើតចម្បាំងនេះ មានតែកាំភ្លើងមួយដើម ចេះវិជ្ជាយុទ្ធសាស្ត្រពេញខ្លួនកូនឥតភ័យបារម្ភឡើយ ។ កូនភ័យបារម្ភម្យ៉ាងតែយើងគ្មានកាំភ្លើង មិនចេះអ្វីសោះ ម្ល៉ោះហើយបើខ្មាំងចូលមក យើងក៏មិនដឹងជាបានអីតតាំងនឹងខ្មាំងក្រៅពីសុំចំណុះចំណូលនឹងវាតែប៉ុណ្ណោះ... "

www.elibraryofcambodia.org

នាងឈប់បន្តិច ទើបបន្តទៅទៀត ៖

–" ម៉ាក់ ! គួរអនុញ្ញាតឲ្យកូនធ្វើកុម្ម៉ង់ដូ ហាត់រៀនវិជ្ជាយុទ្ធសាស្ត្រផងទៅ ! "

មួយប្រយោគនេះ ធ្វើឲ្យអ្នកស្រី បែរឡាំង អាណិតហើយស្រឡាញ់កូនកាន់តែខ្លាំងឡើង ៖

–" មាយ កូនស្រីម៉ាក់ ! ម៉ាក់មិនចង់ឲ្យមាយឃ្លាតចេញឆ្ងាយពីម៉ាក់សោះ ព្រោះម៉ាក់មានតែកូនឯងម្នាក់ប៉ុណោះ ដែលអាចបម្រើម៉ាក់បាន ។ កូនដឹងស្រាប់ហើយ ម៉ាក់កំពុងតែឈឺផង ! "

ពីតាពុម្ពាយពោលដូច្នេះស្រងាកចិត្តបន្តិចដែរ ។ តាមពិត, នាងដឹងច្បាស់ណាស់ថា ម្ដាយរបស់នាងមានជំងឺឡើយបេះដូង មិនហ៊ានធ្វើការអ្វីធ្ងន់ទេ ។ ចំពោះប្អូនៗ ឯទៀត ដូចជាគ្មានសង្ឃឹមចូលចិត្តសោះឡើយ ព្រោះគ្នានៅតូចៗ មិនទាន់ដឹងអីប៉ុន្មាន ។

យុវែន ឡៀប ស៊ីវណ្ណា ជាប្អូនទី ២ បន្ទាប់ពីនាង ឡៀប វណ្ណដារ៉ា មក ។ គេនៅក្នុងបន្ទប់នោះដែរ ។ ពេលពួបងស្រីនិងម្ដាយជាប់ជជែកគ្នា គេទំផ្ទៀងស្ដាប់យ៉ាងយកចិត្តទុកដាក់ ហើយបន្ទាប់ពីឃើញមានសភាពស្ងប់ស្ងាត់ មួយរយៈនៃការសន្ទនា ក៏បញ្ចេញយោបល់ឡើង ៖

–" ម៉ាក់ ! ការគួរ គួរតែម៉ាក់អនុញ្ញាតឲ្យបងមាយធ្វើកុម្ម៉ង់ដូទៅម៉ាក់ ! "

លោកស្រី ឡៀប ស៊ុម ឮកូនទីពីរបន្ទឺដូច្នេះ ងាកមកមើលមុខកូនបន្តិច ហើយដាក់មុខទៅវិញ ។ និស្ស័យរបស់គាត់តែងមានការសន្ដោសច្រើនទៅលើកូន ម៉្លោះហើយការស្នើរយោបល់របស់កូនចំពោះគាត់ ថ្វីបើគាត់យល់ឃើញថាជាការប្រសើរពិតមែនហើយ ក៏ប៉ុន្តែ ហេតុស្រឡាញ់កូន ចង់ឲ្យកូនមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ នោះក៏បណ្ដាលឲ្យមានអាការៈទ័រទើបន្តិច ។

ស៊ីវណ្ណា ឃើញម្ដាយមិនទាន់មានការដាច់ស្រេចក្នុងចិត្ត ក៏បន្ថែមយោបល់ ៖

–" គួរតែម៉ាក់កុំឃាត់បងមាយអី, យើងមានអាវុធនៅដៃ ទើបខ្មាំងមិនហ៊ានមាក់ងាយ ។ ម៉ាក់មើលមិត្តភក្តិខ្ញុំជាច្រើនមានស្រីមានប្រុស គេចុះឈ្មោះអស់ហើយ តើយើងនៅរង់ចាំអីទៀត ឬរង់ចាំដល់ពួកអាឌត្បាតអស់នោះមកច្របាច់កតែម្ដងទៅ?"

ពុសម្ដីប្អូនប្រុសទី២ របស់នាងពោលដូច្នេះ ឡៀប–វណ្ណដារ៉ាហៅមាយរំភើបចិត្តប្រកបដោយសេចក្ដីក្លាហាន កលលេចអណ្ដែតឡើងតាមសរសៃចក្ខុដ៏ភ្លឺថ្លាដូចដួងផ្កាយ ។ នារីបន្តឃ្លាពីស៊ីវណ្ណា ៖

www.elibraryofcambodia.org

-" ជាតិត្រូវការយើងហើយ ស្រែកហៅកូនខ្មែរគ្រប់គេ ក្រោកឡើងតស៊ូប្រយុទ្ធនឹងខ្មាំង... ម៉ាក់... មាយត្រូវតែសម្រេចចិត្តកាន់កាំភ្លើង យកខ្លួនពាំងការពារទឹកដី មិនឲ្យសត្រូវណាចូលមកជាន់កខ្មែរបានទេ ... "

ប៉ុន្មានឃ្លាចុងក្រោយនេះ អ្នកស្រីជាមាតាត្រឹស្បែកដោយកម្លាំងរំភើប តាមសន្ទុះរលកនៃទម្ងន់សម្លេងរបស់បុត្រីជាទីគាប់ចិត្ត ។ នៅពេលនេះ អ្នកស្រីកាន់តែយល់ច្បាស់ពីទឹកចិត្តក្លាហានអង់អាចរបស់កូន ធ្ងន់ទៅលើការស្រឡាញ់ទឹកដីយ៉ាងមុតមាំ ។ តើគាត់អាចទាញទាំនូវគោលបំណងរបស់នាងបានឬទេ ? ថ្វីបើឥទ្ធិពលនៃការស្រឡាញ់បុត្រីធ្វើឲ្យគាត់ពន្យល់បន្តិចបន្តួច ដើម្បីបណ្តាច់ចិត្តកូនពីការចង់ចូលធ្វើកម្មង់ដូមានទំហំប៉ុណ្ណាក៏ដោយ, ពេលនេះ, ចំពោះឧត្តមគតិថ្លៃថ្នូរ សម្បជញ្ញៈស្នេហាជាតិបានធ្វើឲ្យគាត់គ្រេកអរលើសលប់ ហើយថ្លែងទាំងញាប់ញ័រ ៖

-" ល្អហើយ កូនម៉ាក់ ! បើឯងសម្រេចចិត្តដូច្នេះហើយ ម៉ាក់ក៏រីករាយដែរ ដោយបានឃើញកូនសុខចិត្តចូលខ្លួនបម្រើជាតិ ។ ប៉ុន្តែម៉ាក់សូមផ្តាំថា បើចូលហាត់កម្មង់ដូហើយត្រូវព្យាយាមមុះមុតក្នុងចំណេះវិជ្ជានោះ ព្រោះវាជាគ្រឿងសម្រាប់ការពារខ្លួនយើងហើយណា ! "

ប្រយោគរបស់ម្តាយចុងក្រោយនេះ ធ្វើឲ្យឡៀប វណ្ណដារ៉ា មានសោមនស្សយ៉ាងខ្លាំង ទឹកមុខស្រស់ញញឹមស៊ីយផ្កាកុលាបត្រូវទឹកសន្សើមនាអរុណោទ័យ ។ នាងបន្លឺទាំងត្រឹត្រួច ៖

-" ម៉ាក់ចាំមើលមាយចុះ ! តែអាយួនកន្ទបហ៊ានជាន់ជាយសាលា មាយបាញ់បំបែកក្បាលពួកវាឲ្យស្គាល់ដៃកូនស្រីម៉ាក់ពូជខ្មែរអង្គរវត្តម្តង ! "

អ្នកស្រីបែរឡាំង សែនពេញចិត្តរកអ្វីប្រៀបស្មើពុំបាន ចំពោះសម្តីរបស់កូនស្រី ដែលផុះចេញពីក្នុងក្រអៅបេះដូងពិតប្រាកដ ។ អ្នកស្រីបញ្ចេញផ្កាញញឹម ធ្វើឲ្យបរិយាកាសកាន់តែស្រស់ស្រាយជាលំដាប់ ។

-" អើ, ក្លាហានណាស់ មាយកូនស្រីម៉ាក់ ! " អ្នកស្រីឧទាន ។

ទាំងអស់គ្នាបានសម្តែងនូវសេចក្តីរីករាយឡើង ស្របនឹងវាចា នាង ឡៀប វណ្ណដារ៉ាហៅមាយ បន្តទៅទៀត ៖

-" ម៉ាក់, ម៉ាក់ជឿកូនទេ ថាមាយអាចហ៊ានកាន់កាំភ្លើងបាញ់ក្បាលពួកអាយៀកកុងបានណា ? ... ម៉ាក់ចាំមើលចុះ ឲ្យតែមាយបានជួបប្រទះពួកអាចោរទាំងនោះមាយបាញ់ក្បាលពួកវាឲ្យស្លាប់តែហោងហុយដីតែម្តង ! "

www.elibraryofcambodia.org

-" អឺ, ម៉ាក់ជឿហើយ ! ... " អ្នកស្រីបែរឡាំងឥតក្បាល ។

ពេលនោះ ឡៀប-ស៊ីវណ្ណា និង ឡៀប-ដាក់រិទ្ធ បាននិយាយជាមួយគ្នាពីរឿងអ្វីមួយស្រេច ក៏បន្ទឺឡើង ៖

-" ម៉ាក់ ! ម៉ាក់ ! ... "

អ្នកស្រីងាកមករកកូនប្រុសទាំងពីរ ។ ឡៀប-ស៊ីវណ្ណា កូនទី ២ របស់គាត់បញ្ចេញសម្លេងឡើង ៖

-" ខ្ញុំនិងរិទ្ធ សុំគេចុះឈ្មោះហាត់កុម្ម៉ង់ដូនីងគេដែរហើយណាម៉ាក់ ! "

មេគ្រួសារញញឹមបន្តិច ៖

-" អឺ, ចុះក៏ចុះនីងគេទៅ ! "

គ្រានោះ, ស្រាប់តែ ឡៀប-ដាភច័ន្ទ ស្ទុះមកពីក្រៅស្រែកឡើង ៖

" បើបងទាំងអស់គ្នាទៅហើយ ខ្ញុំក៏ទៅដែរ ! "

ឡៀប-ស៊ីវណ្ណា ស្រែកឃាត់ ៖

-" ណ្ហើយ, ភងអីចឹងកុំទៅអី ! មិនកើតទេ នាំគ្នាទៅអស់បានអ្នកណានៅមើលម៉ាក់ហាំ ? "

ដាភច័ន្ទគ្រវីក្បាល ៖

-" បងស្មានថាខ្ញុំមិនចេះកាន់កាំភ្លើងបាញ់ឬ ? មើលនែ៎, ផាំង ! ... ផាំង ! ..." និយាយទាំងធ្វើត្រាប់កាយវិការទាហានកាន់កាំភ្លើងបាញ់ ។ "ឃើញទេ ? អាយៀកកុងស្លាប់ទ្រេល ! "

អ្នកទាំងអស់ទប់សំណើចមិនបាន ចំពោះអាកប្បកិរិយារបស់កុមារដាភច័ន្ទ ។ ស៊ីវណ្ណាបន្ទឺឡើង ៖

-" សមហើយ ! សមជាអ្នកបាញ់ហើយ ! ណ្ហើយ នៅផ្ទះសិនទៅ កុំទាន់អាលទៅអី ចាំកាលណាបងស្លាប់ទៅ អូនឯងនៅសងឈាមឲ្យបងណាំ ! "

អ្នកស្រី បែរឡាំង ជាម្ដាយក៏ក្ដាប់ឃ្លា ៖

-" ហ្នឹងហើយ ច័ន្ទឯងនៅមើលម៉ាក់ កុំទៅអី ! "

ដាភច័ន្ទធ្វើមុខស្ពេះ ដាក់បន្ដយទាំងភ្នែកម៉ក់ៗ ។

ឡៀប-វណ្ណដាក់ ឃើញប្អូនអន់ចិត្តដូច្នោះ ក៏ចូលមកលួងលោម ៖

-" អូនឯងនៅក្មេងណាស់ កាន់កាំភ្លើងមិនទាន់ទំនងទេ នៅផ្ទះមើលម៉ាក់ទៅ ចាំបងកាត់ខោគ្រែអីឲ្យស្លៀកដើរលេងណាំ ! "

www.elibraryofcambodia.org

ទន្ទឹមគ្នានឹងកំហឹងនាងផុតរលត់ នៅឯមាត់ទ្វារឯណោះ បុរសម្នាក់ចាស់ម៉ាំបន្តិច ដើរចូលមក ។ ទាំងអស់គ្នានៅទីនោះ ក្រៅពីអ្នកស្រីជាម្ដាយបន្លឺព្រមគ្នា ៖

-" ហ្ន៎, ប៉ាមកហើយ ! ... "

លោក ឡៀប-ស៊ីម មានទឹកមុខញញឹមពីនាយ ឃើញកូនៗ នៅជុំគ្នានឹងកិរិយា ក៏បន្លឺសួរ ៖

-" អើ, មានរឿងអីដែរថ្ងៃណេះ ? ..."

ឡៀប-វណ្ណដារ៉ាងាកមើលមុខម្ដាយបន្តិច ទំនងចង់ឲ្យម្ដាយនាំរឿងនេះជម្រាបឪពុក ។ អ្នកស្រីយល់ចិត្តបុត្រីក៏ពោល ៖

" អាមាយ និង វណ្ណា ចង់ធ្វើកុម្ម៉ង់ដូហាត់នៅសាលា តើបងអនុញ្ញាតឬទេ ? "

លោកប្រុសដើរចូលទៅអង្គុយទល់មុខអ្នកស្រី ដកបារី ៥៥៥ មកអុជពិសារ ទើបបញ្ចេញប្រសាសន៍ ៖

-" គេមានបញ្ជូនឲ្យទៅច្បាំងឯណាដែរឬ ?"

ឡៀប-វណ្ណដារ៉ា ពន្យល់ឪពុកយ៉ាងរួសរាន់ ៖

-" អត់ទេប៉ា ! កាលណាពួកខ្ញុំរៀនចេះទៅ គេឲ្យនៅយាមការពារសាលា ក្រែងពួកអាយៀកកុងវាចូល មកយកសាលាយើងឬបំផ្លាញចោលណាំប៉ា !"

លោកប្រុសប្រមុខគ្រួសារងក់កេសា ៖

-" ល្អម្យ៉ាងដែរ ! បើកូនឯងចង់ធ្វើក៏ធ្វើទៅចុះ ប៉ាមិនឃាត់ទេ ! "

ឮឪពុកមានប្រសាសន៍ដូច្នោះ, នាង ឡៀប-វណ្ណដារ៉ា សែនរីករាយក្នុងចិត្តយ៉ាងខ្លាំង ។

ក្នុងវ័យ ១៩ ឆ្នាំ នាង ឡៀប-វណ្ណដារ៉ា កំពុងពេញសម្រស់គ្រកាល មានចិត្តម៉ឺងម៉ាត់ព្យាយាមក្លាហាន មានកិរិយាសុភាពរាបសាររមទម្យ ។ ឆ្នាំនេះនាងរៀននៅថ្នាក់ទី ១ ទំនើប "ឆ" នៃវិទ្យាល័យសៀមរាប ។ នាងកើតនៅថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៥១ នៅសង្កាត់លេខ២ក្រុងភ្នំពេញ ជាសុភាពសិស្សនារី ដែលនរណាក៏តែងកោតសរសើរមិនដាច់ពីមាត់ ។ លើសពីនេះទៅទៀត នាងចេះធ្វើឲ្យអ្នកផងស្រឡាញ់រាប់អាននាងណាស់ ជានារីមិនចេះកាច់រាង ឆ្មើងកន្ទ្រើងឡើយ ។ មិត្តភក្តិរបស់នាងជាច្រើនទាំងស្រីទាំងប្រុស និយមរាប់អាននាងណាស់ ។ នាងចេះធ្វើឲ្យគេសប្បាយចិត្ត ចេះធ្វើឲ្យអ្នកផងបានស្រាកស្រាន្តនូវទុក្ខកង្វល់ទាំងឡាយផង ។

នាងបានចូលសិក្សានៅវិទ្យាល័យសៀមរាប នៅថ្ងៃទី ២៥ ឧសភា ឆ្នាំ ១៩៦៤។ នៅឆ្នាំ ១៩៦៨ នាងបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សានៅវិទ្យាល័យសៀមរាប ហើយបន្តការសិក្សាមកទៀត ទល់ថ្ងៃមានព្រឹត្តិការណ៍ ១៨មីនា ១៩៧០ កើតឡើង ។

នៅក្នុងរយៈពេលនៃការសិក្សារបស់នាង មិនសូម្បីតែសិស្សជាមិត្តប៉ុណ្ណោះទេ ដែលស្រឡាញ់រាប់អាននាង រហូតដល់សាស្ត្រាចារ្យទាំងឡាយ ក៏រមែងថ្លែងសេចក្ដីសរសើរមិនដាច់ពីមាត់ ។ ទាំងនេះគឺមកពីនាងជានារីដែលចេះស្គាល់តម្លៃក្នុងការរស់នៅពិតប្រាកដ ។

ម្យ៉ាងទៀត ក្រៅពីនាងចេះធ្វើឲ្យសង្គមមនុស្សទូទៅរាប់អាន នាង ឡៃ-វណ្ណ ជាក់ស្ដាល់ទុក្ខធុរៈអ្នកផងណាស់ ។ ពេលណាជាថ្ងៃសម្រាកសិក្សា នាងតែងតែជួយធ្វើការនៅផ្ទះជំនួសដៃជើងម្ដាយហើយបម្រើប្អូនតូចៗ ឯទៀត ។

អ្នកជិតខាងទាំងអស់ តែងលបលួចសួរគ្នីគ្នាថា ៖

-" នុ៎ះ, តើ កូនចៅនរណាគេក៏សុភាពរាបសារម្ល៉េះ ? "

អ្នកខ្លះដែលធ្លាប់ស្គាល់ក៏ប្រាប់ទៅវិញ ៖

-" អុំ ! កូនអ្នកគ្រូបែរឡាំងនោះអី ! អ្នកមិនធ្លាប់ស្គាល់ទេ ? ពូជអំបូរគេល្អណាស់ ! "

និយាយខ្លីទៅ, នាងជានារីឧស្សាហ៍ទាំងគ្រប់បែបយ៉ាង ។

ម្ល៉ោះហើយម្ដាយឪពុក មិនអាចមានការលំបាកខ្វល់ខ្វាយច្រើនឡើយ ។

គាត់តែងឮអ្នកជិតខាងលួចសរសើរ ពីអកប្បកិរិយាកូនស្រីតែរឿយៗ ។ ការណ៍នេះរឹងរិតតែធ្វើឲ្យគាត់ស្រឡាញ់និងទុកចិត្តលើកូនស្រីពេញទំហឹងចិត្ត។ ធម្មតា, ម្ដាយឪពុកកាលណាមានកូនសមប្រកបដូច្នេះ រមែងសប្បាយរីករាយក្នុងចិត្តណាស់។ គាត់តែងបណ្ដោយតាមចិត្តកូនដោយមានជំនឿយ៉ាងមុតមាំថា កូនស្រីរបស់គាត់ពិតជាស្ថិតនៅក្នុងខ្នងនៃចរិយាធម៌និងសីលធម៌មិនឃ្លាត ឬមិនធ្វើឲ្យគាត់លំបាកចិត្តឡើយ។ លោកបានសម្គាល់ឃើញលក្ខណៈពិសេសរបស់កូនយ៉ាងនេះហើយ ទើបទុកចិត្តទាំងស្រុងទៅលើឧត្ដមគតិ របស់កូនថា មិនងាយប្រព្រឹត្តអំពើផ្ដេសផ្ដាស់ នាំស្មុយកេរ្តិ៍ឈ្មោះដល់ត្រកូលឡើយ ។

លក្ខណៈពិសេសនេះឯងហើយ ធ្វើឲ្យសង្គមមនុស្សទៅរាប់អាននាងគ្រប់គ្នា ។ មិនថាមជ្ឈដ្ឋានសិស្សដូចគ្នា ឬមជ្ឈដ្ឋានសាស្ត្រាចារ្យប៉ុណ្ណោះទេ សូម្បីអ្នកផងដែលធ្លាប់ឃើញនាងរមែងចង់ស្គាល់នាងណាស់ដែរ ។

www.elibraryofcambodia.org

នាង ឡៅ-វណ្ណដាក់ មានមាឌស្រឡះសមសួន, កងសន្ដា, សក់ខ្មៅរលើប រៀបដូចស្លាបកំភេម ស្ទួតសំយុងវែងប៉ប្រះចង្កេះ ។ មុខមូលកំផ្លង់ៗ សមសក្ដិនឹងនេត្រាទាំងគូខ្មៅក្រិបដូចនិល ។ នាងមានប្រជ្រុយខ្មៅមួយប៉ុនចុងចង្កឹះនៅលើបបូរមាត់ខាងឆ្វេង ។ តាមសភាពក្រៅរបស់នាង, បើអ្នកមិនធ្លាប់ស្គាល់ច្បាស់ជាយល់ច្រឡំថា ជានារីកន្ទ្រើះស្អរឆ្មើងកាចហើយ ។ តែការពិត, ប្រសិនណាគេបាននៅជិតនាងយូរទៅ, គេនឹងអាចស្គាល់ច្បាស់នូវទឹកចិត្តបរិសុទ្ធរបស់នាង ព្រោះនាងជាមនុស្សចេះឈឺឆ្អាលជួយធុរៈគេណាស់ ។ នាងមិនរើសត្បៀងខ្លួនឡើយ, ចេះធ្វើខ្លួនឲ្យស្រប តាមកាលៈទេសៈ ពេលគឺប្រសិនជានាងចូលចំណោមគេចាស់ទុំ សម្ដីនិយាយរកចាស់មានការគួរសម, ចាំចាស់ៗ ជជែកលេងពីរឿងផ្សេងៗ ធ្វើឲ្យគាត់សប្បាយរីករាយ, ហើយប្រសិននាងចូលចំណោមក្មេងៗ វិញ បរិយាកាសនោះត្រកាលត្រកុំដោយសារនាងចេះនិយាយបញ្ចុះបញ្ចូល ធ្វើឲ្យគេបានសើចសប្បាយគ្រប់គ្នាៗ ម៉្លោះហើយ នាងក៏សម្បូណ៌ដោយអ្នកចូលចិត្តច្រើន ។ រាប់បានថាកល្យាណមិត្តនារីកម្ររកបានណាស់ ។

ក្នុងសង្គមគ្រួសារក៏យ៉ាងដូច្នោះដែរ, នាងជាស្នើគ្រួសារពិតប្រាកដ ។ ពេលដែលគ្រួសារមានការតប់ប្រមល់ស្អុះស្អាប់ ឡៅ-វណ្ណដាក់ ចេះនិយាយ ចេះធ្វើឲ្យគ្រួសាររបស់នាងបានធូរស្រាលច្រើន ។ គឺពីព្រោះតែសភាពបែបនេះហើយ បានជាគេកម្រឃើញគ្រួសារនេះមានទុក្ខព្រួយណាស់ ។

ម្ដាយរបស់នាង ធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាសៀមរាបក្រុង មានកូនប្រាំបួននាក់ គឺប្រុសប្រាំនាក់និងស្រីបួននាក់ ។ នាង ឡៅ-វណ្ណដាក់ ជាកូនស្រីច្បងបង្អស់ រៀននៅថ្នាក់ទីមួយទំនើបជាតិនៃវិទ្យាល័យសៀមរាប ។ កូនទីពីរជាកូនប្រុសឈ្មោះ ឡៅ-ស៊ីវណ្ណា រៀននៅថ្នាក់ទីបីទំនើបជាតិ និងកូនទីបីប្រុសរៀននៅថ្នាក់ទីបួននៃវិទ្យាល័យសៀមរាបដែរ ឈ្មោះ ឡៅដាក់រិទ្ធិ ។ ចំណែក ឡៅដាកច័ន្ទ កូនប្រុសទីបួនរៀននៅថ្នាក់ទីប្រាំ និង ឡៅសុវត្ថា រៀនថ្នាក់ទីប្រាំមួយ នៅវិទ្យាល័យដដែល ។ បន្ទាប់មក, កូនទីប្រាំមួយជាកូនស្រីឈ្មោះ ឡៅ ដាក៉ក័ន់ រៀនថ្នាក់ទីប្រាំពីរ, កូនទីប្រាំពីររៀនថ្នាក់ទីប្រាំបី ឈ្មោះ ឡៅ-សូលីដា (ប្រុស), ឯកូនទីប្រាំបីជាស្រីរៀនថ្នាក់ទីដប់ ឈ្មោះនាង ឡៅសូឡានី និងពៅគេគឺទី៩ ជាស្រីដែរ រៀនថ្នាក់ទី ១២ ឈ្មោះនាង ឡៅ-ដូលីណា ។

ក្រោយពីបានការអនុញ្ញាតពីមាតាបិតាហើយ ឡៅ-វណ្ណដាក់ ហៅ មាយ ក៏បានចូលធ្វើកុម្មង់ដូសិស្សនៃវិទ្យាល័យសៀមរាបចាប់ពីពេលនោះមក ។

www.elibraryofcambodia.org

វគ្គទីពីរ

# កូនខ្លាកងកុម្ម៉ង់ដូ

ស្ថិតក្នុងក្របខ័ណ្ឌនៃឧត្តមគតិស្នេហាទឹកដីនេះឯងហើយ កញ្ញាឡៅឌៀប-វណ្ណដារ៉ា បានសម្រេចចិត្តប្រគល់ខ្លួន ស្ម័គ្រធ្វើកុម្ម៉ង់ដូដោយតម្កល់ស្មារតីតស៊ូយ៉ាងមោះមុត ជាមួយមិត្តភក្តិជាកុម្ម៉ង់ដូសិស្សទាំងឡាយឯទៀត ។ នេះពិតជាសក្ខីភាពរបស់នាងដ៏បរិសុទ្ធថ្លៃថ្លា នៃទឹកចិត្តស្នេហាបូណកាពទឹកដីជាកេរ្តិ៍មរតកខ្មែរ ។ យើងឃើញច្បាស់ហើយថា ការដែលនាងចូលខ្លួនបម្រើជាតិ មិនមែនដោយសេចក្តីបង្ខំពីជនប្រភេទណាឡើយ គឺពិតជាកើតឡើងពីសន្តានចិត្តស្នេហាជាតិរបស់នាងដោយសុទ្ធចិត្ត ។ គ្រួសារនាងមានទ្រព្យសម្បត្តិស្តុកស្តម្ភបន្តិចដែរ ធ្លាប់រស់នៅដោយសេចក្តីថ្លៃថ្នូរៗក៏ប៉ុន្តែពេលនេះជាតិត្រូវការហើយ ត្រូវការរូបនាងដើម្បីប្រយុទ្ធប្រឆាំងចំពោះអំពើឈ្លានពានទឹកដីពីសំណាក់ចោរព្រៃវៀតកុង នាងបានលះបង់សេចក្តីសុខសាន្តលើគំនរទ្រព្យសម្បត្តិ បូជាសម្ភស្ស បូជាកាយនិងចិត្ត លើកកាំភ្លើងប្រយុទ្ធដោយអង់អាច ប្រយុទ្ធក្នុងសន្ទុះចិត្តក្តៅក្រហាយចំពោះពួកទមិឡ ដែលឈ្លានពានដីរបស់ខ្មែរមួយ ។

ក្រោយពីពួកវាវាយប្រហារដោយបរាជ័យ ទៅលើខេត្តនានារបស់រដ្ឋនៃកម្ពុជាមក ពួកចោរឈ្លានពានបានធ្វើការសាកល្បងខ្លះ ដើម្បីវាយលុកដណ្តើមយកទីរួមខេត្តសៀមរាបមកកាន់កាប់ទាំងមូល ។ ហេតុការណ៍នេះហើយ ដែលជម្រុញទឹកចិត្តកូនខ្មែរគ្រប់រូបឲ្យក្រោកឈរឡើង វាយសំពងក្បាលអាវៀតកុង-យួនខាងជើងដោយឥតរួញរា ។ ជាពិសេសកូនខ្មែរនៃខេត្តសៀមរាប ដែលរងដោយអំពើឈ្លានពាននេះ បានស្ម័គ្រចិត្តកាន់កាំភ្លើងគ្រប់ដៃ ប្រយុទ្ធបណ្តេញក្បាលអាចង្រៃឲ្យវិនាសព្រាត់ប្រាសទៅជាមួយបរាជ័យយ៉ាងជូរចត់ ។

ដូច្នេះហើយ ដើម្បីឆ្លើយតបទីងសេចក្តីត្រូវការរបស់មាតុប្រទេស ក្នុងការដេញកំចាត់ខ្មាំងចោរឈ្លានពានទឹកដីខ្មែរ គឺអាយួនវៀតកុង-វៀតណាមខាងជើងនេះកងកុម្ម៉ង់ដូសិស្សបានទទួលសិស្សប្រុសចំនួន ៥៣៤ នាក់និងសិស្សស្រីចំនួន ៤០ នាក់ នៃវិទ្យាល័យសៀមរាប និងអនុវិទ្យាល័យអង្គរ ដែលស្ម័គ្រចិត្តចូលខ្លួន ដើម្បីហ្វឹកហ្វឺន

វិជ្ជាយុទ្ធសាស្ត្រក្នុងបរិវេណវិទ្យាល័យសៀមរាប ចាប់តាំងពីថ្ងៃទី ៥ មេសា ១៩៧០ ទៅ ដោយមានលោកអនុសេនិយឯក អ៊ុំ អ៊ិត ជាមេបញ្ជាការ និងលោក ទេង-ធុង នាយកវិទ្យាល័យសៀមរាប ជាមេបញ្ជាការរង ។ ការបង្ហាត់បង្រៀននេះ បានរៀមច្បង ខាងទាហានចូលមកជួយមានជាអាទិ៍ លោកអនុសេនិយឯក គិម-ឡេ, លោកអនុ-សេនិយត្រី ប៉េង ម៉ែម (ទាហានសកម្ម) លោកអនុសេនិយទោ ប៉ុក-សារួន, លោកអនុសេនិយទោវេជ្ជបណ្ឌិត អ៊ិត ឆប, លោកអនុសេនិយត្រី ទៀង មិន (ទាហានបម្រុង) និងអស់លោកនាយទាហានរងសកម្មនិងនាយទាហានរងបម្រុងច្រើនរូបទៀត ដែលបានជ្រោមជ្រែងការហ្វឹកហ្វឺននេះឲ្យមានសភាពដ៏ជាទីទុកចិត្ត[១] ។

ចាប់តាំងពីពេលនោះមក, បរិវេណនៃវិទ្យាល័យសៀមរាប បានក្លាយទៅជាវាលសម្រាប់ហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រ នៃកងកុម្មង់ដូសិស្សយ៉ាងសកម្ម ....

-" មួយ ! ពីរ ! .... មួយ ! ពីរ ! .... ប្រយ័ត្ន ! ឈប់ ! .... " នេះជាសម្លេងរបស់នាង ឡៀប-វណ្ណដារ៉ា បញ្ជាមិត្តកក្តិងទៀត ។

ព្រឹប ! .... ស្នើគ្នាហាក់បីដូចមានសម្លេងតែមួយ, កងអនុសេនាធំបញ្ជាការឈប់ព្រមគ្នា ។

ឡៀប-វណ្ណដារ៉ា ហៅសារហួនទៅទៅម្នាងស្រែកបញ្ជាយ៉ាងអង់អាចសាជាថ្មី ៖

-" ស្តាំ ! .... បែរ ! ....."

ក្រោយពីកងបញ្ជាការធ្វើតាមបង្គាប់ហើយ ទើបនាងបញ្ជាឲ្យសម្រាក ។ បន្ទាប់មក នាងដើរចុះឡើងបន្តិចទាំងបញ្ចេញផ្កាញញឹមស្រស់ដាក់មិត្រឯទៀតដែលស្ថិតក្នុងជួរ ។ មិត្រកក្តិទាំងឡាយមានញើសជាបដូចជានាងអ៊ីចឹងដែរ កាលបើឃើញទឹកមុខញញឹមរបស់នាងដូច្នេះ ហាក់ដូចជាមានកម្លាំងត្រឹសឡើង ។

ឡៀប-វណ្ណដារ៉ា អបសួបសម្តីជាមួយសម្រស់ញញឹម ៖

-" ខ្ញុំយល់ថា មិត្តទាំងអស់គ្នាមានការនឿយហត់ច្រើន, នៅក្រោមកម្តៅថ្ងៃឥតមេឃានេះ ខ្ញុំជឿថាមិត្តស្រីៗ យើងទាំងអស់ច្បាស់ជាទ្រាំមិនបានទេ ..."

រំពេចនោះ, សម្លេងមួយបើរកាត់ជាបន្ទាន់ពីក្នុងជួរមក ៖

-" មាយអើយ! ក្តៅប៉ុណ្ណឹងមានអីទីងគួរឲ្យថ្ងូរទេ បើអ្នកស្រែធ្វើការក្តៅជាងនេះទៅទៀតគាត់មិនថ្ងូរផង ។ គ្នាសូមលើកដៃមុនគេហើយថាអត់មានថ្ងូរទេ, បើបាន

---

(១) សម្រួលតាមសេចក្តីរាយការណ៍របស់កងវរសេនាតូចយុវជនស្បៀវភៅនៃលោកគ្រូមិភាគទី ៥ ។

www.elibraryofcambodia.org

ក្តៅជាងនេះទៅទៀតរឹតតែបាយបានច្រើនណាស់ទៀត ។ អើ, ក្រែងតែបងកៅឯងខ្វះបាយឲ្យគ្នាញ៉ាំផងមិនដឹង !...."

មិត្តភក្តិក្នុងជួរផ្ទុះសំណើចលាន់ឡើងបំបាត់នូវការនឿយហត់អស់មួយគ្រា ។ បន្ទាប់មក ឡៀប-វណ្ណដាក់ បន្តតបក្នុងន័យកំប្លែងជាមិត្តភាព ៖

-" អាម៉ាប់ឯងខ្វះបាយតែញយហ្នឹង, មិនបាច់ចាំថាហត់ឬមិនហត់ហាលថ្ងៃទេ ។ កាលពីថ្ងៃអាទិត្យមានហត់ឯណា, ម៉េចក៏អាម៉ាប់ឯងវាត់អស់ដល់ទៅបួនចាន ហ្ន៎ះ ?"

អ្នកឯទៀតនាំគ្នាទប់សំណើចមិនបាន ហើយចោលភ្នែកទៅរកនាងម៉ាប់ដែលឡើងមុខក្រហមដោយការអៀនខ្មាស់ ។ នាងតបទាំងញញឹម ៖

-" ចុះនរណាប្រើឲ្យមាឃឯងធ្វើម្ហូបឆ្ងាញ់ធ្វើអី ? "

ព្រះអាទិត្យជាមេកម្តៅ បានអណ្តែតទៅជ្រកក្នុងរបាំងពពកមួយផ្ទាំងបណ្តាលពិភពលោកនេះឲ្យស្រទុំស្រទន់អស់មួយរយៈ ។ ប៉ុន្តែចំហាយនៅតែធ្វើឲ្យទឹកវាលនៃខ្យល់យ៉ាងសៀមរាបត្តិនខ្លាចជាស្រេចដែល ។

នៅពេលសម្រាកនេះ, ឡៀប-វណ្ណដាក់ បាននាំមិត្តភក្តិគេឲ្យសើចសប្បាយរីករាយ ដើម្បីបំភ្លេចនូវភាពស្អុះស្អាប់ដែលមេឃពុំព្រមប្រណី ។

ខណៈនោះ, នៅឯម្ខាង បុរសម្នាក់ជានាយទាហាន មានឯកសណ្ឋានជាកងឆ័ត្រយោង មានឋានន្តរសក្តិជាអនុសេនីយឯក, កំពុងធ្វើដំណើរយ៉ាងអង់អាចទាំងទឹកមុខស្រស់បស់មករកកងកុម្ម៉ង់ដូនាវី ។ គាត់មានរាងជាត់មាំខ្មៅក្រអាញ សក់កាត់ជ្រុងផ្កាថ្ងៃ, សមជាមនុស្សមុតមាំណាស់ ។

ឡៀប-វណ្ណដាក់ ងាកទៅឃើញនាយទាហានភ្លាម ក៏ស្រែកឡើងទាំងទះដៃត្រេកអរ ៖

-" សួស្តី ! ប៉ា ប៉ា ! ... "

នាយទាហាននេះជាអនុសេនីយឯក គិម-ឡៅ មាននាទីជាអ្នកបង្ហាត់កងកុម្ម៉ង់ដូនាវី ។ គាត់ញញឹមតប ៖

-" អើ, ម៉េចទៅពួកអ្នក ហាត់ដើរត្រូវជើងគ្នាហើយឬនៅ ? "

-"ចាំ៎ះ! ប៉ា ប៉ា !...នៅតែអាម៉ាប់ម្នាក់ទេ ដូចជាអឹកអាក់ជាងគេណាស់ប៉ាប៉ា !..?" ឡៀប-វណ្ណដាក់ បន្ថែមទាំងសើចផង ។

នាងម៉ាប់ឮដូច្នោះក៏ឆ្លើយឡើង ៖

–" លោកគ្រូ, ពួកហ្វ៊ូង៍អាង់តែទុំដើមិនលឿន នាំគ្នាដាក់លេខ ១២០ ឲ្យនរណាតាមទាន់ ! "

លោកសក្តិបី គិម-ឡេា សើច ៖

–" អើ, អាហៃណាំឯងកង់ដូចទាគាប៉ាយ៉ាង់ហ្វ៊ូង៍ បានជាគេឲ្យដើរក្រោយគេណាំ ! " គាត់ស្មៀមបន្តិច ទើបបន្ត ។

–" អើ, ពួកឯងសម្រាកហើយឬ ? "

ឡៀប-វណ្ណដារ៉ា តប ៖

–" ចាំៈ ! ប៉ា ប៉ា !, ការហាត់ដើរដូចជាសមដើង៍ហើយ, តើដល់កាលណាបាន ប៉ាប៉ាឲ្យរៀនកុមបា ( combat ) ? "

លោក គិម-ឡេា មើលមុខនាង វណ្ណដារ៉ា បន្តិច ហើយង៉ាកទៅសិស្សនារីឯទៀត ដែលស្ថិតនៅក្នុងជួរដោយសេចក្តីអាណិតអាសូរ ។ គាត់បានកត់សម្គាល់ឃើញ ទឹកចិត្តក្លាហានតស៊ូរបស់យុវនារីទាំងនេះដោយច្បាស់លាស់ណាស់ ។

គាត់មិនបានឆ្លើយតបទៅ ឡៀប-វណ្ណដារ៉ា ភ្លាមទេ បែរជាបញ្ជាដូច្នេះវិញ ៖

–" អើ ! ពួកអ្នកង៍ នាំគ្នាបំបែកជួរហើយចូលទៅជ្រកម្លប់ក្រោមដើមចំបក់ ខាងណោះទៅ ! "

ឡៀប-វណ្ណដារ៉ា ទទួលបញ្ជាហើយបង្អាប់ឲ្យមិត្តកក្តិនាង ៖

–" ប្រុង ! " រួចបំបែកជួរ ។

ក្រោយមក, សិស្សនារីកុម្ម៉ង់ដូទាំងអស់បានមកជួបជុំគ្នានៅក្រោមដើមចំបក់ ដែលមានមែកស៊ុបទ្រុបល្មមអាចជ្រកម្លប់បាន ។ ព្រះអាទិត្យអណ្តែតផុតពីផ្ទាំងពពក បញ្ចេញរស្មីៈយ៉ាងខ្លាំងក្លា ហាក់បីដូចជាចង់ធ្វើឲ្យលោយសៀមរាបទាំងមូលឲ្យលោយ ។ ប៉ុន្តែទោះបីអាទុកាពក្តៅហួតហែងយ៉ាងនេះក៏ដោយ ក៏ពុំអាចបំបាក់ទឹកចិត្ត មិត្តនារីកង៍កុម្ម៉ង់ដូសិស្សទាំងនោះ ឲ្យចុះចាញ់បានឡើយ ។ ផ្ទុយទៅវិញ, គេកាន់តែ ឃើញច្បាស់ នូវទឹកចិត្តអង់អាចល្យាយាមមុះមត់ ឥតត្អូញត្អែរបន្តិចនៃកូនស្រីខ្មែរ ។

លោកអនុសេនិយឯក គិម-ឡេា ស្រឡាញ់រាប់អានសិស្សទាំងអស់ទុកដូចជា កូនបង្កើតដូច្នោះ ។ ថ្វីបើគាត់មានបណ្តាសក្តិខ្ពស់ដូច្នេះ, តែគាត់មិនចេះប្រកាន់ឫក លើកកម្ពស់ឡើយ ដែលជាហេតុញុាំងកង៍កុម្ម៉ង់ដូទាំងអស់ឲ្យគោរពទុកដូចឪពុក ។

សេចក្តីរាប់អាននេះ បាននាំឲ្យបរិយាកាសនៃការហាត់រៀនប្រកបទៅដោយ សភាពគ្រួចៈគ្រួចង៍និង៍ជាទីទុកចិត្ត ។

www.elibraryofcambodia.org

លោកអនុសេនិយឯកឈរនៅចំកណ្ដាលវង់សិស្សកម្ពុជ ដោយកក្រោកក្បាកាពញញឹមប្រិមប្រិយដដែល ៖

-" លោកគ្រូបានឃើញអ្នកទាំងអស់គ្នា យកចិត្តទុកដាក់នឹងការហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនេះណាស់, លោកគ្រូសប្បាយរកអ្វីប្រៀបស្មើពុំបាន ។ លោកគ្រូមានជំនឿថា អ្នកទាំងអស់គ្នា សុទ្ធសឹងជាអ្នកដែលមានចិត្តស្នេហាជាតិដូចគ្នា ហើយស្អប់ពួកឈ្លានពានទឹកដីខ្មែរយើងគ្រប់គ្នាទាំងអស់, មិនអីចឹងទេឬ ? "

គេឆ្លើយព្រមគ្នាក្នុងចិត្តគំនិតតែមួយ ធ្វើឲ្យវង្វង់នៃការប្រជុំមានសភាពកាន់តែក្រកុំក្រកាលឡើង ។

នាងម៉ាប់បន្លឺឡើង ៖

-" ជាពិសេស, ខ្ញុំស្អប់អាយួនឆ្កួញខ្មៅហ្នឹងជាងគេ ព្រោះវាដំ, វាដំ, វាជាចោរលួចតាំងពីខ្មែរទាលម៉ូអែន្ត្រស៊ីឡើងទៅ ! "

អ្នកទាំងអស់គ្នា ទះដៃហ៊ោសប្បាយនឹងសម្ដីរបស់នាងម៉ាប់ដែលបន្លឺឡើង ។

រំលងប៉ុន្មាននាទីបន្ទាប់មក លោកសក្ដិបីក៏បន្លឺបន្តទៅទៀត ៖

-"ថ្ងៃក្ដៅស្មើរបែកក្បាល, យើងសម្រាកកន្លះម៉ោងសិនចុះហើយសឹមលោកគ្រូបង្រៀនពួកឯងឲ្យចេះកាន់កាំភ្លើង "។ គាត់រវៃក្នុកមើលអ្នកទាំងអស់គ្នាបន្តិច។ "លោកគ្រូឃើញអ្នកទាំងអស់គ្នាសុទ្ធតែអង់អាច ច្បាស់ជាគ្មាននរណាម្នាក់មិនញញើតនឹងកាន់កាំភ្លើងទេ មែនទេ ? "

គេទាំងឡាយ ឮលោកគ្រូយុទ្ធសាស្ត្រថាបង្រៀនឲ្យចេះកាន់កាំភ្លើង មានចិត្តរំភើបជាខ្លាំង, ឆ្លើយព្រមគ្នា ៖

-" អត់ញញើតទេលោកគ្រូ ! "

ជាបន្ទាប់, ឡៀប-វណ្ណដារ៉ា ក៏បន្លឺឡើង ៖

-" ប៉ា ប៉ា ! ពួកយើងទុកចិត្តខ្លួនឯងស្រេចហើយថា នឹងកាន់អាវុធប្រយុទ្ធយ៉ាងអង់អាច ប្រសិនខ្មាំងហ៊ានដាន់ជាយសាលា ... ប៉ាប៉ាមិនទុកចិត្តកូនទេ ? ប៉ាប៉ាស្មានថាមានតែពួកប្រុសៗ ទើបកាន់កាំភ្លើងបានឬ ? "

លោក គិម-ឡេា ញញឹមពេញចិត្ត ៖

-" កូនស្រីប៉ាប៉ា ! ប៉ាប៉ាទុកចិត្តហួសពីទុកចិត្តហើយ, ប៉ាប៉ាគ្រាន់តែក្រែងទេតើព្រោះអ្នកប្រាជ្ញខ្លះតែងពោលថា ស្រីៗ ច្រើនមានចិត្តទន់ខ្សោយនៅចំពោះមុខគ្រោះថ្នាក់ ។ អើ, ក៏ប៉ុន្តែ ពួកឯងក៏មិនមែនគេបញ្ជូនឲ្យវាយប្រយុទ្ធឯណាដែរ, ហាត់រៀនគឺ

www.elibraryofcambodia.org

ដើម្បីការពារផ្ទះនៃវិទ្យាល័យប៉ុណ្ណោះ ។ តែបើថាពួកវាចូលវាយសៀមរាប ប្រសិនពួកទាហានខ្វះខ្នាត គេនឹងហៅពួកឯងទៅ ...."

ឡៀប-វណ្ណដារ៉ា ហេតុតែនារីមាននិស្ស័យចិត្តក្លាហាន ក៏បន្ទីបន្ត ៖

-" ប៉ាប៉ា ! កូនអត់ខ្លាចទេ, ស្លាប់ក្រោមទង់ជាតិ ដើម្បីជាតិ-សាសនានិងទឹកដី កូនត្រេកអរណាស់ ។ កូនមានអាវុធនៅដៃ, ស្ត្រីខ្មែរមិនអនុញ្ញាតជាដាច់ខាតឲ្យពួកវាចូលមកចាប់បានដោយស្រួលឡើយ ។ "

មិនចំពោះតែលោកអនុសេនីយឯកម្នាក់ប៉ុណ្ណោះទេ ដែលមានការព្រឺស្បែកដោយរំភើបចិត្តតាមលោកសម្ដីដ៏មានខ្លឹមសាររបស់នាង, សូម្បីមិត្តភក្ដិស្រីៗ ឯទៀតក៏ហាក់ដូចជាផុសចិត្តក្លាហានឡើងជាលំដាប់ដែរ ។

ឡៀប-វណ្ណដារ៉ា បន្តទៅទៀត ៖

-" ប៉ាប៉ា ! កូនធ្លាប់រៀនប្រវត្តិសាស្ត្រសកលលោក ធ្លាប់បានឃើញស្ត្រីអង់អាចមិនចាញ់ពួកប្រុសៗ ប៉ុន្មានទេ ។ ចំណែកកូន បានប្ដេជ្ញាចិត្តថា មិនសុខចិត្តស្លាប់ដោយគ្មានបានបាញ់ក្បាលអាយៀកកុងឲ្យវាតៃហោងឡើយ ។

លោកសក្ដិបីត្រេកអរពេកទះដៃសាទរឡើង ៖

-" ចំជាប្រសើរ, កូនស្រីប៉ាប៉ា ! "

កញ្ញា ជា សាវេត ជាមិត្តនារីស្និទ្ធស្នាលរបស់ ឡៀប-វណ្ណដារ៉ា និងត្រូវជាក្មួយរបស់នាងផង បន្ទឹ ៖

-" លោកគ្រូ, សម័យឥឡូវនេះស្រីៗ មិនមែនចាញ់ប្រុសៗ ប៉ុន្មានទេ ។ បើប្រុសៗ ធ្វើអ្វីកើត ស្រីៗ ក៏គោងតែធ្វើអ្វីនោះបានយ៉ាងដូច្នោះដែរណាលោកគ្រូ ! "

មិត្តឯទៀតទះដៃបន្ទរដោយត្រូវចំណុចចិត្ត ។ ឡៀប-វណ្ណដារ៉ា បន្តទៅទៀត ៖

-" ប៉ាប៉ា ! សម័យបដិវត្តន៍នេះ, យុវជនទាំងអស់ភ្ញាក់រលឹកគ្រប់គ្នា សាមគ្គីកំចាត់ខ្មាំងសត្រូវដោយឥតរួញរា ស្ម័គ្របូជាចិត្តគំនិតកម្លាំងកាយដើម្បីជាតិ ។ ប៉ាប៉ាឃើញស្រាប់ហើយ នៅពេលប្រទេសជាតិមានអាសន្ន, យុវជនទាំងអស់, ទាំងប្រុសទាំងស្រី សុខចិត្តផ្អាកការសិក្សាចូលខ្លួនបម្រើក្នុងកងទ័ពដោយស្មោះស្ម័គ្រ ។ នេះសឲ្យឃើញថា ទឹកចិត្តយុវជនខ្មែរស្នេហាទឹកដីមានសម្បជញ្ញៈជាតិដោយគ្រប់គ្រាន់ " ។

លោកសក្ដិបីញញឹមខ្ទឹបបន្ទឹ ៖

-" ប៉ាប៉ាជឿនិងទុកចិត្តលើគំនិតបដិវត្តន៍របស់យុវជនខ្មែរយើងហើយ ។ ប៉ាប៉ាជាទាហាន ជារបងការពារជាតិ បានលះជីវិតដើម្បីជាតិ-ទឹកដី មិនព្រមឲ្យខ្មាំងសត្រូវ

www.elibraryofcambodia.org

យកឪខ្មែរមួយជុំបានឡើយ ។ អាមាយ កូនស្រីប៉ាប៉ា គឺលក្ខណៈពិសេសនេះដែល ប៉ាប៉ាបានមកស្គាល់ពួកឯង ។ ប៉ាប៉ាកាន់តែមានជំនឿទៅលើអនាគតជាតិ ដោយពួកយុវជនទាំងអស់បានភ្ញាក់រលឹក ព្រោះអ្នកប្រាជ្ញតែងពោលថា យុវជនជាចន្ទល់នៃអនាគតជាតិ " ។

អ្នកទាំងអស់គ្នាទះដៃហ៊ោឡើង ៖

–" ប្រាវ៉ូ ! ប៉ាប៉ា ! ( Bravo ! Papa ! )

លោកអនុសេនិយឯក គិម–ឡេា នាំសិស្សស្រីជាកុម្ម៉ង់ដូនិយាយគ្នាសំណេះសំណាលពីនេះពីនោះបន្តិច ដើម្បីញ៉ាំងទឹកចិត្តអ្នកទាំងអស់ឲ្យក្លាហានឡើង ឲ្យមានសេចក្ដីសង្ឃឹមក្នុងកិច្ចហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រ ។

លំដាប់មក, លោកសក្តិបី គិម–ឡេា យកកាំភ្លើង ( Mauser 36 ) មកបង្ហាញពីរបៀបដោះដូត របៀបប្រើដល់ក្រុមសិស្សកុម្ម៉ង់ដូ ។ ក្រោយពីបង្ហាញឲ្យស្គាល់ឈ្មោះគ្រឿងគ្រាប់ របស់កាំភ្លើងហើយ, លោកឲ្យសិស្សម្នាក់ៗ រៀនដោះ ។

ដោះបណ្ដើរលោកពន្យល់បណ្ដើរ ។ ការណ៍នេះប្រព្រឹត្តទៅដោយឥតមានឆ្គួញឆ្គរឡើយ ទោះបីក្ដៅស្អុះស្អាបយ៉ាងណាក៏ដោយ ។ ម្នាក់ៗ មានញើសជោកខ្លួន ។ ជាពិសេសពួកខាងស្រីៗ មុខឡើងក្រហមហាក់បីដូចត្រូវភ្លើងកេល ។ តែដោយនាងចង់ចេះដឹងនូវចំណេះវិជ្ជានេះ ក៏ខំប្រឹងរៀនតទៅទៀត ដោយពុំគិតពីកម្ដៅថ្ងៃ ។

នាង ឡៀប–វណ្ណដារ៉ា ឆ្លាតវាងវៃណាស់, ឆាប់យល់ឆាប់ចាំ, ពេលនាងចូលទៅដោះកាំភ្លើងបានលេខមួយ ធ្វើឲ្យលោក គិម–ឡេា ជាគ្រូសប្បាយចិត្តជាខ្លាំង ។

ជម្រាបបញ្ជាក់ថា នាងតែងហៅលោកអនុសេនិយឯក គិម–ឡេា ថា "ប៉ាប៉ា" ។ ចំណែកលោកវិញស្រឡាញ់រាប់អានសិស្សកុម្ម៉ង់ដូដូចជាកូន ។ ការស្រឡាញ់រាប់អានគ្នានេះ
ធ្វើឲ្យសន្តិមមួយនៃកងកុម្ម៉ង់ដូសិស្សស្ថិតក្នុងភ្លេងសាមគ្គីភាពយ៉ាងថ្លៃថ្នូរជិតស្និទ្ធជាទីបំផុត ។

តាំងពីថ្ងៃហាត់មុនដំបូងរហូតមកដល់ពេលនេះ ឃើញថាពួកសិស្សកុម្ម៉ង់ដូទាំងអស់ មានសេចក្ដីចម្រើនល្អគួរណាស់ច្រើន ។ ទាំងនេះគឺ មកពីមនសិការនិងសេចក្ដីព្យាយាមមុះមុតរបស់គេតែប៉ុណ្ណោះ, ជាហេតុញ៉ាំងលោកគ្រូទាំងអស់ជាអ្នកបង្ហាត់បង្ហាញឲ្យមានចិត្តសប្បាយរីករាយឡើង ខំយកចិត្តទុកដាក់បង្រៀនគ្រប់យុទ្ធវិធី ។

លោកពន្យល់ជាអាទិ៍ថា ៖

www.elibraryofcambodia.org

-" ពួកអាយៀកកុងបានប្រើល្បិចសង្គ្រាមទ័ពព្រៃ, បារាំងហៅថា ( Guérilla ) ។ ជាសង្គ្រាមធ្លាក់វាយប្រហារមកលើយើងដោយឥតដឹងខ្លួនមុនឡើយ។ ដូច្នេះ, ក្នុងករណីណាក៏ដោយ, យើងមិនត្រូវប្រហែសធ្វេសមួយដង្ហើមទេ ត្រូវប្រយ័ត្នគ្រប់យាមវេលា ។ ពួកវាបានប្រើសង្គ្រាមធ្លាក់នេះនៅវៀតណាមមានលទ្ធភាពបន្តិចដែរ។ តែវាបានយកមកអនុវត្តលើប្រទេសកម្ពុជាយើងទៀត, លើកនេះវាបរាជ័យទាំងស្រុង ព្រោះមិនអាចអនុវត្តមកលើទឹកចិត្តមុតស្រួចដូចបន្លា នៃយុទ្ធជនទិនប្រជារាស្ត្រខ្មែរយើងបានឡើយ " ។

ក្នុងជួរនៃកងកុម្ម៉ង់ដូសិស្សវិទ្យាល័យសៀមរាប គេទាំងឡាយបានបញ្ជាក់នូវសេចក្ដីតស៊ូស្វិតស្វាញបំផុត ក្នុងការស្រឡាញ់ទឹកដីកេរ្ដិ៍មរតក របស់កូនខ្មែរស្នេហាជាតិពិតប្រាកដ ព្រោះក្នុងជួរនោះឯងហើយ គេឃើញនូវការទំនុះខ្នែងក្រោមកម្ដៅថ្ងៃស្ទើរបែកក្បាលរបស់យុវសិស្សខ្មែរគ្រប់រូប។ នេះក៏គឺជានិមិត្តរូបបញ្ជាក់កាន់តែច្បាស់ថា ពួកចោរយៀកកុង-យួនខាងជើងមិនអាចវាយបំបែកស្មារតីខ្មែរតស៊ូបានឡើយ ។

នៅពេលហាត់រៀនវិជ្ជាយុទ្ធសាស្ត្រនេះ, មិត្តសិស្សប្រុសស្រីរបស់យើងតែងបែកពេលហាត់តាមក្រុមៗ ។ ខ្លះហាត់ព្រឹក ខ្លះទៀតហាត់ល្ងាច ។ ដល់ចប់ការហាត់រៀនម្ដងៗ គេនាំគ្នាជិះកង់ម៉ូតូត្រឡប់ទៅផ្ទះវិញ ។

ខណៈនោះចំពេលវិស្សមកាលផង, សិស្សានុសិស្សប្រឹងប្រឹក្សតែបានឈប់សំរាកប៉ុន្តែគេមិនព្រមឈរឱបដៃមើលវៀមច្បងជាយុទ្ធជន ដែលកំពុងប្រយុទ្ធប្រឆាំងចោរឈ្លានពានបានឡើយ, គេសុខចិត្តលះបង់ពេលទំនេរពីការសិក្សាចូលមកបម្រើជាតិដោយស្មោះស្ម័គ្រ ។

*

* *

## វគ្គទីបី

# មិត្តដ៏ឧត្តម

ប្រាសាទក្រហ៊ន់លេចសម្ផស្សឡើងចំកណ្ដាលទេសភាពបំព្រង នាសាយណ្ហកាល ។

សិលាប្រាសាទជាបុរាណវត្ថុដ៏ប្រណីតនេះ ព័ទ្ធទៅដោយស្នែប្រវត្តិសាស្ត្រ ជានិមិត្តរូបបង្ហាញនូវតេជៈដៃអស្ចារ្យ ភ្ជាប់ជាមួយប្រាសាទអង្គរវត្តស្ដីមស្ដែ ឲ្យឃើញអរិយធម៌នៃប្រជាជាតិខ្មែរនាអតីតកាលរុងរឿង ។ នេះហើយជាតំណាងនៃញើសឈាមខ្មែរគេស៊ូប្ដូរបេ្ដជ្ញ ស្ថិតនៅគង់វង្សដល់បច្ឆាជនជាកូនចៅជាន់ក្រោយ ។

ផាំង ! ផាំង ! ... សម្លេងកាំភ្លើងពីរគ្រាប់ទើបលេបលាយតាមខ្សែអាកាសនៅវាលនៃប្រាសាទក្រហ៊ន់ ។

សំណើចគ្រេកអរក៏បន្លឺឡើង ៖

-" ប្រាវ៉ូ ! (Bravo!) "

នេះជាឧទានវាចារបស់កញ្ញា ល្មើង-វ៉ាដា ជាមិត្តស្និទ្ធស្នាលរបស់នាង ឡៀប-វណ្ណដាក់ ។

-" ឃើញទេ ? អាមាយ, ខ្លាបាញ់ត្រូវគ្រាប់បើដៃរតើ !" នាងបន្ទីបន្ថែមទាំងបញ្ចេញសភាពញញឹមស្រស់ ។

ឡៀប-វណ្ណដាក់ ផ្ដងកាំភ្លើងហៀបតាស់កៃទៅហើយ កាលបើឮមិត្តនារីពោលដូច្នោះ, ដាក់កាំភ្លើងចុះមកវិញទាំងញាក់ក្លែក ៖

-" អូខេ ! ( OK ) " រួចនាងសើចតប "ជោគជ័យមែន ! សូមឲ្យឯងបាញ់ក្បាលអាយៀកកុងត្រូវយ៉ាងហ្នឹងណា ! "

-" អូខេ ! " កញ្ញា វ៉ាដា ងក់ក្បាលតបវិញ ។

-" ហ៎, ដល់វេនអាមាយបាញ់ហើយ ! " លោកគ្រូម្នាក់បន្លឺឡើង ។

www.elibraryofcambodia.org

ឡៀប-វណ្ណដារ៉ា ផ្ទាប់ស្វាយកាំភ្លើងនៅនឹងស្មា លុតជង្គង់យ៉ាងមាំទាំតម្រង់កាណុង ( Canon ) ទៅលើវង់បាញ់ ( Cible ) រួចសម្រួលជង្គើមគាស់កៃជាំង !... ឥតស្ទុតបន្តិចឡើយ ។

លោកគ្រូអ្នកពិនិត្យវង់បាញ់ស្រែកឡើង ៖

-" អស្ចារ្យ ! ចំជាត្រង់មែន !.... Alors, Ving Sept !, ។ ល្បឿង-ក៉ុំផា ស្ទុះមកទះខ្នងមិត្តនារីគេផាច់ ឌូទាន ៖

-" គ្រាន់បើរ៉ី ! ខ្ញុំបាញ់ត្រង់ជាងគ្នាទៅទៀត ! "

ឡៀប-វណ្ណដារ៉ា ញញឹមតប ៖

-" យេស្ស ! ខ្មោចឲ្យដៃទេតើ !"

បន្ទាប់នោះ, លោកគ្រូបង្ហាត់ស្រែកពីនាយមក ៖

-" ហាំ ! គ្រាប់ទីពីរ ! "

កញ្ញា ក៉ុំផា យកកាំភ្លើងរុញគូចមិត្ត ៖

-" នៅពីរគ្រាប់ទៀត ! "

បុត្រីនៃលោក ឡៀប-ស៊ុម ផ្តងកាំភ្លើងសាជាថ្មី រួចស្មូរ ផាំង !...

-" Ving Sept, 2 fois ! " លោកគ្រូបង្ហាត់ស្រែកទាំងលើកដៃ ។

-" មួយគ្រាប់ទៀត, ចុងបង្អើយ ! " ល្បឿង-ក៉ុំផា បន្ទឺ ។

-" Ancore 27 ! " លោកគ្រូអ្នកឲ្យពិន្ទុស្រែកទាំងស្ទុះមកទះស្មានាង ឡៀប-វណ្ណដារ៉ា ។ " អាមាយ ឯងចំជាបាញ់ត្រង់លេខមួយ ! "

នាងដាក់មុខចុះ ៖

-" លោកគ្រូសរសើរខ្ញុំហួសចន្លោល, តាមពិត មាយត្រូវខ្មោចនាំដៃទេតើ !"

លោកគ្រូនិងមិត្តកក្តិឯទៀតនាំគ្នាសើចកក្អៀក ។ កញ្ញា ផា-សាវ៉េតបន្ទរឡើង ៖

-" ហេតុតែកូនគេបម្រុងផុះ លើថ្មចាក់ទឹកអាស៊ីដក៏ផុះដែររ៉ី ! "

លោកគ្រូងាកទៅត"រកម្ចាស់សម្លេង ៖

-" អាវ៉េតឯងក៏គ្មានទៅខ្មះអីទេ, បាញ់ក៏មិនកើត រវល់តែញ៉េរញ៉ៃ ហើយកុមបាក៏មិនកើតទៀត ! "

ល្បឿង-ក៉ុំផា ចំអន់ថែម ៖

-" បើគ្រាប់វិញ ឲ្យស្អិបៗ ដូចកន្ត្អប់ខេច្រាំងអ៊ីចឹង ! "

www.elibraryofcambodia.org

សម្តីនេះធ្វើឲ្យអ្នកទាំងអស់សើចលាន់ឡើង ។ កញ្ញាត្រូវគេចំអន់ ញាក់បបូរមាត់បន្តិ៍ ៖

-" អើ, ព្រោះតែគ្នាមិនមែនជាទាហានណាំ ! "

កំពុងជជែកគ្នា, ស្រាប់សាម្លេងមួយបន្លឺមកពីខាងឆ្ងាំងៗ ៖

-" នែ៎, វ៉ីយ ! ពួកឯងនាំគ្នាសម្រាកសិនទៅ ! "

ឡៀប-វណ្ណដាក់ ក្រឡេកឃើញម្ចាស់សម្លេង ក៏នាងទាំងត្រវៃដៃឡេង ៖

-" ប៉ា ប៉ា ប៉ាក៉ ! "

រូបនាងតែសំដៅប៉ុរសនោះ ។ លោក គិម-ឡេា ញញឹមលីកាំភ្លើងកាក់ប៊ីនដើរមកបន្ទីសួរ ៖

-" យ៉ាងម៉េចហើយ, អ្ហ៎ ! អាមាយកូនស្រីប៉ាប៉ា ?"

ឡៀប-វណ្ណដាក់ ទៅជិតលោកសក្តិបីឈរត្រង់ខ្លួន ដាក់អាវុធចុះមាជើង ហើយលាស់សម្លេងយ៉ាងរួសរាយ ៖

= « 27 trois fois, Papa ! 27 trois fois ! »

លោកសក្តិបី គិម-ឡេា ពុជ្ជច្រោះ ត្រេកអរយ៉ាងលើសលប់ ឧទានទាំងសោមនស្ស ៖

-" ល្អ, កូនស្រីប៉ាប៉ា ! "

ព្រមទាំងដោះមួកប៉េរ៉ែក្រហមរបស់គាត់បោកព្រួសទៅលើស្មៅ ។ បន្ទាប់មក, គាត់លោស់វាចា ៖

-" កូនស្រីប៉ាប៉ាបាញ់ត្រង់មែន ! "

-" ប៉ាប៉ាបានអីធ្វើកាដូ ហ៎ ? "

-" អូ៎, ប៉ាប៉ាបាំបាយកូនស្រីមួយពេល ! "

-" អរគុណ ! "

នាងញញឹម, លើកកាំភ្លើងលីលើស្មា ហើយនិយាយបន្ត ៖

" ចាំមើលណាំប៉ាប៉ា, ដល់កូនទៅផ្ទះវិញ កូនយកខ្ញើយាធ្វើស៊ីប រៀនបាញ់ជាមួយប្អូនៗ ខ្ញុំហើយ ! រៀនបាញ់ឲ្យត្រង់ដើម្បីសម្ពះក្បាលអាយៀកកុងឲ្យស្គាល់ដៃតែម្តង ! "

លោកសក្តិបីដូចជាសប្បាយរីករាយណាស់ ។ គាត់ងាកមករកនាង ឡៀប-វណ្ណដាក់ បន្តិច ហើយនាំគ្នាដើរទៅរកអ្នកឯទៀតដែលកំពុងរៀនបាញ់ ។

-" ពួកយើងសម្រាកបន្តិចសិនទៅណ៎ា ! " លោកប្រាប់អ្នកទាំងនោះ រួចហួសទៅធ្វើការផ្សេងៗ ទៀត ។

ពេលសម្រាកនៅក្រោមម្លប់ឈើក្បែរប្រាសាទក្រហំ, មិត្តសិស្សនារីជាច្រើននាក់ អង្គុយជុំវិញនាង ឡៀប-វណ្ណដាក់ ស្ដាប់នាងនិយាយលេងសើចចំហរមាត់ ។ នាងជាមនុស្សរួសរាយណាស់ ហើយបានរហ័សរហួនទៀតផង, យ៉ាងនេះហើយទើបបានជាគេតែងឃើញពេលណាទំនេរ ឬសម្រាកពីហាត់រៀន, នាងនាំមិត្តភក្ដិនិយាយលេងឲ្យសើចសប្បាយបំភ្លេចនូវសេចក្ដីនឿយហត់ទាំងឡាយ ។ លក្ខណៈនេះ ជាហេតុធ្វើឲ្យមិត្តទាំងអស់ចូលចិត្តនាងណាស់ ។

ក្រៅពីនេះ, នាងស្គាល់អធ្យាស្រ័យមិត្តភក្ដិ ជាពិសេសដូចជាកាលពីមុន, នៅពេលដែលពួកកងកុម្ម៉ង់ដូចែកជាកង, គេត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តដើម្បីកាន់តំណែងជាមេបញ្ជាការ ។ ចំណោមកងកុម្ម៉ង់ដូទាំងអស់, គ្មាននរណាម្នាក់លើកដៃទេ ។ នាង ឡៀប-វណ្ណដាក់ ក្រឡេកទៅគ្មានឃើញនរណាលើកដៃ ក៏យកខ្លួនរ៉ាប់រងនូវបន្ទុកដ៏ធ្ងន់នេះ ។ ម្យ៉ាងទៀត, មិត្តភក្ដិឯទៀតចេះតែជម្រុញនាងផង ព្រោះដោយសាររូបរាងនាងមាំទាំ, ខ្ពស់ស្រឡះ, ត្រូវនឹងឯកសណ្ឋានកុម្ម៉ង់ដូទៅទៀត, មានឧនាងសាម៉ៀមអស្ចារ្យ សមសក្ដិជាអ្នកក្លាហានមុះមុតមែន ។ ក៏ព្រោះតែមានឧនិងសាម្លេងហ្មត់ចត់របស់នាង, ក្នុងកងរបស់នាងក៏មានរបៀបរៀបរយ ប្រកាន់វិន័យថ្លៃថ្នូរបំផុត ដែលនរណាក៏កោតសរសើរដែរ ។ នេះគឺជាកិត្តិយសមួយ ។

លោក គិម-ឡេា ជាគ្រូបង្ហាត់បង្រៀនផ្ទាល់តែងសរសើរនាងរឿយៗ ប្រាប់មិត្តភក្ដិនិងគ្រូឯទៀត នូវសន្ដានចិត្តតស៊ូក្លាហាននិងការយកចិត្តទុកដាក់របស់នាង ។ ម៉្លោះហើយ, មជ្ឈដ្ឋានគ្រូក៏ចូលចិត្តនាង ព្រោះនាងក៏រួសរាយជាមួយគ្រូដែរ ។

ដំណើរការណ៍នេះក៏ឮដល់ឪពុកម្ដាយ ។ លោក ឡៀប-ស៊ុម និងអ្នកស្រី ប៊ិន-ប៊ូប៉េឡាំងញញឹមបិទមាត់មិនជិត ព្រោះតែគាត់មានកិត្តិយសខ្ពង់ខ្ពស់ប្រពៃមួយ ដែលលោកបានទទួលពីបុត្រីសម្លាញ់ចិត្ត ។ ម្ដាយឪពុកគ្មានអ្វីធ្វើឲ្យសប្បាយចិត្តជាងឃើញកូនល្បុះដោយគុណធម៌នោះទេ ។

កូនបំពេញមុខឪពុកម្ដាយ, កេរ្តិ៍ឈ្មោះលោកក៏ក្រអូបក្នុងសង្គមមនុស្ស មាននាមជាអ្នកចេះអប់រំកូនបានប្រពៃដែរៗ ម៉្លោះហើយ, លោកប្រុសនិងលោកស្រីញញឹមរីករាយត្រេកអរកណ្ដាលចំណោមមិត្តខ្ទះរិះគន់គាត់ ដែលបណ្ដោយឲ្យកូនចូលធ្វើកុម្ម៉ង់ដូនេះ ។

www.elibraryofcambodia.org

មតិរិះគន់នោះ តែងលេចឡើងពីពួកចិនលក់ទំនិញមួយ ប៉ែកផ្សារដែលស្គាល់គាត់ជិតដិតខ្វះដោយចាក់រុកបញ្ចុះបញ្ចូលអីចេះអីចុះ ។ ប៉ុន្តែ, ទោះបីមានមតិទាំងចង់បំបែកបំបាក់យ៉ាងនេះក៏ដោយ គាត់មិនយកត្រចៀកស្ដាប់ឡើយ ថែមទាំងស្ដីឲ្យវិញផង ។

នាង ឡៀប-វណ្ណដារ៉ា តែងពោលប្រាប់ម្ដាយរឿយៗ ៖

-" ម៉ាក់ ! មាយស្អប់កំពូជអាយួនស្អីគេហ្នឹងដល់ហើយ វាទើសអីបានជាពួកវាមកប្លន់ទឹកដីខ្មែរយើងអីចឹង ? បើជាតិនេះកូនមានវាសនា, មាយសម្លាប់អាយួនឲ្យស្គាល់ដៃម្ដង ! "

អ្នកស្រីជាម្ដាយសើចញញឹមៗ ពេញចិត្តឲ្យកូននិយាយបែបនេះណាស់, ពីរោះណាស់ ។

ចំណុចមួយផ្នែកទៀតដែលគាត់បានកត់សម្គាល់ គឺចាប់តាំងពីនាងហាត់កុម្មុំងផូមក, នាង ឡៀប-វណ្ណដារ៉ា ស្រាប់តែមានការសប្បាយប្លែកហួសពីទម្លាប់របស់នាង ។ ជាពិសេស, នាងនិយាយប៉ប៉ាច់ប៉ប៉ោចជាមួយម្ដាយ បញ្ជាក់ឲ្យដឹងថា ក្នុងចិត្តនាងពិតជាមានចេតនារម្មណ៍អ្វីម្យ៉ាង ដែលបម្រុងនឹងសម្រេច ។ បើតាមការយល់ឃើញច្បាស់ជាចេតនារម្មណ៍ទៅលើគោលការណ៍បម្រើជាតិសាសន៍ទឹកដីនេះឯងហើយ ។ ម្ដាយឪពុក, ធម្មតាកាលបើឃើញកូនសប្បាយប្លែកដូច្នេះហើយនិស្ស័យស្រឡាញ់កូនផង និងជាពិសេសនាងមិនដែលធ្វើអ្វីឲ្យឃ្នើសដល់ពន្លកចិត្ត, ក៏សប្បាយរីករាយជាមួយកូនទៅ ពុំបានចាប់ភ្លឹកនឹកទៅដល់ហេតុការណ៍អ្វី ដែលនឹងកើតមានឡើងដល់កូនឡើយ ។

នៅពេលនាងចេញពីហាត់វិជ្ជាយុទ្ធសាស្ត្រ ត្រឡប់មកដល់ផ្ទះវិញ, នាងតែងនាំរឿងកំប្លុកកំប្លែងផ្សេងៗ ដែលនាងបានជួបនៅពេលហាត់នោះជម្រាបឪពុកម្ដាយ ធ្វើឲ្យគាត់អស់សំណើចជាមួយ ។

ជួនកាល, នាងនិយាយសរសើរពីសន្ដានចិត្តលោកសក្តិបី គិម-ឡោ ជម្រាបមាតាបិតា ៖

-" អ្ហ៎ , ម៉ាក់ ប៉ា ! ប៉ាប៉ាប៉ាក៏ខ្ញុំស្រឡាញ់រាប់អានកូននិងពួកកូនណាស់ ។ គាត់មានប្រសាសន៍ថា កូនកាន់កាំភ្លើងសមសឹងអី! ហ្អ៎ ! ថ្ងៃមុន, គាត់ជប់លៀងពួកកូនហើយប្រកាសថា ដើម្បីជាជោគជ័យនៃយើង ! "

លោកប្រុស-លោកស្រីញញឹមខ្ទិប ។

www.elibraryofcambodia.org

លោក គិម-ឡេ មានហំឡូនសេក្តិជាអនុសេនីយឯក, បណ្ដាសក្តិរបស់គាត់ឡើងដោយរបស់កម្មរបស់គាត់ មិនមែនបានដោយប្រការអ្វីឡើយ ។ ដើម្បីគាត់ជាកូនទាហានធម្មតា ។ កាលពីជំនាន់អាណានិគមបារាំង, គាត់ត្រូវគេបញ្ជូនឲ្យទៅធ្វើសង្គ្រាមនៅឡៀនបៀនកូ ។ នៅទីនោះ, គាត់បានវាយសក្តិមួយយួនពីរដៃបាក់ថ្គាមហើយបាក់ច្រមុះ ។ អាយួនសក្តិមួយនោះអុកក្តិតធ្វើមាត់ស្មេញ មិនហ៊ានទីងគាត់វិញឡើយ ព្រោះវាកង់សំគមដូចកន្ទ្រើបខ្ទេចក្រាំង រីឯលោក គិម-ឡេ ឯណោះវិញមាឌដូចដីសារ ។ ដោយសារតែវាត់យួនអស់ថ្គាមយ៉ាងហ្នឹង ទើបបានជាគាត់ត្រូវពួកបារាំងចម្លតចាប់គាត់បញ្ចូលគុកអស់បីអាទិត្យ ហើយត្រូវលីស្បោងសាក់កាដូ ( Sac-à-dos ) ច្រកឡាច់រត់ជុំវិញបន្ទាយមួយជុំរាល់ព្រឹក ។

ក្រោយមក, គាត់ត្រូវគេបញ្ជូនឲ្យទៅកាន់សមរភូមិញ៉ីកញាប់ជាងគេ ព្រោះគាត់មិនសូវគោរពបារាំងច្រមុះស្រួច ។ ហេតុតែជីវិតគាត់ថ្លៃ, វាសនារបស់គាត់បានជម្រុញឲ្យឡើងសក្តិញ៉ីកញាប់ ។ គ្រប់តែសមរភូមិរបស់គាត់, តែងតែទទួលនូវជ័យជំនះ ជាហេតុធ្វើឲ្យបារាំងស្រឡាញ់រាប់អានគាត់វិញ ។

លុះដល់ស្រុកខ្មែររួចពីនឹមដែករបស់អាណានិគមបារាំងសែសមក, លោកក៏ត្រឡប់មកកាន់មាតុប្រទេស ហើយបានត្រូវរាជការក្នុងសម័យនោះ ឲ្យចូលរៀននៅបណ្ឌិតសភាភូមិន្ទយោធា ដើម្បីឡើងកាន់ជានាយទាហានសកម្មតែម្ដង ។

ចំណោមមកទៀត, ជីវិតទាហានអង់អាចនេះធ្វើឲ្យគាត់មុខគ្រាប់កាំភ្លើងច្រើនសារក៏ឡើងសក្តិជាបន្តៗ រហូតដល់សក្តិបីក្រឡៅតែម្ដង ។ គួរឲ្យសរសើរគាត់ដែរ ! ។

ឥឡូវគាត់ត្រូវរដ្ឋការខ្មែរបញ្ជូនឲ្យមកបង្ហាត់បង្ហាញវិជ្ជាយុទ្ធសាស្ត្រដល់សិស្សកុម្មង់ដូនៃវិទ្យាល័យសៀមរាបទៀត ។

ការហាត់រៀននេះ ចាប់ធ្វើដំបូងឡើងពីវិន័យ, វិន័យយោធានិងវិន័យស៊ីវិលៗ បន្ទាប់តទៅ គឺពីការប្រយុទ្ធប្រឆាំងសង្គ្រាមព្រៃ, ពីរបៀបការពារក្នុងករណីខ្មាំងចូលមកវាយលុក, ពីរបៀបបាញ់, ពីរបៀបវាយលុក (combat)... មិនតែប៉ុណ្ណោះ, គាត់បានអប់រំយុវជនឲ្យស្គាល់ច្បាស់ នូវគោលបំណងរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិ ហើយពីស្មារតីមុតមាំក្នុងកិច្ចកំចាត់ខ្មាំងយួនវៀតកុង ឲ្យប្រាសពីដែនដីយើង ។ រួមផ្សំជាមួយចិត្តគំនិតរបស់គាត់មិនប្រកាន់ខ្លួនផង, សិស្សកុម្មង់ដូប្រុសស្រីទាំងអស់ស្រឡាញ់រាប់អានគាត់ទុកដូចជាឪពុកបង្កើតដូច្នោះ ។

********

www.elibraryofcambodia.org

... ថ្ងៃត្រង់ជាក់ ក្ដៅស្ទើរឆេះប្រថពី ។

សិស្សកុម្ម៉ង់ដូចាំងអស់ ចេញពីហាត់ហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រ ខ្លះជិះកង់, ខ្លះជិះម៉ូតូ, ខ្លះផ្ទុះទៅជិតរៀងអាយក៏ដើរទៅកាន់លំនៅ ។

នាង ឡៀប-វណ្ណដារ៉ា ទើបបែកមិត្រភក្តិស្និទ្ធស្នាលគ្នាបីនាក់ទៀត មានកញ្ញា លឿង-កុំផា, កញ្ញា លឿង-ផល្លីន, និងកញ្ញា ជា-សារ៉េត សុទ្ធសឹងជាកល្យាណមិត្តស្រឡាញ់គ្នាចាក់ទឹកមិនលិច ។ មិត្តទាំងបួននេះនៅក្នុងកងជាមួយគ្នា ។ ជិតជិះកង់ទៅផ្ទះវិញម្នាក់ឯង។ នៅពេលនោះ, តាមផ្លូវដូចជាស្ងាត់បន្តិចទៅហើយព្រោះបណ្ដាសិស្សទាំងឡាយទៅផ្ទះមុនជាស្រេចអស់ នៅសល់នាង វណ្ណដារ៉ា និងមិត្តពីរបីនាក់ទៀត សំណេះសំណាលជាមួយគ្រូខ្លះៗ ពីសភាពការណ៍ដែលខ្មាំងយៀកកុងឈ្លានពានប្រទេសជាតិយើង ។ ដូច្នេះហើយបានជានាងនៅក្រោយគេ ។

ប្រមាណជាម៉ោងជិតដប់ពីរ ។ ផ្ទៃមេឃប្រាសចាកពពកជាហេតុបាននឹកាសឲ្យព្រះអាទិត្យមេកម្ដៅ បើកឥទ្ធិពលយ៉ាងខ្លាំងក្លា ។ ឡៀប-វណ្ណដារ៉ា ទំពាក់ទោចក្រយានយ៉ាងលឿនដើម្បីឲ្យបានឆាប់ដល់ផ្ទះ ព្រោះនាងឃ្លានបាយផង ។ នាងទំពាក់កង់ឡើងបែកញើសជោមតាមអាវកាគី ហើយនៅលើផ្ទៃមុខដ៏កំប្លុងៗ ដុំញើសដូចគ្រាប់ពេជ្រហូរកាត់តាមផែនថ្ពាល់បាក់បីដូចជាផ្លូតទឹក ។

នាងទំពាក់កង់ហ្វូតទៅដល់ផ្លូវបំបែកក្បាលស្ពានសៀមរាប ស្រាប់តែលាន់ស្នូរប៉ាំង ! ប្រូស !... នារីភ្ញាក់ក្រញាង, ងាកទៅឃើញនារីម្នាក់ដួលស្រប៉ាប់ៗ ក្បែរចិញ្ចើមថ្នល់ ។ វិការភាពនេះកើតឡើងដោយមានរថយន្តមួយ បើកមកកៀរស្រីម្នាក់ជិះកង់បណ្ដាលឲ្យដួលច្រង៉ាប់ច្រងិល កំពប់ទាំងចានស្រាក់ដាក់សម្លហូរហោចហើមពេញទាំងថ្នល់ ។ រូបអ្នកបើករថយន្តដ៏អសប្បុរស ដាក់លេខបន្ថែមល្បឿនទៅមុខទៀត ឥតទាំងខ្វីងាកមើលស្រីអភ័ព្វឡើយ ។ មិនតែប៉ុណ្ណោះ, ពួកអ្នកជិះទាំងអម្បាលមាណថែមទាំងសើចក្អាកក្អាយចំអកឲ្យទៀត ដោយយកសភាពដ៏សែនវេទនារបស់អ្នកជិះកង់ជាគាកកំប្លែងសម្រាប់ពួកខ្លួនកំសាន្ត ។

នាង ឡៀប-វណ្ណដារ៉ា ឃើញដូច្នោះ បញ្ឈប់ជំនិះផ្អែកនឹងចិញ្ចើមថ្នល់, ស្ទុះទៅត្រកងនារីរងគ្រោះនោះដៃ ។ ស្រីអភ័ព្វសន្លប់បាត់មាត់ឈឹងសល់តែដង្ហើមផ្អិតៗ ។ នាងបែកក្បាលហូរឈាមកក្លាក់ ហើយជើងខ្នងក៏មានកកឈាមឡើងខ្លាំងត្រង់កំភួន ។

www.elibraryofcambodia.org

ឡៀប-វណ្ណដារ៉ា ក៏ឃើញរស្មៅខ្លួន កាលបើឃើញស្រីរងគ្រោះមានសភាពដុនដាប យ៉ាងខ្លាំង ។ តាមពិត, នាងត្រូវបាក់ជើងទ្វេងផង ។

ខណៈកំពុងមានអាសន្ន, ទឹកភ្លេងសៀមរាបហាក់ដូចជាស្ងប់ស្ងាត់បន្តិច ពុំសូវមានមនុស្សម្នាធ្វើគមនាគមនាការទេ ។ ប៉ុន្តែនៅតាមផ្លូវមានមនុស្សដើរពីរបីនាក់ដែរ ។ ដល់ឃើញមានហេតុការណ៍ផ្ទុះឡើងដូច្នេះ គេនាំគ្នាស្ទុះមកចោមរោមអ៊ូអែរ, ខ្លះទៀតសួរ ៖

-" នាងយ៉ាងម៉េចហើយអីចេះ ? "

ឡៀប-វណ្ណដារ៉ា ឆ្លើយជម្រាបអ្នកទាំងនោះទាំងកិតក័យ ៖

-" នាងត្រូវរបួសធ្ងន់ណាស់! មិនដឹងជាយ៉ាងម៉េចទេ, នាងឥតដឹងខ្លួនបន្តិចទេ!"

អ្នកខ្លះឲ្យយោបល់ ៖

-" ប្រញាប់ដឹកនាងទៅពេទ្យទៅ ! "

រីឯអ្នកខ្លះទៀតក៏ជួយឈឺក្បាលស្រីរងគ្រោះដែរ ហើយដល់ដឹងថាហេតុការណ៍កើតឡើងដោយពួកជនចោកចាបមួយក្រុម ក៏ស្រែកជេរប្រទេចផ្តាសាយ៉ាងច្រើន ។ នាង ឡៀប-វណ្ណដារ៉ា ក៏ស្រែកហៅរ៉ឺម៉ក ដែលពូរ៉ឺម៉កឈប់ឈរមើលហេតុកេទនេះដែរ ឲ្យជួយលើកអ្នករបួសទៅមន្ទីរពេទ្យ ។

ពេលនោះ, អ្នកជិតខាងផ្ទះនាងម្នាក់បានមកឃើញនាង ឡៀប-វណ្ណដារ៉ា សែនមនុស្សរងគ្រោះ ក៏ជ្រែកគេឯងចូលទៅសួរ ៖

-" យ៉ាងម៉េចហ្នឹងមាយ ? "

នាងតបមកវិញទាំងផ្តាំថា ៖

-" អើ, ស្រួលហើយ ! គីម, គីមឯងមកពីណាហ្នឹង? ឯងទៅផ្ទះប្រាប់ម៉ាក់ខ្ញុំផង ថាខ្ញុំជូនមិត្តនារីនេះទៅពេទ្យណា៎ ហើយនិងឯងយកកង់ខ្ញុំទៅផ្ទះផង ! "

នាងគីមងក់ក្បាលយល់ព្រម ៖

-" អើ ! មិនអីទេ ! "

លំដាប់មក, ពូរ៉ឺម៉កក៏ដាក់យានដឹកអ្នកជំងឺទៅកាន់មន្ទីរពេទ្យជាបន្ទាន់ ។ នាងចេញលុយឲ្យថ្លៃរ៉ឺម៉ក រួចសែងស្រីកំសត់ជាមួយបុគ្គលិកពេទ្យ ចូលទៅក្នុងបន្ទប់ព្យាបាល ។ ជាសំណាងល្អដែរ, លោកវេជ្ជបណ្ឌិតរៀបចំប្រដាប់ប្រដាប្រុងចេញទៅផ្ទះហើយ ជួនប្រទះឃើញមានអ្នករបួសមកដល់ ក៏ជួយខ្នះខ្នែងឡើង ។

នាង ឡៀប-វណ្ណដារ៉ា បាននិយាយអង្វរលោកវេជ្ជបណ្ឌិតដោយសម្តីទន់ភ្លន់ ដើម្បីឲ្យលោកគ្រូពេទ្យជួយព្យាបាលស្រីអភ័ព្វ ៖

www.elibraryofcambodia.org

-" សូមលោកគ្រូពេទ្យ មេត្តាជួយព្យាបាលប្ដីរបស់នាងផង់ទៅ, មិនដឹងជានាងយ៉ាងណាទៅហើយទេ ! "

លោកវេជ្ជបណ្ឌិតជាមនុស្សមានចិត្តល្អ យល់ទុក្ខធុរៈអ្នកផងណាស់ ងក់ក្បាលទាំងស្រាកយកបមកនាងវិញ ៖

-" អូ! សូមនាងកុំព្រួយ ! នេះជាការៈខ្ញុំហើយ, ខ្ញុំមិនមែនដូចអស់លោកខ្លះទេ!......."

វេលានោះ, លោកប្រើបុគ្គលិកពេទ្យឲ្យសែងអ្នករបួសចូលទៅក្នុងបន្ទប់ពិសេស ហើយលោកចាត់ចែងព្យាបាលនាងដោយប្រញាប់ ។

ប្រមាណជាមួយម៉ោងក្រោយមក, លោកវេជ្ជបណ្ឌិតចេញពីបន្ទប់ព្យាបាលវិញ ហើយរៀបចំឡើងរថយន្តទៅលំនៅ ។ នាង ឡៀប-វណ្ណដាក់ ទ្រាំរង់ចាំស្ដាប់ដំណឹងអ្នករងគ្រោះទាំងភ្លេចឃ្លានបាយ ។ គ្រាន់តែឃើញលោកវេជ្ជបណ្ឌិតចេញមកភ្លាម, នាងស្ទុះទៅសាកសួរដោយក្ដីបារម្ភ ៖

-" សូមទោសលោកគ្រូ, អ្នករបួសយ៉ាងម៉េចហើយ ? "

លោកវេជ្ជបណ្ឌិតញញឹមតាមនិស្ស័យល្អរបស់គាត់ មុននឹងតប ៖

-" នាតត្រូវរបួសធ្ងន់ណាស់ ! ជាពិសេស ឆ្អឹងជើងរបស់នាងត្រូវបាក់ខ្ទេច, កំប៉ុន្តែអាចព្យាបាលបាន តែត្រូវដេកពេទ្យអស់រយៈពេលយ៉ាងយូរទើបជា ! "

-" បើអ៊ីចឹង, នាងអត់អីទេ ? "

-" បាទ ! នាងអាចរស់វិញបាន កំប៉ុន្តែត្រូវចាក់ស៊ីរ៉ូមបញ្ចូល ព្រោះឈាមហូរចេញពីខ្លួននាងច្រើនពេក ! "

ក្រោយមក, លោកវេជ្ជបណ្ឌិតក៏បញ្ចេះដំនិះចេញទៅ ។

ចំណែកអ្នកជំងឺក៏ត្រូវគេយកទៅដាក់ក្នុងបន្ទប់មួយផ្សេងទៀត ដើម្បីព្យាបាល។ នាង ឡៀប-វណ្ណដាក់ សុខចិត្តទ្រាំរង់ចាំអ្នករងគ្រោះទាំងមួលពោះឃ្លានអាហារ ។

លោកគ្រូពេទ្យប្រចាំការបានប្រាប់ថា អ្នករបួសបានដឹងខ្លួនហើយ តែត្រូវឲ្យនាងសម្រាកបន្តិច ព្រោះពេលដែលនាងដួលនោះ ក្បាលនាងត្រូវបោកទៅលើដីបណ្ដាលឲ្យបែកចេញឈាម ។ សំណាងល្អដែរ ដែលមិនមានប៉ះចំគ្រឿងសំខាន់នៅក្បាល ។

* ***** *

www.elibraryofcambodia.org

## វគ្គទីបួន

# ថ្ងៃបែកគ្នានៃគ្រូនិងសិស្ស

ប្រមាណម៉ោងជាង ១៤ ។

អ្នកជំងឺប្រែខ្លួនដកដង្ហើមធំទាំងថ្ងូរហើមៗ នាងប្រែខ្លួនទាំងឈឺចុកចាប់។ ឃើញដូច្នោះ, ឡៀប-វណ្ណដារ៉ា ទៅអង្គុយជិតជួយលើកអ្នករងគ្រោះឲ្យគេងតាមសម្រួល ។

-" សម្ងំគេងទៅមិត្ត ! សម្ងំគេងទៅ, កុំប្រឹងប្រែខ្លួនធ្វើអ្វី ! " នាង វណ្ណដារ៉ា ពោល ។

អ្នកជំងឺពុំវាចាស្រួយស្រិប ប្រកបដោយមធុរសផ្អែមពិសារ ក៏ព្យាយាមបើកនេត្រាសន្សឹមៗ ឡើង មើលមុខម្ចាស់សម្លេង ។ នាងឃើញស្រីជំទាវយ៉ាក្មេង រូបស្រស់ត្រដូចត្រដឹមបីដូចបុប្ផ។ គេនិយមហៅថា«បុប្ផអង្គរ» រាយសម្រស់ផ្កាញញឹម, ជាផ្កាញញឹមដក់ដោយសេចក្ដីអាណិតអាសូរ ។ នាងអង្គុយសុភាពរាបទាបក្បែរខ្លួន បង្ហាញទឹកមុខហាក់ដូចជាជួយរំលែកនូវសេចក្ដីឈឺចាប់របស់អ្នកជំងឺ ។

ស្ត្រីរងគ្រោះស្ថិតក្នុងតរុណវ័យ, មានសម្រស់កាយមិនជាចាញ់កញ្ញា ឡៀប-វណ្ណដារ៉ា របស់យើងប៉ុន្មានទេ ។ ប៉ុន្តែសក់នាងកាត់ខ្លីត្រឹមស្មា ជាការផ្ទុយនឹងសក់របស់បុត្រីលោក ឡៀប-ស៊ីម ដែលវែងអន្លាយប៉ប្រះចង្កេះ ។ ពេលនាងឃើញនារីអង្គុយជិតក្លាម ហាក់ដូចជាមានចិត្តារម្មណ៍ម្យ៉ាងចង់ស្គាល់នាង ហើយរៀបនឹងបើបមាត់សួរ, ស្ត្រីនោះដឹងអធ្យាស្រ័យមុន ក៏ឆ្លើយបំពេញបំណងជាស្រេច ៖

-" ចាំ, ខ្ញុំឈ្មោះ ឡៀប-វណ្ណដារ៉ា ហៅ មាឃ ! "

អ្នករងគ្រោះញញឹមងក់ក្បាល សួរ ៖

-" ជាអ្នកជួយនាំខ្ញុំមកមន្ទីរពេទ្យមែនទេ ?"

-" នៅពេលមិត្តត្រូវឡានកៀរឲ្យដួលទៅលើថ្មតំរៀមថ្នល់ " វណ្ណដារ៉ាផ្ដើមប្រាប់ហេតុពិត, "ខ្ញុំក៏ដឹកមិត្តមកមន្ទីរពេទ្យដើម្បីព្យាបាល... មិត្តមានរបួសធ្ងន់ណាស់ធ្វើឲ្យខ្ញុំភ័យបារម្ភយ៉ាងខ្លាំង ។ ពេលលោកវេជ្ជបណ្ឌិតប្រាប់ខ្ញុំថា មិត្តមិនមានត្រូវ

www.elibraryofcambodia.org

ទម្ងន់ក្នុងខ្លួន, ខ្ញុំសែនត្រេកអរជាអនេកហើយក៏បានធូរអារម្មណ៍បន្តិចវិញ ។ ប៉ុន្តែនៅពេលខ្ញុំដឹងថាមិត្រត្រូវគេឯងនៅពេទ្យយ៉ាងយូរ ខ្ញុំហាក់ដូចជាអផ្សុកជំនួស ! "

–" អរគុណណាស់ ! អរគុណណាស់ ! " អ្នកប្រុសបន្លឺទាំងញញឹម, "ខ្ញុំបារម្ភក្រែងតែខ្ញុំតបស្នងសងគុណមិត្តវិញមិនសមសួនទេ !"

ឡៀប–វណ្ណដារ៉ា កាត់ជាបន្ទាន់ ៖

–" ទេ! ទេ! មិត្រមិនត្រូវគិតឲ្យវែងឆ្ងាយដល់ថ្នាក់ហ្នឹងទេ, ធម្មតាមនុស្សយើងកើតមកត្រូវចេះជួយទុក្ខធុរៈគ្នាយ៉ាងហ្នឹងឯងហើយ ។ម្យ៉ាងទៀត, កិត្តិយសគឺស្ថិតនៅត្រង់ចិត្តស្មោះនឹងគ្នាតែប៉ុណ្ណោះ ។ គឺក្នុងន័យនេះឯងហើយដែលខ្ញុំត្រូវការពីមិត្ត, មិនមែនគុណូបការៈអ្វីផ្សេងទេ ដែលជាន័យក្នុងការរាប់អានគ្នានោះ ! "

ពួសម្តីរបស់មិត្រជនឧត្តមនេះ, ស្រីរងគ្រោះសែនរំជួលក្នុងចិន្តាដោយបីតិពុះកញ្ជ្រោល ។ នាងរកនឹកពាក្យអ្វីថ្លែងរៀបរាប់ទៅម្ចាស់ប្រយោគវិញគ្មាន ដើម្បីឲ្យសមនឹងគុណបំណាច់ដែលគេទំជួយសង្គ្រោះខ្លួន និងសេចក្តីស្មោះត្រង់ក្នុងផ្លូវមិត្តភាពនេះក្រៅពីថ្លែងយ៉ាងនឹង ៖

–" អរគុណមិត្តណាស់ ! គឺជាហេតុការណ៍មួយដែលខ្ញុំមិនអាចបំភ្លេចបានទេ !"

នារីពោលតែប៉ុណ្ណោះ ហើយក៏បង្អង់ទៅវិញ ព្រោះអាការៈប្រុសហាក់ដូចជាចាប់ខ្មាសឡើង បណ្តាលឲ្យនាងទំតាំងស្មារតីដើម្បីទប់ទល់យ៉ាងសែនលំបាក ។

យល់សភាពការណ៍ដូច្នេះ នាង ឡៀប–វណ្ណដារ៉ា ក៏បន្ទឺសំនៀងសម្តីព្រមទាំងយកដៃលើកកួយគ្រប់ទៅលើអ្នកប្រុស ៖

–" គេងទៅមិត្ត ! គេងទៅកុំនិយាយច្រើនពេកពេលវេលានៅច្រើនណាស់សំរាប់យើង, ចាំដល់មុខរបួសបានស្រាកស្រាយយើងនិយាយគ្នាឲ្យបានច្រើន ! "

អ្នករងគ្រោះ, ថ្វីត្បិតតែគានតឹងដោយអាការៈចុកចាប់ក្នុងខ្លួនយ៉ាងណាក៏ដោយ, ក៏ហាក់បានធូរស្រាលឡើងវិញ ព្រមទាំងព្យាយាមកម្រើកបបូរមាត់ពិណស្វាយពោលតប ៖

–" មិនអីទេមិត្ត, ខ្ញុំហាក់បានស្រាកស្រាន្តខ្លះ... "

នាងដកដង្ហើមមួយយ៉ាងវែងដើម្បីរម្ងាប់សេចក្តីចុកចាប់, "អូ៎, ខ្ញុំភ្លេចជម្រាបមិត្តថាខ្ញុំឈ្មោះអ្វី...."

នាងនិយាយទាំងបែរមកមើលមុខមិត្តនារី ៖

–" ចា៎ះ, ខ្ញុំឈ្មោះវិទ្ធ–យុទ្ធារី ..."

www.elibraryofcambodia.org

នាង ឡៀប-វណ្ណដារ៉ា ញញឹមទទួលនូវការនេះទុសនាម ៖

-" អរគុណ, ខ្ញុំសុំស្គាល់មិត្តរហូតណា៎ ! "

-" ចាំ៎ៈ, ខ្ញុំសូមជម្រាបមិត្តតាមត្រង់ទៅចុះ " អ្នកនាងគ្រោះនិយាយទាំងអារម្មណ៍រៃរវល់, "ខ្ញុំបានកៀសខ្លួនពីរឿងចំបែងដួងចិត្តមួយមករស់នៅក្នុងខេត្តសៀមរាបនេះៗ ម្តាយខ្ញុំចាស់ជរាណាស់, គាត់ជាស្ត្រីកំសត់ពិការភ្នែក..."

តរុណីពោលតែប៉ុណ្ណោះ  ក៏បែរមកមើលមុខមិត្តនារីនាងម្តងទៀតដោយការរង្កៀស ៖

-" មិត្តមិនធុញទ្រាន់ទេឬ ? "

វណ្ណដារ៉ាងក់ក្បាលតបរួសរាន់ ៖

-" ចាំ៎ៈ, ចូលចិត្តស្តាប់រឿងកំសត់របស់មិត្តណាស់ មិនជាការធុញទ្រាន់ទេ ! "

-" មិនរំខានចិត្តទេឬ ? "

នាងមាយគ្រវីក្បាល ៖

-" ចាំ៎ៈ, អត់រំខានទេ...,, នាងបន្ត, "តើមិត្តជាអ្នករកស៊ីចិញ្ចឹមម្តាយជរានោះមែនទេ ? "

-" អ៊ឺ អ៊ឺ ! ខ្ញុំលក់ឥវ៉ាន់កំប៉ិកកំប៉ុកបន្តិចបន្តួចនៅតាមផ្សារបានកម្រៃយ៉ាងស្តួចស្តើងបំផុត ... "

ឡៀប-វណ្ណដារ៉ា ងើបទៅធុងទឹកដោះគោមួយកែវ ព្រមទាំងបន្ទីបណ្តើរ ៖

-" ចាំ៎ៈ, ការពិតមិត្រជាអ្នកដែលគួរឲ្យខ្ញុំចាប់ចិត្តណាស់ ! ខ្ញុំត្រូវតែជួយកំដរមិត្រទាល់តែសះស្បើយ ! "

រួច, នាងលើកកែវទឹកដោះគោមកហុចឲ្យមិត្រនាងគ្រោះ ៖

-" ញ៉ាំទឹកដោះគោបន្តិចទៅដើម្បីឲ្យមានកម្លាំង ! "

-" អរគុណ ! "

នាងយុវ្វនារីទទួលកែវទឹកដោះគោក្រេបអស់ពីរបីក្អឹក ហើយងាកមកនិយាយរកនាង ឡៀប-វណ្ណដារ៉ា ទៀត ៖

-" ប្រុសសម័យឥឡូវទិលៗ ណាស់ ! ពួកគេចូលចិត្តឡួយឆាយដាក់ស្រីៗច្រើន... "

នាងពោលទាំងញញឹមបន្តិច ។ ឡៀប-វណ្ណដារ៉ា ក៏ញញឹមដែរអបស្តុបសម្តីទន់ភ្លន់ ៖

www.elibraryofcambodia.org

-" អ្នកម្ចាស់ឡានទោះដូចជាអត់ធម៌មេត្តាពេក... ពេលដែលធ្វើមិត្តដោយបេតនាឲ្យដួលហើយ គេនាំគ្នាសើចចំអក រួចឥតឈប់មើលអ្នករងគ្រោះឡើយៗ ឃោរឃៅបមែន ! "

អ្នកជំងឺព្យាយាមក្រេបទឹកដោះគោយ៉ាងត្រដាបត្រដួស ទាល់តែអស់មួយកែវ ។ រួចស្រីកំសត់គេងទៅវិញ ទាំងផ្ដោតក្រសែភ្នែកទៅលើពិដាន បង្ហើរអារម្មណ៍ឲ្យចាប់យកនូវហេតុការណ៍អ្វីមួយជារឿងអាថ៌កំបាំងនៃដួងចិត្តរបស់នាង ។

កញ្ញា ឌៀប-វណ្ណដារ៉ា, មិត្តនារីដ៏ឧត្ដម, ងើបទៅលាងកែវទុកដាក់ស្រួលបួល ក៏មកអង្គុយជិតនាងយុទ្ធារី ព្រមទាំងលោសរាំងចាទន់ភ្លន់ ៖

" ខ្ញុំចង់ស្ដាប់រឿងកំសត់របស់មិត្តខ្លះដែរ, បើមិនយល់ទាស់ទេ សូមមិត្តរៀបរាប់ឲ្យខ្ញុំស្ដាប់ផងបានទេ ? "

ស្រីកំសត់ងាកក្រសែភ្នែកយ៉ាងមុតសម្លឹងទៅកក្រូនាង វណ្ណដារ៉ា ជាមិត្តទាំងមុខស្លូតស្លប់ ៖

-" រឿងនេះ កន្លងជាច្រើនខែមកហើយ ។ ខ្ញុំព្យាយាមរម្ងាប់សេចក្ដីឈឺចាប់ទាំងអម្បាលម៉ាណឲ្យជ្រះស្រឡះពីខ្ញុំ ។ មែន! នៅពេលខ្ញុំនិរទេសខ្លួនឆ្ងាយពីគេ រឿងដែលធ្វើឲ្យខ្ញុំខ្លោចដួងចិត្តក៏ហាក់សោយបានច្រើន ។ ខ្ញុំក៏ភ្លេចគេបន្តិចម្ដងៗ ហួតដល់លែងនឹកនារកឈ្មោះគេសោះសូម្បីតែម្ដង ! "

នាងដកដង្ហើមធំរួចបន្ត ៖

-" នៅពេលដែលខ្ញុំដឹងថា ប្រុសដែលក្បត់ចិត្តខ្ញុំនោះហៀបរៀបទៅមានសង្សារថ្មី ខ្ញុំក៏កើតទុក្ខយ៉ាងធំក្នុងខ្លួន ។ មុនដំបូង, ខ្ញុំច្រើគ្រប់មធ្យោបាយ ទោះបីមធ្យោបាយនោះឃោរឃៅយ៉ាងណាក៏ដោយឲ្យតែបានឈ្នះទៅលើចិត្តមាន់របស់ខ្ញុំ..."

តាមរបៀបសម្ដីនេះ, ឌៀប-វណ្ណដារ៉ា ឃើញទឹកមុខរបស់មិត្តនាងកាន់តែស្រពាប់ស្រពោនជាលំដាប់ ។ ក្រោយពីឈប់ដកដង្ហើមធំៗ បានពីរបីសា, យុទ្ធារីប្រាប់រឿងកំសត់បន្តទៅទៀត ៖

-" មិត្តវណ្ណដារ៉ាអើយ, កូនមួយជាអនុស្សាវរីយ៍នៃការទាក់ទងគ្នារវាងមួយឆ្នាំបានធ្វើឲ្យខ្ញុំប្រែឆាយ៉ាងខ្លាំង... ឥឡូវវាមិនទាន់ចេះដើរស្រួលបួលនៅឡើយទេ ទើបតែបានតតិបតតុប... គេគ្មាននឹកនាមកដល់កូនកំសត់សោះ..."

ដល់ត្រង់នោះ, ធីតាហូរទឹកភ្នែកមករហាម ធ្វើឲ្យបរិយាកាសកាន់តែធ្ងន់ពាប់មួយកម្រិតទៀត ។ នាងបន្ត ៖

www.elibraryofcambodia.org

–" មិនតែប៉ុណ្ណោះ, គេជេរជៀលត្មះខ្ញុំជាច្រើន ព្រោះម្ដាយរបស់ខ្ញុំខ្វាក់ភ្នែកៗ គេជៀលម្ដាយខ្ញុំថាមីកន្ធ្វាក់... យ៉ាងហ្នឹងហើយ, បានជាម្ដាយខ្ញុំថ្នាក់ខ្លួនមានជំងឺរហូតមកដល់សព្វថ្ងៃ... ខ្ញុំឈឺចិត្តណាស់មិត្ត !... ខឹងហាក់រំភ្លាក់ ខ្វាក់រំភ្លែង, គិតសព្វៗ មិនចង់រស់នៅទេ.. តែមកអាណិតកូន.. ប៉ុន្តែជីវភាពជម្រុញឲ្យត្រដាបត្រដួសព្រោះតែការៈចិញ្ចឹមកូននិងម្ដាយពិការភ្នែកទាំងសងខាង, ខ្ញុំគិតក្លាយទៅជាស្រីលក់ខ្លួនទៅហើយ តែក្រែងកិត្តិយសអាប់អន់ មានតែផ្លូវម្យ៉ាងប៉ុណ្ណោះ គឺនិរទេសខ្លួនចេញឲ្យឆ្ងាយ..."

នាងពោលចប់ ទំជូតទឹកភ្នែក ទំនងមិនចង់ឲ្យមិត្តឧត្តមរបស់នាងឃើញនូវទុក្ខសោករបស់នាង ។ វិទ្ធ–យុទ្ធារី ងាកមុខមកសួរ ៖

នៅពេលហ៊ានៈជីវភាពរបស់គ្រួសារខ្ញុំ កាន់តែដុនដាបទៅ ខ្ញុំបានសម្រេចចិត្តមួយដោយយកខ្លួនបម្រើកងទ័ពជាតិហើយ... ខ្ញុំនឹងចូលបម្រើជាតិ... បាញ់ក្បាលអាយៀកកុងដែលឈ្លានពានស្រុកយើង... ខ្ញុំលែងត្រូវការស្លាប់ព្រោះតែរឿងស្នេហាទៀតហើយ បើចំណាច់នឹងស្លាប់គឺស្លាប់នៅលើសមរភូមិតែម្ដង គឺស្លាប់ដើម្បីជាតិ ដើម្បីសេរីភាព ដើម្បីបូរណភាពទឹកដី... "

នាងពោលទាំងទឹកចិត្តអង់អាច តាមចង្វាក់សម្ដីធ្ងន់ៗ ។ ទីបំផុតស្រាប់តែជីតាបន្ទន់សម្លេងមកវិញ ៖

–" ប៉ុន្តែ ចំណងមួយគឺម្ដាយជរាពិការភ្នែកនិងកូនប្រុសដែលទើបនឹងចេះដើរតតិបតតុប អត់ពីខ្ញុំទៅតើរពឹងទៅលើនរណា ?

ចំពោះចនិងសំណួរនេះ នាងដាក់ឡើងបំណងឲ្យមិត្តនាងជួយដោះស្រាយនិងជួយថ្នឹង ។

កញ្ញា ឡៀប–វណ្ណដារ៉ា បានមានអារម្មណ៍កើបញាប់ញ័រយ៉ាងខ្លាំង ព្រោះសម្ដីរបស់មិត្តនារីចំលើចំណុចចិត្តនាងជាក់ច្បាស់ណាស់ ។ និស្ស័យរបស់នាងគឺ «ជាតិ» ព្រោះក្នុងកាលៈទេសៈនេះ ជាតិកំពុងត្រូវការយុទ្ធជនស្ម័គ្រចិត្ត ដើម្បីប្រយុទ្ធជាមួយពួកទមិឡឈ្លានពានទឹកដី ។ តាំងពីដើមមក ទឹកចិត្តនាងស្រឡាញ់ទឹកដីថ្លៃថ្លាដែនកំណើតនាងណាស់ ។

នាងនៅចាំច្បាស់ថា រឿងយួនយកក្បាលខ្មែរធ្វើជុំចង្ក្រានដាំតែអុង... នាងសែនមហាឈឺចិត្តស៊ងក្អួតឈាម !... ឱ! អកុសលកម្មរបស់ខ្មែរអើយ ! ជួបតែនឹងប្រវត្តិសាស្ត្រក្ដៅក្រហាយម៉្លេះ... សតវត្សន៍មួយៗ រួញចុះទៅ រួញតូចឲ្យស្លុតចិត្ត រហូតមក

នៅត្រឹមចុងជើងធូបក្នុងវង្វង់ផែនទីពិភពលោក ។ តើដីខ្មែរអស់ទាំងនោះ ដែលខ្មែរកាលពីដើមជាមហានគរទៅឯណា ? បាត់បង់ដោយសារនរណា ? ...

អស្ចារ្យមែន ! យួនយកសាច់ស្រស់ប៉ូវឈាមមកស្ងួតស្ដេចខ្មែរឲ្យឆីប់ (ជ័យជេដ្ឋាទី២) ... ស្ដេចខ្មែរធ្លាក់ឈ្លក់, ក៏ស្លាប់ក្រោមជើងខាមីយួន ហើយស៊ីញ៉េឲ្យដីទៅយួន... មានស្ដេចខ្លះទៀត ឈ្លោះគ្នីគ្នាដណ្ដើមអំណាច ទៅពឹងយួនឬពឹងថៃ ឲ្យមកវាយខ្មែរគ្នាឯង ដូចតួយ៉ាង សីហនុ ទៅពឹងយៀកកុងឲ្យមកវាយខ្មែរ ដើម្បីឲ្យខ្លួនបានឡើងសោយរាជ្យយកជើងជាន់ក្បាលខ្មែរទៀត ឲ្យខ្មែរទូលបង្គំខ្លួនទៀត ។ តិរច្ឆាន ! ... ទីបំផុត, ដីខ្មែរក៏រួញចុះគួរឲ្យចុកឈាម ! ...

ទាំងនេះហើយដែលធ្វើឲ្យ ឡៅ-វណ្ណដារ៉ា ស្ម័គ្រចិត្តកាន់អាវុធការពារទឹកដី មិនព្រមឲ្យពួកចោរព្រៃយៀកកុងមកប្លន់យកដីខ្មែរមួយដុំ ទៅធ្វើជាកម្មសិទ្ធរបស់ខ្លួនបានឡើយ ។ មិនសូម្បីតែនាងម្នាក់ប៉ុណ្ណោះទេ ខ្មែរដទៃទៀតក៏ដោយ (លើកលែងតែជំពូកជនវង្វេងជាតិខ្លះ) សុទ្ធសឹងក្ដៅក្រហាយផ្ទុះកំហឹងគ្រប់គ្នាទាំងប្រុសទាំងស្រី រួបរួមសាមគ្គីគ្នាយ៉ាងមុតមាំ ប្រយុទ្ធយ៉ាងអង់អាចដើម្បីបណ្ដេញខ្មាំងយៀកកុងឲ្យប្រាសពីដីខ្មែរជាស្ថាពរ ។

យោលតាមឧត្តមគតិជាតិដ៏បរិសុទ្ធនេះ, នាង ឡៅ-វណ្ណដារ៉ា ក៏បញ្ចេញវាចាយ៉ាងម៉ឺងម៉ាត់ ៖

មិត្តយុទ្ធនារី ប្រសើរឧត្តមណាស់ដែលយើងបានជួបគ្នា ។ តាមពិតខ្ញុំបានចូលបម្រើក្នុងកងកុម្ម៉ង់ដូហើយ ដើម្បីការពារទឹកដី... ។ មិត្តជាស្រីដូចខ្ញុំដែរ ហើយស្រីខ្មែរទាំងអស់ មិនសុខចិត្តឲ្យពួកអាយៀកកុងចោរឈ្លានពានចាប់រំលោភឬជិះជាន់ដីខ្មែរបានឡើយ ត្រូវតែក្រោកឡើងកាន់អាវុធប្រយុទ្ធ បើសូវស្លាប់គឺស្លាប់ដើម្បីជាតិ ស្លាប់ក្រោមទង់ជាតិ ស្លាប់ក្នុងឈ្មោះជាកូនខ្មែរគេស្ទំ ... "

ព្រះប្រយោគរបស់ ឡៅ-វណ្ណដារ៉ា កញ្ញា យុទ្ធនារីងើបក្បាលបន្តិចពីខ្នើយ បន្លឺឡើងដោយសម្ដីផុសចេញពីដួងចិត្តពិតៗ ៖

-" ត្រូវណាស់មិត្ត ! ត្រូវណាស់ ! កូនខ្មែរត្រូវតែក្លាហាន ក្រោកឈរឡើងដេញខ្មាំងឈ្លានពាន ដើម្បីកុំឲ្យបាត់បង់ទឹកដីដ៏មានតម្លៃរបស់ខ្មែរ ..."

នាងពោលទាំងដាក់ខ្លួនទៅវិញ ហើយសម្រួលសម្ដី ៖

-" កាលណាខ្ញុំបានជាសះស្បើយ ខ្ញុំចេញពីពេទ្យវិញចូលធ្វើកុម្ម៉ង់ដូទីងគេហើយមិត្ត ! "

www.elibraryofcambodia.org

ឡៀប-វណ្ណដាក៉ លូកហត្ថចាប់ដៃកល្យាណមិត្រដោយការស្និទ្ធស្នាលនិងកក្តីភាព ៖

–" សូមឲ្យមិត្រសម្រេចតាមបំណងប្រសើររបស់មិត្រចុះ ! "

កល្យាណមិត្រថ្មីទាំងពីរសំណេះសំណាលគ្នាពីនេះពីនោះយ៉ាងយូរ ទើបកញ្ញា ឡៀប-វណ្ណដាក៉ លាអ្នកសង្គ្រោះទៅកាន់លំនៅដ្ឋានវិញ ។ ប៉ុន្តែមុននឹងទៅដល់គេហដ្ឋាន ស្រស់ស្រីបានបង្ហួសទៅផ្ទះរបស់កញ្ញា រិទ្ធ-យុទ្ធារី ដើម្បីនាំដំណឹងនេះទៅជម្រាបម្ដាយពិការភ្នែក ។ ហេតុតែនាងជាមនុស្សមានសម្ដីសម្ដៅពិរោះពិសារ ចេះប្រើឲ្យស្រួសរាយផ្អែមល្ហែម ក៏ពុំបានធ្វើឲ្យម្ដាយរបស់ស្រីកំសត់រំជួលចិត្តប៉ុន្មាន ។

អ្នកមីង នាង-សន ម្ដាយ យុទ្ធារី មានរូបរាងស្គមស្គាំងខ្លាំងណាស់ ភ្នែកខ្វង កក្រោជ្រង ថ្ពាល់ផត ដង្ហើមតឹងៗ សឲ្យឃើញថាគាត់មានជម្ងឺក្នុងខ្លួនដុនដាបណាស់ ។ ថ្វីបើរោគាព្យាធិគាត់មែន ប៉ុន្តែស្រ្តីជរាហាក់ដូចជានៅមានការរាំងរៃច្រើន ទទួលរាក់ទាក់ភ្ញៀវយ៉ាងគួរសម ។

ស្អែកឡើង ឡៀប-វណ្ណដាក៉ បាននាំមីងសនឲ្យទៅជួបកូននៅមន្ទីរពេទ្យ ព្រមទាំងទិញផ្លែឈើនំនែកផ្សេងៗ ទៅផ្ញើអ្នកជំងឺផង ។

ជារៀងរាល់ថ្ងៃ ពេលណានាងទំនេរ កញ្ញា ឡៀប-វណ្ណដាក៉ តែងឆ្លៀតទៅអើតសួរសុខទុក្ខអ្នកជំងឺពុំដែលខាន ។

០

០ ០

នៅឯបរិវេណនៃវិទ្យាល័យសៀមរាប ការហាត់វិជ្ជាយុទ្ធសាស្ត្រចេះតែប្រព្រឹត្តទៅ ក្រោមការលំបាកកទីបំផុតគ្មាន ។ សិស្សស្រីប្រុសទាំងអស់ប្រឹងប្រែងយ៉ាងពេញសមត្ថភាពដោយឥតមានស្រែកថ្ងូរមួយហ៊ឺះឡើយ ។

កន្លងកន្លះខែមកហើយ ទើបនៅពេលមួយនោះ លោកអនុសេនិយឯក អ៊ុំ អិត ជាមេបញ្ជាការ ហៅអ្នកទាំងអស់គ្នាឲ្យប្រជុំជួរនៅវាលជុំវិញដងទង់ជាតិ ។ នៅពេលលោកដើរកាត់មុខនាង ឡៀប-វណ្ណដាក៉ និងមិត្រនាងឯទៀត គាត់ញញឹមព្រមទាំងមានប្រសាសន៍ ៖

–" ឥឡូវនេះ វេកការបានឲ្យពួកឯងមួយថ្ងៃសាមសិបរៀលជាថ្ងៃបាយហើយ !"

www.elibraryofcambodia.org

សិស្សនារីទាំងអស់សប្បាយរីករាយគ្រប់គ្នា ។ តាមពិត មិត្តនារីទាំងអស់សប្បាយនោះមិនមែនមានន័យថាស្រេកឃ្លានទឹកប្រាក់សាមសិបរៀលទេ គឺសប្បាយដោយបានមកបម្រើជាតិដោយស្មោះស្ម័គ្រ ។

ក្រោយមក លោកមេបញ្ជាការបានប្រកាសពីមុខកងកុម្ម៉ង់ដូទាំងអស់ដោយសំដីពីរោះខ្លឹមសារ ៖

" ប្អូនទាំងអស់គ្នា ទាំងប្រុស ទាំងស្រី បានហាត់រៀនវិជ្ជាយុទ្ធសាស្ត្រអស់រយៈពេលកន្លះខែមកហើយ។ កន្លះខែនេះ ប្អូនបានទទួលកាត់នូវការលំបាកវេទនាយ៉ាងច្រើន។ ប៉ុន្តែ ប្អូននៅតែតស៊ូរួមសាមគ្គីគ្នា ទំក្រេបជញ្ជក់នូវវិជ្ជាដ៏ពិសេសនេះដើម្បីសម្រាប់ការពារជាតិ ដែលជាតិកំពុងស្ថិតក្នុងគ្រោះអាសន្ន ដោយសារអំពើលោភឈ្លានពានដ៏ព្រៃផ្សៃពីពួកចោរយៀកកុង។ សភាពការណ៍នេះបានធ្វើឲ្យរៀមច្បងទាំងអស់មានការចាប់អារម្មណ៍ជាពិសេស នូវទឹកចិត្តស្នេហាជាតិពិតៗរបស់ប្អូន..ក្នុងនាមនៃរដ្ឋាភិបាល ខ្ញុំសូមថ្លែងនូវអំណរគុណ និងស្វាមីភក្តិចំពោះប្អូនដោយស្មោះស្ម័គ្រ ។ រដ្ឋាភិបាលសូមសន្យាថានឹងជួយផ្គត់ផ្គង់ប្អូនៗ ឲ្យយល់នូវសេចក្តីរុងរឿងជាស្ថាពរ... ជយោ ! កងកុម្ម៉ង់ដូវិទ្យាល័យសៀមរាប ! "

ជាមួយសម្រែកទាំងក្រោយនេះ ហ្វូងសិស្សទាំងអស់ស្រែកជ័យឃោសន៍បន្តឡើងលាន់រំពងគួរឲ្យព្រឺក្បាល សម្តែងនូវសក្ខីភាពនៃសេចក្តីតស៊ូប្តូរផ្តាច់ ក្នុងកិច្ចប្រយុទ្ធបណ្តេញខ្មាំងឈ្លានពាន ។

មេឃថ្ងៃនេះដូចជាមានហឫទ័យល្អ ។ ពពកមួយផ្ទាំងធំមកបាំងព្រះអាទិត្យបណ្តាលឲ្យបរិវេណវិទ្យាល័យយល់នូវភាពស្រទុំត្រជាក់ប្រសើរ ។ ជួនជារំហោបក់មករំភើយ ៗផង ទង់ជាតិបក់រវិច ៗ ហាក់ដូចជាសញ្ញាបោយដៃហៅប្រជាជនខ្មែរគ្រប់រូប ឲ្យក្រោកឈរឡើងស្ម័គ្រស្មាគមគ្នា ដើម្បីសំពងក្បាលពួកចក្រពត្តិឈ្លានពានយៀកកុងឲ្យរាវៃតហោងអន្តរធាន ។

បន្ទាប់មក លោកមេបញ្ជាការក៏បញ្ជាក់បន្ថែមទៀត ៖

-" ប្អូនទាំងអស់គ្នាបានរួមសាមគ្គីគ្នានេះ រដ្ឋាភិបាលស្រោចស្រង់ជាតិយើងមិនព្រងើយកន្តើយនឹងប្អូនទេ ព្រមទាំងបានផ្តល់នូវកម្រៃខ្លះជូនប្អូន នូវប្រាក់សាមសិបរៀលក្នុងមួយថ្ងៃ។ នេះជាវិភាគទានមួយសម្រាប់ឲ្យយើងទាំងអស់គ្នារឹតតែមានកម្លាំងប្រយុទ្ធប្រឆាំងពួកយៀកកុងលុះថ្ងៃអវសាន ! "

www.elibraryofcambodia.org

ស្នូរទះដៃបន្ទីក្រោមសម្លេងសោមនស្សផ្ទុះឡើងពីសន្តានចិត្តរបស់មិត្តសិស្ស កម្ពុជ ធ្វើឲ្យបរិយាកាសនៃវិទ្យាល័យទាំងមូលក្លាយទៅជាទីលានសាមគ្គីមួយដ៏មហាធំធេងមិនអាចរាស់កម្រិតបាន ។

មួយរយៈក្រោយមកទៀត លោកមេបញ្ជាការដែលធ្លាប់ដឹងទឹកចិត្តនិងទេពកោសល្យរបស់មិត្ត ឡៅ-វណ្ណដារ៉ា ជាក់ច្បាស់ ក៏តម្រូវឲ្យនាងឡើងថ្លែងនូវសមានចិត្តរបស់នាងកណ្តាលទីប្រជុំ មានសំនៀងក្នុងន័យខ្ទីមសារដូចតទៅ ៖

–" មិត្រទាំងអស់គ្នាដែលស្ម័គ្រចិត្តមកឈរនៅកណ្តាលថ្ងៃក្តៅហែងនេះ សុទ្ធសឹងជាអ្នកប្តូរជីវិតសាច់ឈាមដើម្បីជាតិ សាសនា សាធារណរដ្ឋខ្មែរ ដោយជាក់ច្បាស់. យើងរួមគ្នាកាន់អាវុធជាក់ក្បាលអាយៀកកុងចោរឈ្លានពាន ឲ្យថយពីទឹកដីខ្មែរ ។ គឺក្នុងន័យនេះឯងហើយដែលយើងចូលខ្លួនបម្រើក្នុងកងកម្ពុជ ដោយគ្មាននរណាជាអ្នកចាប់បង្ខំអូសទាញឡើយ ពិតជាកើតឡើងដោយមនសិការជាតិដ៏ពិតប្រាកដ..."

ស្នូរទះដៃលាន់រំពង ជានិមិត្តរូបនៃការពេញចិត្តដ៏ក្រៃលែង ។ នាងវណ្ណដារ៉ាបន្តទៅទៀត ៖

–" ហេតុដូច្នេះ, សូមមិត្រទាំងអស់គ្នាយល់ឲ្យច្បាស់ពីន័យនៃការសាមគ្គីរបស់យើង ដែលជាបេងជីមាំទាំ សម្រាប់ការពារជាតិ ហើយទំហាត់រៀនវិជ្ជាយុទ្ធសាស្ត្រទៅទៀត ក្នុងក្របខ័ណ្ឌស្រឡាញ់គ្នាជាសមភាពជាភាតរភាព លុះត្រាតែបានសម្រេច .... ជយោ ! មិត្រកងកម្ពុជវិទ្យាល័យសៀមរាប ! ..."

អញ្ជើនសព្ទលាន់ស្នូរយ៉ាងយូរ បញ្ជាក់យ៉ាងច្បាស់នូវការតស៊ូសាមគ្គីចងជាបាច់ ដើម្បីរក្សាទឹកដីឲ្យគង់វង្ស ។

ការសិក្សាវិជ្ជាយុទ្ធសាស្ត្រក្នុងបរិវេណនៃវិទ្យាល័យសៀមរាប បានប្រព្រឹត្តទៅក្នុងសភាពស្និទ្ធស្នាល និងព្យាយាមប្តូរប្តេជ្ញាអស់រយៈពេលម្តងប្រាំពីរថ្ងៃទើបចប់ៗ នៅទិវាបញ្ចប់កម្មសិក្សានេះ, សិស្សទាំងឡាយបានរួមគ្នាធ្វើពិធីជប់លៀងយ៉ាងអ៊ឹកធឹកមួយ ដើម្បីជាកិត្តិយសដល់អស់លោកគ្រូជារៀមច្បងទាហានទាំងអស់ដោយមេត្រីភាពជាទីបំផុតៗ គួរកត់សម្គាល់ផងដែរថា នៅពេលនៃការជប់លៀងនេះ មេឃនៃខែត្រសៀមរាបមានសភាពស្រទុំស្រទន់ ហាក់បីដូចជាជួយស្រណោះស្រណោកខ្លោចផ្សា ចំពោះការបែកគ្នារវាងគ្រូនិងសិស្សកម្ពុជ ។ គេអាចស្តាប់សូរក្នុងដម្រៅដួងចិត្តនៃម្នាក់ៗ បានយ៉ាងប្រាកដទៀតថា រយៈពេលម្តងប្រាំពីរថ្ងៃ ប៉ុន្តែគឺតែមានសភាពខ្លីពេក

www.elibraryofcambodia.org

កន្ទង់ តែក៏គឺជាថ្ងៃដែលគេបានស្គាល់គ្នាច្បាស់ណាស់ គ្រូបង្ហាត់ស្គាល់ទឹកចិត្តនិងឧត្តមគតិរបស់សិស្សព្រមទាំងសេចក្ដីតស៊ូព្យាយាមគួរជាទីសរសើរ ។ ឯសិស្សក៏ស្រឡាញ់រាប់អាន គោរពលោកគ្រូបង្ហាត់ទាំងអស់នោះដោយសុទ្ធចិត្តដែរ ។ ការយោគយល់គ្នានេះឯងហើយ និងការដែលយើងត្រូវបែកគ្នានេះឯងហើយ បានញ៉ាំងពិធីជប់លៀងឲ្យក្លាយទៅជាបរិយាកាសមួយ មានសភាពសែនអាឡោះអាល័យស្ទើរថ្លែងពុំបាន ។ នេះគឺជាអនុស្សាវរីយ៍មួយកម្រនឹងមានណាស់ គេបែកគ្នាទាំងអួលអាក់ បែកគ្នាដោយគ្មានសង្ឃឹមថាបានជួបគ្នាវិញឡើយ !...

គួរសង្កេតម្យ៉ាងទៀតបានថា លោកអនុសេនីយឯក គឹម-ឡេា ដែលធ្លាប់មានសន្ដានចិត្តប្រពៃ, ធ្លាប់មានព្រហ្មវិហារធម៌ប្រកបដោយកក្ដីភាព ចំពោះប្អូនជាសិស្សកងកុម្ម៉ង់ដូទាំងអស់នោះ បានធ្វើឲ្យហឫទ័យរបស់គាត់មានសភាពមិនប្រក្រតីសោះ ។ ជាការធម្មតាទេ, ធ្លាប់ជួបមុខគ្នាក្នុងស្ថានភាពប្រពៃ ឃ្លាតគ្នាវិញនាំបណ្ដាលឲ្យមានការអណោចអធម្មជាអនេក ។ គាត់ដើរសំណេះសំណាលជាមួយយុវសិស្សទាំងអស់យ៉ាងស្និទ្ធស្នាល ។ ការសំណេះសំណាលនេះជាអនុស្សាវរីយ៍មួយ មិនអាចឲ្យលោយសាបសូន្យពីចិត្តារម្មណ៍របស់មិត្តសិស្សកុម្ម៉ង់ដូនោះបានឡើយ ។

កញ្ញា ឡៀប-វណ្ណដាក់, តំណាងសិស្សកុម្ម៉ង់ដូ, ក្រោកឡើងថ្លែងបើកពិធីជប់លៀង ក្រោមសំនៀងគួរឲ្យអណោចខ្លោចចិត្ត ៖

-" លោកគ្រូ ! មិត្តទាំងអស់គ្នា ! នេះជាបរិយាកាសមួយ ដែលប្រព្រឹត្តឡើងដើម្បីជាកិត្តិយសដែលមិត្តកងកុម្ម៉ង់ដូទាំងអស់ ត្រូវបានលោកគ្រូទាំងអស់ឃ្លាតឆ្ងាយយ៉ាងអាឡោះអាល័យ ។ រយៈពេលម្ភៃប្រាំពីរថ្ងៃដែលយើងធ្លាប់បានហាត់រៀន យើងបានស្គាល់ចិត្តថ្លើមគ្នាយ៉ាងច្បាស់លាស់ណាស់ ធ្លាប់បានស្គាល់អធ្យាស្រ័យល្អរាក់ទាក់គ្នានិងគ្នា ។ ឥឡូវលោកគ្រូនឹងឃ្លាតពីយើងហើយ ធ្វើឲ្យយើងសោកស្ដាយនូវអនុស្សាវរីយ៍ដែលយើងធ្លាប់ហាលថ្ងៃ ធ្លាប់លូន ធ្លាប់រត់... ប៉ុន្តែ អស់លោកជាវៀមច្បងសុទ្ធសឹងមានការៈជាអ្នកប្រយុទ្ធ ។ ពេលនេះ, គ្រាស្រុកទេសយើងមានចម្បាំង, លោកគ្រូក៏តោងតែបំពេញកាតព្វកិច្ចជាអ្នកបម្រើជាតិដែរ ។ យើងខ្ញុំគ្មានអ្វីជូនជាសគុណទេ មានតែការជប់លៀងនេះជានិមិត្តរូបនៃស្វាមីភក្ដិនិងជាការប្រសិទ្ធិពរ សូមឲ្យលោកគ្រូមានជ័យជំនះគ្រប់សមរភូមិប្រយុទ្ធជាកយោ្យាភាពដើម្បី ជាតិ - សាសនា និងសាធារណរដ្ឋខ្មែរតទៅ ! ..."

www.elibraryofcambodia.org

ស្ពរទេះដៃលាន់រំពង់ឡើង ហាក់ដូចជាជួយបញ្ជូនសម្លេង ឡៀប-វណ្ណដារ៉ា មិត្តនារីយើង ឲ្យបានឮដល់ពួកអារក្សទេវតាទាំងឡាយៗ បន្ទាប់មក, លោកសក្តិបី គិម-ឡោ ឡើងថ្លែងជាតំណប ។ ក្នុងការតបវិញនេះ, លោកសក្តិបីមានការអួលអាក់យ៉ាងខ្លាំង ជាហេតុធ្វើឲ្យប្រយោគរបស់គាត់ដាច់ៗ ៖

-" ប្អូនទាំងអស់គ្នា, ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដែលប្អូនផ្តល់កិត្តិយសដល់បងជាគ្រូ ។ ប្អូនជ្រាបស្រាប់ហើយ ភារៈកិច្ចរបស់បងជាទាហាន គ្មានការទៀងទាត់ទេ តាមតែព្រឹត្តិការណ៍ផ្ទុះឡើង និងយោលតាមសេចក្តីត្រូវការរបស់ជាតិ ។ ពេលដែលខ្ញុំឃ្លាតពីប្អូនទាំងអស់គ្នានេះ គឺគ្មានសង្ឃឹមថាបានវិលមកជួបប្អូនវិញផងទេ ព្រោះសង្គ្រាម ! ខ្ញុំមិនតូចចិត្តទេ យើងឃ្លាតគ្នាសិនចុះព្រោះជាតិត្រូវការ ប្រសិនមានភ័សនា ដល់ស្រុកទេសយើងមានសន្តិសុខបានសាន្តត្រាណវិញ យើងគង់នឹងបានជួបគ្នាមិនខាន ..."

ក្រោយពីសេចក្តីប្រកាសនេះទៅ, ការជប់លៀងក៏ប្រព្រឹត្តយ៉ាងឧឡារិក ។

ម្ហូបអាហារសម្រាប់ការជប់លៀង, នាង ឡៀប-វណ្ណដារ៉ា និងមិត្តភក្តិនាងឯទៀតជាអ្នករ៉ាប់រងរៀបចំ ។

លោកសក្តិបីមានប្រសាសន៍ទៅ ឡៀប-វណ្ណដារ៉ា ៖

-" កូនស្រីប៉ាប៉ាប្រសប់ធ្វើម្ហូបអស្ចារ្យ ! ប៉ាប៉ាសូមអរគុណហើយកោតសរសើរ ! "

កញ្ញា ឡៀប-វណ្ណដារ៉ា ដាក់ទឹកមុខដោយអៀន ៖

-" ប៉ាប៉ាអួតមាយាពេក, មាយមិនសូវប្រសប់ប៉ុន្មានឯណា ! "

លោក គិម-ឡោ ញញឹម ។

បន្ទាប់ពីការជប់លៀងទៅ, យុវសិស្សកងកុម្មង់ដូទាំងអស់ ត្រូវបានឈប់សម្រាកនៅផ្ទះ រហូតដល់ជិតមួយសប្តាហ៍ ទើបកងកុម្មង់ដូសិស្សទាំងអស់នោះ ត្រូវបានហៅឲ្យចូលទៅសាលាវិញ ដោយបានទទួលពត៌មានថា ស្រុកទេសរឹតតែមានអាសន្នខ្លាំងឡើងជាលំដាប់ ។

**

**    **

## វគ្គទីប្រាំ

# នៅវិទ្យាល័យសៀមរាប

ចាប់ពីថ្ងៃទី ១៧ ឧសភា ១៩៧០ ទៅ, កងកុម្មង់ដូសិស្សសៀមរាប ក៏បានទទួលបញ្ជាឲ្យរៀបចំសកម្មភាពចម្បាំងឡើងវិញ ដោយមានលោក ទេង-តេង ជាមេបញ្ជាការបណ្ដោះអាសន្ន និងលោកអនុសេនីយត្រី ប៉េង-ប៉ែម ជាទីប្រឹក្សាបច្ចេកទេស ហើយជាអ្នកទាក់ទងរកគ្រឿងសព្វាវុធគ្រប់បែបយ៉ាងមកផ្ដល់ឲ្យកងកុម្មង់ដូដោយទាន់ពេលវេលា ព្រមទាំងបុគ្គលិកនៃនាយកដ្ឋានខេត្ត, វិទ្យាល័យសៀមរាប និងអនុវិទ្យាល័យអង្គរទាំងអស់ជាអ្នកឃុំគ្រង ទទួលខុសត្រូវតាមផ្នែកតាមក្រុមទាំងអស់ផង ។

មកដល់ថ្ងៃទី ២៦ ឧសភា ១៩៧០, លោកវរសេនីយឯក ទៀប-បែន ជាមេបញ្ជាការកងពលថ្មើរជើងលេខ ១២ មានភារៈមកធ្វើអន្តរាគមនៅទីរួមខេត្តសៀមរាប ហើយកងពលមួយបានបំបាក់ស្បាតសត្រូវ ក្នុងពេលពួកវាល្បងវាយប្រហារខេត្តពោរពេញដោយសម្បត្តិវប្បធម៌ជាតិដ៏ថ្លៃថ្លា រួមជាមួយទីងសហការីដ៏អង់អាចក្លាហានផ្សេងទៀត បានអញ្ជើញទៅតែងតាំងលោកអនុសេនីយឯក ជួប-ភ័ន់ឌី ជាមេបញ្ជាការនៃកងវរសេនាតូចយុវជនសៀមរាប (ពីដើមជាកងកុម្មង់ដូសិស្ស) ដោយមានអនុសេនីយឯក ប៉េង-ប៉ែម ជាមេបញ្ជាការរង, លោក គង់-សារុន ជាទីប្រឹក្សានយោបាយប្រចាំកងវរសេនាតូចនេះផង ។

សូមបញ្ជាក់ថា កងវរសេនាតូចនេះ មានកងអនុសេនាធំបញ្ជា ដែលមានសិស្ស ៨៧ នាក់និងបុគ្គលិក ២៨ នាក់ និងកងអនុសេនាធំ ៤ ទៀត ដែលមានសិស្ស ១១២ នាក់ និងបុគ្គលិក ១៤ នាក់ក្នុងមួយកងៗ ។ ដូច្នេះ កងវរសេនាតូចយុវជនសៀមរាប មានយោធាទាំងអស់ ៦១៩ នាក់ ។

ចាប់តាំងពីលោកអនុសេនីយឯក ជួប-ភ័ន់ មកកាន់កាប់កងវរសេនាតូចយុវ-ជនសៀមរាបនេះ បានបំពេញបេសកកម្មយ៉ាងស្វាហាប់ និងអង់អាចជាទីបំផុត ។ ដូចជានាំគ្នាជីកជម្រក និងធ្វើលេណដ្ឋានឲ្យបានត្រឹមត្រូវតាមក្បួនខ្នាតយុទ្ធសាស្ត្រ ។ ពិសេស, គេបានចែកគ្នាឃ្លាំមើលខ្មាំងដោយយកចិត្តទុកដាក់គ្មានប្រហែសធ្វេស ព្រម

www.elibraryofcambodia.org

ទាំងធ្វើការត្រៀមខ្លួនប្រុងប្រយ័ត្ន ដើម្បីប្រយុទ្ធនឹងខ្មាំងដោយទឹកមុខញញឹមជានិច្ច ឈមមុខរកសត្រូវគ្មានតក់ស្លុតសូម្បីបន្តិចបន្តួចឡើយ ។

គេកត់សម្គាល់ឃើញថា យុវមិត្តយើងទាំងអស់បានបញ្ចេញកម្លាំងកាយទំប្រឹង កាប់ដីទាំងស្រីទាំងប្រុស ដើម្បីជីកលេណដ្ឋានតាមដោយកន្លែងរៀងៗ ខ្ទនព័ទ្ធជុំវិញវិទ្យាល័យ ។ អ្នកខ្លះទៀតក៏ចែកគ្នាយាមល្បាត ដើម្បីការពារយថាហេតុផ្សេងៗ ។

ចំណែកនាង ឡៀប-វណ្ណដារ៉ា ព្រមទាំងមិត្តនារីជិតស្និទ្ធបីនាក់ទៀត បាននាំគ្នាជីកលេណដ្ឋាននៅក្បែរដើមចំបក់ស្ថិតនៅខាងជើងក្លោងទ្វារចូលវិទ្យាល័យ ដែលនៅខាងត្បូងនាទិសខាងលិច ។ ដើមចំបក់ទាំងនេះមានទំហំធំបន្តិចដែរ ។ នៅពេលជីកលេណដ្ឋានរួចហើយ, នាង វណ្ណដារ៉ា មិត្តនារីរបស់យើងបានប្រាប់ទៅមិត្តទាំងបីថា ៖

-" អើ, ពួកឯងសុទ្ធតែធ្មេញឈើទ្ធិ ត្រូវតែនាំគ្នានៅក្រាបខាងក្រោយដើមចំបក់នេះហើយ មានដើមចំបក់ការពារស្រាប់ ទុកឲ្យគ្នានៅក្រាបក្នុងត្រង់សេចុះ ព្រោះគ្នាវែងជាងគេ ! "

អ្នកទាំងអស់នាំគ្នាសើចលាន់ឡើង ហើយក៏នាំគ្នាក្រាបសាកល្បងមើល ដោយដាក់ដងចបធ្វើជាកាំភ្លើងបញ្ចេញកាណុងទៅខាងក្រៅរបង ធ្វើហាក់ដូចជាប្រុងបាញ់សត្រូវដូច្នោះ ។

កញ្ញា ឡៀប-វណ្ណដារ៉ា ស្រែកប្រាប់មិត្តនារីរបស់គេ ៖

-" អើ, ពួកឯងក្រាបហើយក្លែកកុំភ្លេចមើលពួកអាយៀកកុងឲ្យសោះ តម្រង់ក្បាលវាឲ្យចំ ហើយបាញ់កុំឲ្យខុសមួយវ៉ី ! "

កញ្ញា លើង-ផល្លីន ជាប្អូនរបស់នាង លឿង-កុំផា រៀននៅថ្នាក់ទីមួយ "ខ" តបវិញ ៖

-" សូមបងមាយកុំព្រួយ, ពួកយើងនៅត្រង់នេះមើលទៅក្រៅបានច្បាស់ណាស់, បាញ់ក្បាលពួកវាគ្មានខុសទេ ! "

ក្រោយមក, កញ្ញា វណ្ណដារ៉ា ក្រោកពីលេណដ្ឋានជាមួយមិត្តឯទៀត ដោសដីជម្រះពីឯកសណ្ឋានកុម្ម៉ង់ដូ ឧទានទាំងមុខស្រស់ស្រាយ ៖

-" ល្អ ! ពួកឯងធ្វើការល្អប្រសើរ ! "

សូមជម្រាបថា កញ្ញា ឡៀប-វណ្ណដារ៉ា និងមិត្តទាំងបីរបស់នាងស្ថិតនៅក្នុងកងបញ្ជូនសារនៃកងវរសេនាតូចយុវជនសៀមរាប ។ ពួកនាងត្រូវគេឲ្យកាន់កាំភ្លើង

www.elibraryofcambodia.org

Mauser ។ ជាពិសេស, ក្រុមនាងជាចុងភៅផង ។ ចំណែកនាង ឌៀប-វណ្ណដាក់ មាននាទីទៅផ្សារទិញគ្រឿងអីវ៉ាន់ផ្សេងៗ ។

ក្រៅអំពីកិច្ចរវល់មមាញឹកនៅក្នុងបន្ទាយ (វិទ្យាល័យសៀមរាប), កងអនុសេនាធំនីមួយៗ បានត្រូវចាត់ឲ្យចេញទៅធ្វើប៉ាំងកងផ្លូវការពារឡានចំនួនបីកន្លែង គឺផ្លូវពីក្រុងសៀមរាប ទៅភ្នំពេញ, ទៅបាត់ដំបងនិងទៅភ្នំក្រោម ។ កងអនុសេនាធំនេះ ចែកវេនគ្នាយាមក្នុងរយៈ ២៤ ម៉ោងម្តងៗ រីឯអ្នកដែលមិនបានទៅយាម ឬមិនត្រូវវេនយាម ក៏ឈប់នៅចាំយាមបន្ទាយ ដោយស្ថិតនៅក្នុងទីតាំងការពារយ៉ាងមធ្យ័ត ។ យុវជនយើងបានបំពេញបេសកកម្មថ្មីៗ នេះដោយក្លាហានអង់អាច ហើយស្អាតស្អំជាទីបំផុត ក្នុងកិច្ចការឆែកឆេរយានជំនិះ និងអ្នកដំណើរចេញចូលសព្វគ្រប់ទាំងអស់ដោយហ្មត់ចត់ ។ មិនតែប៉ុណ្ណោះ, យុវជនទាំងនេះបានត្រូវទទួលបញ្ជាឲ្យជួយថែរក្សាក្រសួងអភិរក្សអង្គរទៀតផង ។

ករណីយកិច្ចទាំងនេះ, មិត្តយុវជនស្ម័គ្រចិត្តយើងបានបំពេញយ៉ាងល្អិតល្អន់ក្នុងក្របខណ្ឌនៃមនសិការជាតិ ។ គួរកត់សម្គាល់ផងដែរ, លោក គង់-សារុន ជាទីប្រឹក្សានយោបាយប្រចាំកងវរសេនាតូចយុវជនសៀមរាប បានបញ្ចេញសកម្មភាពយ៉ាងសកម្ម ទាំងខាងផ្នែកនយោបាយ ទាំងការសម្រុះសម្រួលវិបត្តិផ្សេងៗ និងទាំងខាងផ្នែកបច្ចេកទេសកងទ័ពទៀតផង ។ ចំណែកលោកអនុសេនិយត្រី ប៉េង-យ៉ែម វិញ ដោយលោកជាបុគ្គលិកខាងឃ្លាំងសម្ភារៈនៃយោធភូមិភាគទី ៤ ផង ក៏បានខ្នះខ្នែងក្នុងការរកគ្រឿងសព្វាវុធ មកផ្តល់ដល់កងវរសេនាតូចយុវជនសៀមរាបនេះយ៉ាងគ្រប់គ្រាន់តាមក្បួនខ្នាតច្បាប់ ។

លើកនេះ, មិត្តយុវជននៃកងវរសេនាតូចយុវជនសៀមរាបទាំងអស់ ពុំបានទៅគេងផ្ទះដូចមុន ៗ ទៀតឡើយ ។ គេស្ម័គ្រចិត្តដេកនៅតាមទីតាំងការពារប្រចាំការផ្ទាល់នឹងដីក្រោមសន្សើមដ៏ត្រជាក់គួរឲ្យព្រឺព្រួច ។ នេះ, សឲ្យឃើញថាគេទាំងឡាយសុទ្ធសឹងជាកុលបុត្រ-កុលធីតាខ្មែរអង្គរវត្តស្រឡាញ់ទឹកដីពិតប្រាកដមែន ដោយពុំព្រមឲ្យសត្រូវចូលមកឈ្លានពានបូរណភាពទឹកដីដោយអយុត្តិធម៌បែបណាឡើយ ។ គេទាំងឡាយសុខចិត្តប្តូរជាសេចក្តីសុខផ្ទាល់ខ្លួនចូលមកកាន់អាវុធ, មកដេកក្រោមមេឃល្ងីងល្ងើយដោយឥតគិតញញើតបន្តិចឡើយ ហើយបើប្រសិនត្រូវគេប្តូរជាជីវិតនោះ, នោះច្បាស់ជាគេទាំងឡាយគ្មានរួញរា សូម្បីប៉ុនសរសៃសក់ឡើយ ព្រោះគេធ្លាប់សច្ចាដោយច្បាស់លាស់ថា បើល្អិតណាសត្រូវមិនឈប់មកឈ្លានពានដែនដីកម្ពុជាទេ,

www.elibraryofcambodia.org

ល្អិកនោះ គេត្រូវតែពើងទ្រូងដាក់សត្រូវជាដរាប ហើយស្ម័គ្រចិត្តស្លាប់ ឈាមក្រាលធរណីដើម្បីជាតិយ៉ាងសុទ្ធចិត្ត ។

មិត្តនារីទាំង ៤ រូបស្រឡាញ់គ្នាដោយស្មោះស្មើណាស់ គេដេកក្នុងទីតាំងតែជាមួយគ្នា ទៅណាក៏ទៅតែជាមួយគ្នាដែរ ហើយនៅក្នុងទីតាំងនិមួយៗ គេគង់ចែកវេនគ្នាយាមពីរម៉ោងម្នាក់ ។ ដូច្នេះឃើញថា ក្រៅពីការនឿយណាយនិងដេកហាលភ្លៀងហាលខ្យល់ គេត្រូវអត់ងងុយរៀនយប់ទៀត ហើយដល់ថ្ងៃឡើង គេទាំងអស់ត្រូវហាត់រៀនយុទ្ធសាស្ត្របណ្ដើរៗ ។ អ្នកទាំង ៤, មានលោកគ្រូម្នាក់ឈ្មោះ ប៉ូ ជាអ្នកទទួលខុសត្រូវថែរក្សាការពារ ។

ម្យ៉ាងទៀត, មិត្តនារីទាំង ៤ រូបសុទ្ធតែរៀនថ្នាក់ទី ១ ទំនើបជាតិ ។ ឯថ្ងៃប្រឡងយកមធ្យមសិក្សាប័ត្រភាគទី១ ក៏នៅឆ្ងាយណាស់ដែរ។ ពេលទំនេរ, ឆ្លៀតឱកាសរៀនខ្លះៗ ព្រោះនៅពេលដេកយាមវិទ្យាល័យ នាងក៏យកសៀវភៅទៅជាប់ជាមួយផងដែរ ។ ក្នុងចំណោមនារីទាំង៤, គេសង្កេតឃើញតែកញ្ញា ឡៀប-វណ្ណដារ៉ា ម្នាក់ប៉ុណ្ណោះ ឧស្សាហ៍ហាត់ឧស្សាហ៍រៀនសូត្រច្រើនជាងគេ ។ ថ្វីត្បិតនាងមានសេចក្តីក្លាហានការពារទឹកដីយ៉ាងនេះហើយ, ជវន្តចិត្តរបស់នាងជាប់តែក្នុងការសិក្សាឥតឈ្លាងឈ្លាត ។

ពេលថ្ងៃទំនេរខ្លះ, នាងតែងអង្គុយខ្ជួនទល់នឹងដើមចំបក់កាន់សៀវភៅសិក្សា ឬជួនកាលខ្លះនាងនាំអាទិមិត្តភក្តិឯទៀតនិយាយលេងសើចកំសាន្តកំដរអារម្មណ៍ ។

រាត្រីមួយនោះ, បរិយាកាសដូចជាស្ងប់បន្តិច តែរងាស៊ីងរីងថ្លាម ។ សន្សើមធ្លាក់ចុះមក ធ្វើឲ្យស្ពានកោពនៃវិទ្យាល័យសៀមរាប ដែលជាបន្ទាយរបស់កងវរសេនាតូចយុវជន ស្ថិតក្នុងសភាពត្រជាក់ដល់កម្រិត ។ យុវជនខ្លះត្រូវវេនយាមបានបំពេញការកិច្ចយ៉ាងម៉ឺងម៉ាត់ជាទីបំផុត, ក្លែកសម្ងំងចុះកាត់ស្បែករាត្រីចេញទៅក្រៅពិនិត្យហ្មត់ចត់ ក្រែងមានខ្មាំងបង្កំខ្លួនចូលមក ។ ឯកាំភ្លើងនៅដៃប្រុងប្រៀបជានិច្ចចាំប្រយុទ្ធយ៉ាងអង់អាច ។

នៅម្ខាងនោះ, យុវមិត្តមួយហ្វូងទៀតមិនទាន់រកកន្លែងសម្រាកនៅឡើយទេ ។ ពួកគេសុទ្ធសឹងតែមិនមែនជាអ្នកត្រូវយាម អង្គុយនៅជុំវិញស្ដាប់មិត្តនារីរបស់គេ, ឡៀប-វណ្ណដារ៉ា, យ៉ាងយកចិត្តទុកដាក់ដែលនាងកំពុងនិយាយពីរឿងផ្សេងៗ ជាហូរហែ ។

កញ្ញា ឡៀប-វណ្ណដារ៉ា បានពន្យល់មិត្តភក្តិឲ្យយល់ន័យនៃសេចក្តីស្នេហាជាតិ ហើយលើកឧទាហរណ៍ផ្សេងៗ តាមខ្សែភាពយន្តពីភាពតស៊ូអង់អាច សុខចិត្តស្លាប់

ក្នុងសមរភូមិរបស់អ្នកស្នេហាជាតិ ។ ចួនកាលនាងលើកវណ្ណកម្មឯកៗ របស់អ្នកនិពន្ធបរទេសជំនាញៗ ជាច្រើនមកបរិយាយនូវសកម្មភាពប្រយុទ្ធក្លៀវក្លាឥតខ្លាចស្លាប់ ។ គេនៅចាំច្បាស់ថា រឿងដែលនាងច្រើននិយាយជាងគេ គឺវនារីបារាំងម្នាក់ដែលត្រូវគេដុតទាំងរស់កណ្ដាលសមុទ្ទមនុស្សកុះករ ពីព្រោះតែនាងធ្វើបដិវត្តនៃសេរីភាពប្រទេសបារាំង ។ នាងនោះឈ្មោះ ហ្សានដាក ។ នាងនិយមការតស៊ូប្រកបដោយសេរីភាពនៃយុទ្ធជនស្នេហាជាតិទាំងឡាយក្នុងសកលលោកណាស់ ។ ការតស៊ូមួយស្វែងរកសន្តិភាព, សេរីភាព និងសាធារណរដ្ឋនិយម ។

ក្នុងសម្ដីរបស់នាង គួរឲ្យកត់សំគាល់បានថា នាងចូលចិត្តសង្គមមួយដ៏មានយុត្តិធម៌, គ្មានការជិះជាន់ គ្មានការប្រកាន់វណ្ណៈ, ពោលគឺសង្គមសមភាព ។ លើសពីនេះ, នាងតែងសង្កត់សម្ដីទៅលើន័យថា "រស់នៅក្នុងសង្គមមនុស្សត្រូវធ្វើសកម្មភាពដើម្បីជាតិ " ។

ម៉ោងម្ដេចប្លាយទៅហើយ ។ បរិវេណវិទ្យាល័យទាំងមូលកាន់តែធ្លាក់ជ្រៅទៅក្នុងរាត្រីកាលគួរឲ្យព្រឺព្រួច ។ ហ្វូងចង្រិតយំទូងន្ទើយផ្ការរើក ជាចម្រៀងញ៉ាំងទឹកចិត្តយុវជនឲ្យក្លាហានអង់អាច ។ ខ្យល់បក់ស៊ុកឈើរ៉ូ! ៗ! ដែលពីមុនម៉ិញស្ងប់ស្ងៀមសោះ ។ ធាតុត្រជាក់កាន់តែបន្ថែមកម្រិតឡើង ។

ប្រើរនេះ, ត្រូវវេនលោកគ្រូ គងសារុន ដើរពិនិត្យមើលស្ថានការណ៍វិទ្យាល័យ។ គាត់ឃើញនាង ឡៀប-វណ្ណដារ៉ា មិនទាន់រកកន្លែងសម្រាកក៏មានប្រសាសន៍ ៖

-" យប់ហើយ, អាមាយមិនទាន់រកគេងទេឬ ? តិចលោអត់ងងុយស្អែកមុខទៅផ្ទះម៉ាក់ស្ដីឲ្យណាំ! "

មិត្តឧត្តមតបស្រស់ស្រាយ ៖

-" មិនអីទេលោកគ្រូ, ពួកយើងមិនទាន់ងុយទេ ! "

-" ឆាប់ទៅរកដេកពួនទៅ ក្រែងមានការណ៍អីឡើង កុំឲ្យរាំអត់ងងុយណាំ, ម្យ៉ាងទៀតជិតដល់ម៉ោងយាមផង ! " លោកគ្រូបន្ថែម ។

លំដាប់មក, ពួកគេក៏បែកគ្នាទៅកាន់កន្លែងរៀងខ្លួន ។

នាងវណ្ណដារ៉ា និងមិត្តភក្តិក៏ទៅកាន់កន្លែងរបស់គេដែរ ។ មិត្តនាងទាំងបីប្រាស់ខ្លួនគេងព្រមគ្នាទាំងមានវាចា ៖

-" យប់ក្រែងតែភ្លៀងផងទេ ! "

www.elibraryofcambodia.org

កញ្ញា លឿង-កុំផា ងើយកន្ត្រាមើលមេឃ, រួចស្ទាប ហឹម ! ៗ ! យ៉ាងវែង ហើយលោសសម្តី ៖

-" មេឃងងឹតណាស់ ច្បាស់ជាភ្លៀងហើយ, ពួកយើងមុខតែពិបាកជាពិតប្រាកដ ! "

បន្ទាប់មក, មិត្តទាំងប្អូនចែកវេនគ្នាយាមពីរម៉ោងម្នាក់ ។ នាង ឡៀប-វណ្ណដាក់ បានប្រាប់មិត្តភក្តិគេឲ្យយាមពីក្បាលព្រលប់ ហើយទុកវេនចាប់ពីម៉ោងម្ភៃប្អូនឡើងលើឲ្យគេ ។

ចែកឡើងចែកចុះ ត្រូវចំវេននាង ជា-សាវេត យាមដំបូង ។ លឿង-កុំផា និង លឿង-ផល្លីន នាំគ្នាគ្រលំក្លួយគេងយ៉ាងស្រួល ។ ត្រូវខ្យល់បក់មកត្រជាក់ៗ, អ្នកទាំងពីរគេងលក់បាត់ទៅ ។

ជា-សាវេត, កាំភ្លើងនៅដៃ, អង្គុយផ្អែកខ្នងនឹងដើមចំបក់ ភ្នែកសម្លឹងទៅក្រៅយ៉ាងហ្មត់ចត់ ។ យូរៗ នាងងាកមកមើលមិត្តនារីនាងម្តង, ឃើញកញ្ញា ឡៀប-វណ្ណដាក់ មិនទាន់រកកន្លែងសម្រាកនៅឡើយ ។ នាងអុជទៀនផ្លុងៗ បើកសៀវភៅទន្ទេញមេរៀន ។

ឃើញដូច្នោះ, កញ្ញា ជា-សាវេត ក៏បន្លឺ ៖

-" មាយ មិនទាន់គេងទេឬ ? "

ម្ចាស់នាមងើបមុខបន្តិចតប ៖

-" ខ្ញាដូចជាមិនទាន់ងុយទេ ! "

បន្ទាប់មក, គេនៅស្ងាត់ស្ងៀមទៅវិញ ។ នាង វណ្ណដាក់ នៅតែទំសិក្សាតទៅទៀត ក្រោមពន្លឺភ្លើងទៀនដែលនាងទំប្រឹងយកដៃបាំង ព្រោះខ្យល់បក់មករកកលរលត់ម្តងៗ ។

លោកគ្រូ គង់-សារុន ដើរពិនិត្យស្ថានភាពអស់មួយជុំ ក៏មកដល់កន្លែងមិត្តនារី វណ្ណដាក់ ឃើញនាងអុជទៀនដូច្នោះ ក៏ស្ទុះចូលទៅជិតសួរតិចៗ ៖

-" ភ្នំ, អ្នកងមិនទាន់គេងទេ ? "

ងីតាងក់ក្បាល ៖

-" ចាំះ ! ដូចជាមិនទាន់ងុយទេ, ម៉ោងទើបតែជាងប្រាំបី, ខ្ញុំមិនធ្លាប់សម្រាកឆ្មើរហ្នឹងផង ! "

លោកគ្រូមើលទៅភ្លើងទៀន ទាំងឲ្យយោបល់ ៖

www.elibraryofcambodia.org

–" សុំទោសចុះមាយ ! ខ្ញុំមិនគួរទោសឯងទេ, បើឯងអុជទៀនអីចឹងទៅ ហាក់ដូចជាធ្វើស៊ីបឲ្យសត្រូវបាញ់ដូច្នោះ ។ ឯងពន្លត់ភ្លើងហើយសម្ងំគេងទៅ ចាំថ្ងៃឡើងសឹមរៀនណា៎ ! "

នាងវណ្ណដាក៉ានឹកឃើញសមហេតុផលដូច្នោះមែន, ឥតប្រកែកក៏ពន្លត់ភ្លើងទៅៗ នាងខ្ចប់សៀវភៅដាក់ទៅក្នុងកន្ត្រក ហើយគេងដណ្តប់ភួយក្បែរមិត្តនារីរបស់គេៗ លោក សារុន ក៏ដើរចេញពីទីនោះទាំងចិត្តអាណិតអាសូរជាពន់ពេក ។ គាត់នឹកក្នុងចិត្តថា ក្មេងនេះចំជាប្រសើរមែន ! គេជិតប្រឡងផង ដោយប្រទេសជាតិត្រូវការ, សុខចិត្តចំណាយពេលដ៏មានតម្លៃមកដេកហាលភ្លៀងខ្យល់ដូច្នេះ ។

មេឃកាន់តែមីរងាស់ជាលំដាប់ ។ សន្ធុះខ្យល់កាន់តែខ្លាំងក្លាឡើង បក់ប៉ើងធូលីដីហុយទ្រលោម ។ ផ្លេកបន្ទោរគួសរាំសាក់ស្មើម្តងៗ ធ្វើឲ្យយើងអាចមើលឃើញបរិវេណវិទ្យាល័យមួយរយៈហើយងងឹតសូន្យទៅវិញ ។ ផ្គរលាន់គ្រឹមៗ ពីជើងមេឃម្ខាងទៅជើងមេឃម្ខាង ហាក់បីដូចជាគម្រាមមហាប្រថពីឲ្យចុះញ៉ម ។ កូនក្អាត់យំគួរឲ្យស្រណោះ ។

នាង ឡៀប–វណ្ណដាក៉ា ទើបតែលើវៗ ទៅ ស្រាប់តែភ្ញាក់ព្រើតឡើង ដោយពេលនោះ ជា–សាវេត ងាស់ដោយប្រាប់ថា ៖

–" មាយ ! មាយ !... ភ្លៀងឥឡូវហើយ, ដាស់ពួកយើងឡើង ! "

ទើបតែដាស់មិត្តពីរនាក់ទៀតឲ្យងើបបានបន្តិច, ភ្លើងពិលមួយចាំងភ្លូតមក ជាមួយវាចាបន្ទឺឡើង ៖

–" ពួកឯងមិនទាន់ដេកទេឬ ? ... ហ៎ៃ, ភ្លៀងឥឡូវហើយ ពួកស្រីៗ នាំគ្នាទៅជ្រកក្នុងសាលាទៅណា៎ ! "

ម្ចាស់សម្លេងគឺមិនមែននរណាក្រៅពីលោកមេបញ្ជាការ ជួប–ក៉ន់ឌី ឡើយ ។

ឮប្រសាសន៍លោកសក្តិបី, មិត្តនារីទាំងអស់មើលមុខគ្នាឡឹនឡង់ ។ នាង វណ្ណដាក៉ា, ក្រោយពីមើលមុខមិត្តគេបន្តិច, ក៏បន្ទឺតបទៅមេបញ្ជាការវិញ ៖

–" លោកសក្តិបី, មិនអីទេ ពួកខ្ញុំអាចអត់ទ្រាំនឹងរងាបាន ហើយពួកស្រីៗ ត្រូវតែនៅហាលភ្លៀងឲ្យដូចពួកប្រុសៗ អីចឹងដែរ ។ ពួកគេអាចប្រយុទ្ធនឹងរងាបាន ពួកខ្ញុំក៏អាចប្រយុទ្ធបានដែរ... ម្យ៉ាងទៀតយើងគោងតែទម្លាប់ខ្លួន ឲ្យចេះនៅហាលភ្លៀងយ៉ាងហ្នឹងហើយ ឧបមាមានអាសន្នកើតឡើង យើងរាងធ្លាប់ស្រាប់នឹងមិនមានវិបត្តិអ្វី ។

ជាពិសេស យើងមិនត្រូវដើរចោលកន្ទេលទេ, ពេលភ្លៀងពួកសត្រូវបានចិត្តណាស់ណាំលោកសក្តិបី ! "

មានវាចាហើយ, នាងងាកមកមើលមុខមិត្តនាងម្តងទៀត ។ មិត្តនារីរបស់នាងញញឹមគាប់ចិត្ត ស្របតាមយោបល់នាងទាំងអស់ ពោលគឺស្ម័គ្រចិត្តនៅហាលភ្លៀង ។

លោក ជួប-ភ័ន់ឌី ពន្លត់ភ្លើងពិល ហើយមានប្រសាសន៍ដោយសេចក្តីពេញចិត្ត ៖

-" ជាការប្រសើរណាស់ ! " រួចលោកស្រែកហៅកូនទាហានបង្គាប់ឲ្យយកសំពត់ភ្លៀងមកឲ្យ ហើយងាកទៅប្រាប់ស្រីៗ វិញ "ហ៎, ពួកឯងនាំគ្នាជ្រកក្នុងសំពត់ភ្លៀងទៅ ! "

មិត្តនារីម្នាក់បន្ទឺសួរ ៖

-" ចុះលោកសក្តិបីបានអ្វីការពារភ្លៀង ? "

លោកអនុសេនិយឯកញញឹមបន្តិច ៖

-" ខ្ញុំអាចទ្រាំនៅហាលភ្លៀងបាន, វាជាទម្លាប់របស់ទាហាន កាលណាមានចម្បាំងហើយធ្លងកាត់មេឃដែលមានភ្លៀងខ្លាំងឬខ្យល់ដូវបក់ពីជើង ! "

ពួកស្រីៗ នាំគ្នាឈ្លបចូលក្រោបក្រោមសំពត់ភ្លៀងនោះ ព្រោះព្រះកិរុណាហាក់ដូចជាជាប់ធម៌មេត្តាបង្អុរមក រុះរោយផងល្អិតៗ ជាស្រេច ។

ឡៀប-វណ្ណដារ៉ា មិនទាន់ចូលជ្រកភ្លាមទេ ។ នាងនឹកឃើញនូវសន្តានចិត្តល្អរបស់លោកមេបញ្ជាការណាស់។ គាត់តែងយកចិត្តទុកដាក់ចំពោះអ្នកនៅក្រោមបង្គាប់ជានិច្ច ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ។ គាត់តែងបរិច្ចាគសេចក្តីសុខផ្ទាល់ខ្លួនចែករំលែកចំពោះអ្នកដទៃ ។ លើសពីនេះ, នាងខ្លាចក្រែងរអែងដោយពួកប្រុសៗ ឯទៀត មិនមានអ្វីបិទការពារតំណក់ភ្លៀង ។ ច្បាស់ជាគេឧបដៃរងាតត្រូននៅក្រោមស្បែព្រះកិរុណានិងខ្យល់ត្រជាក់ ។ ប្រសិនបើគេឃើញនាងបានសំពត់ភ្លៀងមួយពីលោកមេបញ្ជាការ ពិតជាមានការច្រណែន ឬ ចំអកឡកឡឺយថា លោកសក្តិបីយកចិត្តតែស្រីៗ ។

យោលតាមគំនិតនេះ, នាងក៏បន្ទឺទៅលោក ភ័ន់ឌី ៖

-" ពួកប្រុសៗ គេមុខជារិះគន់លោក, ចាំះ !.... "

លោកអនុសេនិយឯកហាក់ដូចជាភ្ញាក់អារម្មណ៍ដែរ ដោយការដែលគាត់មិននឹកស្មានសោះធ្វើឲ្យស្រីៗ ឲ្យយោបល់ទើបគាត់មានការអៀនខ្មាស់ ។ តាមពិតសុទ្ធចិត្ត

របស់គាត់មិនបានបង្អាប់ឲ្យគាត់ប្រព្រឹត្តដោយប្រាសចាកសីលធម៌ ឬ ដោយប្រការផ្សេងៗ ឡើយ ។ ការណ៍នេះកើតឡើងដោយគ្មានចេតនា ។

លោកស្លុងប្រយោគដោយមិនបានគិតទុកជាមុន ៖

-" ការណ៍នេះវាធម្មតាទេ, ប៉ុន្តែគ្មានហេតុអ្វីដែលគួរឲ្យពួកនោះចាប់អារម្មណ៍ឡើយ ខ្ញុំនៅសល់សំពត់ភ្លៀងពីរបីទៀត ហើយម្យ៉ាងទៀត មិត្តយើងខ្លះមានអាវការពារភ្លៀងផ្ទាល់ខ្លួនស្រាប់ ! ... "

ពេលរួចគាត់ប្រញាប់ពិលមើលស្រីៗ ដែលនៅក្រោមសំពត់ភ្លៀង ។ គាត់ពន្លត់ភ្លើងវិញ ហើយថ្លែងជាចុងក្រោយ ៖

-" អូ ! នែ, សូមពួកនាងនាំគ្នាគេងឲ្យបានស្រួលណាំ, តែកុំប្រហែសខ្លួនក្រែងមានហេតុការណ៍អ្វីកើតឡើង ចាំស្តាប់បញ្ជាខ្ញុំ មុននឹងធ្វើការអ្វីមួយៗ ណាំ ! "

មានប្រសាសន៍ចប់, លោកក៏ចាកចេញពីទីនោះ ហើយយកសំពត់ភ្លៀងទៅចែកដល់មិត្តយុវជនឯទៀត ។

ភ្លៀងធ្លាក់ខ្លាំងៗ ដូចហែកមេឃ ។ ខ្យល់ក៏បក់ខ្លាំងដែលណាស់ដែរ, ម្តងយោលទៅកើត ម្តងទៅលិច... ហាក់ដូចជាចង់សម្បារនឹងអ្វីមួយ ។ យូរ! ផ្គរបន្ទោរម្តង ...

យុវសិស្សយោធាទាំងអស់ទ្រាំនៅហាលភ្លៀង ឱបកាំភ្លើងញាក់ខ្លួនទទ្រើកហាក់បីដូចកូនសត្វ ។ ភ្នែកចាក់មុតទៅក្នុងស្ពានទីងនីតដោយឥតហ៊ានប្រហែសមួយដង្ហើមឡើយ ។

លោក ជួប-ភ័ន់ទី និងសហការីឯទៀត គ្មាននរណារកទីជម្រកទេ ស្ម័គ្រចិត្តដើរហាលភ្លៀងទទឹកស្រកក់ ដែលជាហេតុញ៉ាំងទឹកចិត្តយុវជនឯទៀត ឲ្យកាន់តែមានសេចក្តីក្លាហានឡើង ។ គាត់ដើរពិនិត្យស្ពានកាពបន្ទាយដោយឥតប្រហែសឡើយ ។ ចំណែកប៉ែកខាងស្រីៗ ប្រជ្រៀតគ្នាក្រោមសំពត់ភ្លៀងឱបកាំភ្លើងផងញាក់អាត្មាផង ព្រោះសំពត់នោះមិនជាធំប៉ុន្មាន, ម្ល៉ោះហើយភ្លៀងក៏សាចចូលមក ធ្វើឲ្យទទឹកខោអាវជោករងើដល់ខ្លួនតែម្តង ។ ប៉ុន្តែអាកាសៈរងានេះហាក់ដូចជាពុំសូវមានឥទ្ធិពលប៉ុន្មានលើទឹកចិត្តព្យាយាម តស៊ូរបស់គេទាំងឡាយទេ ។ ថ្វីត្បិតតែរងា ថ្វីត្បិតតែភ្លៀង, ប៉ុន្តែកម្លាំងទឹកចិត្តមុះមុតបានបញ្ចេញចំហាយក្តៅកាយៗ មកធ្វើបរិយាកាសឲ្យដូចជាកក់ក្តៅមធ្យម ។ ហួសពីនេះ, មិនឲ្យទំនេរឥតប្រយោជន៍ នាង ឡេប-វណ្ណដារ៉ា ជាមនុស្សធ្លាប់មានវោហារ ក៏នាំមិត្តភក្តិនិយាយលេងពីនេះពីនោះក៏ដរសើចឲ្យញ៉ើ បំភ្លេចអស់ពីរឿងរងា...

រាត្រីពោរពេញដោយក្តីវេទនានោះ, ភ្លៀងធ្លាក់ហូតដល់ម៉ោងជាងបីទៀតក្តី ទើបដកអានុភាពចេញ ៗ កង្កែប, កូនក្អាត់ទាំងឡាយយំទ្រហឹងអឹងអាប់ ៗ

ភ្លៀងរាំងហើយ ៗ ក៏ប៉ុន្តែស្លានទឹកពេញប្រឡាយទៅដោយទឹកល្អក់ល្អក់ ៗ យុវកងទ័ពទាំងអស់ទទឹកខ្លួនជោក ៗ ប៉ុន្តែគេអាចទ្រាំគេងផ្អែកគល់ឈើលុះត្រាតែភ្លឺ ...

* *

*

ល្ងាចមួយ, លោកស្រី ឡៀប-ស៊ុម នាមដើម ប៊ិន-បូរ៉ែបឡាំង បានទទួលភ្ញៀវម្នាក់ ៗ ភ្ញៀវនោះជាអ្នកលក់ទំនិញនៅមួយផ្លូវផ្សារសៀមរាប, ជាចិនស្រីម្នាក់ ដែលបានមកនិយាយខ្សឹបខ្សៀវអុជអាលគាត់ថា ៖

-" អ្នកគ្រូអើយ ! អ្នកគ្រូមិនអាណិតកូនទេឬ បណ្តាយគ្នាទៅធ្វើកុម្ម៉ង់ដូវេទនាចង់ស្លាប់...គេនឹងបញ្ជូនឲ្យទៅច្បាំង, នំ អ្នកគ្រូអើយ! ស្រីៗ ក្មេងៗ គ្នាចេះអី ទៅច្បាំងម៉េចនឹងឈ្នះគេ គ្រាន់តែលឺកាំភ្លើងមិនរួចផង! ... ពួកអាយៀកកុងពូកែៗ ណាស់ .... ប្រយ័ត្នស្លាយកូនណាំ !... ស៊ីមិនឆ្ងាញ់ទេណាអ្នកគ្រូ មួយថ្ងៃសាមសិបរៀល ! ... គ្រួសារអ្នកគ្រូគ្រាន់បើដែរ មានខ្វះលុយឲ្យកូនឯណា, ទៅឃ្លានអីលុយមួយថ្ងៃសាមសិបរៀលនោះ ? "

ប្រយោគដ៏អសប្បុរសនេះ មិនមែនជាចម្រៀងដែលធ្វើឲ្យអ្នកស្រីចាប់អារម្មណ៍ឡើយ ៗ ផ្ទុយទៅវិញ, ជាទឹកសម្តីដែលធ្វើឲ្យគាត់ជិនឆ្អន់ ធ្វើឲ្យគាត់ស្អប់ខ្ពើមបំផុត ៗ

អ្នកស្រីចងមុខក្រមូវ, ដោះវែនតាចេញ ហាក់ដូចជាក្តៅក្រហាយណាស់ ៖

-" ចាំៈ, សូមជម្រាបអ៊ីឯងឲ្យភ្លឺក្នុកចុះ ! មិនមែនលុយសាមសិបរៀលមួយថ្ងៃហ្នឹងទេ ដែលធ្វើឲ្យកូនខ្ញុំចូលធ្វើកុម្ម៉ង់ដូ ឬក៏ដោយសារការបង្ខំអ្វីមួយឡើយ... តាមពិតគឺជាចេតនារបស់កូនខ្ញុំ... គឺមនសិការស្នេហាជាតិ ! វាក្មេងមែន, វាភេទស្រីទន់ខ្សោយមែន, ក៏ប៉ុន្តែ ពូជខ្មែរក្លាហានអង់អាចណាស់, ស្រឡាញ់ទឹកដីកេរ្តិ៍មរតកដូនតា មិនឲ្យសត្រូវឈ្លានពានណាចូលមករំលោភបានឡើយ... សូមអ៊ីជ្រាបម្តងទៀតចុះ, កូនខ្ញុំវាស្ម័គ្រចិត្តដោយខ្លួនវា តាំងពីគេមិនទាន់ឲ្យសាមសិបរៀលមួយថ្ងៃម្ល៉េះ ! "

គាត់ស្ងៀមបន្តិច ទើបបន្តទៅទៀត ៖

-" ដូចជាគ្មានជំនឿទេ ! ... ខ្មែរជាពូជអ្នកចម្បាំងមិនអាចចាញ់អាយៀកកុងបានជាដាច់ខាត ... "

គាត់ញញឹមចំអកក្នុងន័យនៃប្រយោគបន្ថែមដ៏មុតមាំ ៖

www.elibraryofcambodia.org

–" ខ្ញុំសប្បាយចិត្តណាស់ ! សប្បាយដោយឃើញកូនខ្ញុំបានចូលធ្វើកុម្ម៉ង់ដូ បម្រើជាតិ... "

យាយប៉ិកញ្ចាស់ជាតិចិនដាក់ទឹកមុខជ្រប់ ដោយអាការៈអៀនខ្មាស់ដ៏ក្រៃលែង។ វាមានចេតនាអាក្រក់ចង់បញ្ចុះបញ្ចូលធ្វើខ្មែរឲ្យនាតាមផ្លូវចិត្តសាស្ត្រ ប៉ុន្តែបែកទឹកចិត្តស្នេហាជាតិនៃប្រជាពលរដ្ឋខ្មែរ ។ គឺជាលក្ខណៈមួយរបស់សត្រូវ ក្នុងលក្ខណៈជាច្រើនទៀត...

–" អ៊ុំ ... ទេ ... អ្នកស្រី... អ្នកស្រីយល់ច្រឡំហើយ ! " វាដោះសារដោយភ័យខ្លួន, " តាមពិត, ខ្ញុំអាណិត មាយ ណាស់ ព្រោះនាង... ជាក្មេងគួរឲ្យរាប់អាន... "

អ្នកស្រីម្ចាស់ផ្ទះតម្រង់មុខចំអក ៖

–" អរគុណដែលអ៊ីងឯងចេះស្រឡាញ់កូនខ្ញុំ តែការស្រឡាញ់របស់អ៊ីងឯង គឺមានន័យថាសម្លាប់ខ្មែរពិតប្រាកដណាស់ !... "

គាត់ពាក់វ៉ែនតាទៅវិញ ហើយបន្ត ៖

–" សូមអ៊ីជ្រាបថា ខ្មែរសម័យឥឡូវនេះលែងឆោតល្ងង់ឲ្យពួកបរទេសបន្ទិលក្បាល ដូចអាប៉ោងទៀតហើយ ពីព្រោះប្រវត្តិសាស្ត្រម្ដេសតវត្សរ៍កន្លងមក សែនមហាជូរចត់ណាស់ ! "

កញ្ញា ឡៀប-វណ្ណដាក់ មកដល់ជាយូរមកហើយ តែនាងមិនទាន់ចូលផ្ទះភ្លាមទេ ។ នាងឮយាយប៉ិចិនកញ្ចាស់មានវាចាដូច្នោះសែនឈ្នាន់ខ្នាញ់ជាទីបំផុត ។ នាងលបស្ដាប់ឯខាងក្រៅញាក់ខ្លួនទទ្រើក ចង់ស្ទុះទៅអូសកវាទម្លាក់ដី ។ តែនាងទំសង្កត់ចិត្តឲ្យស្ងប់ទៅវិញ, មួយសន្ទុះទើបដើរចូលទៅ ។

ស្ត្រីចិនឃើញមាណវីដើរចូលមក ភ័យប្រហោងពោះ ក្លែកស ចង់ស្ទុះដាក់រមេងាយ, ព្យាយាមបន្ទប់ដោយវាចារញីរញ៉ៃ ៖

–" អ៊ុំ... អ៊ុំ ក្មួយមាយមកហើយ ? .... "

កញ្ញា ឡៀប-វណ្ណដាក់ ស្ងប់មុខមិនចង់និយាយរកឡើយ តែទើសទាល់មកនៅលើផ្ទះទៅហើយ ក៏បោះសម្ដីកំបុតកំបុយតបវិញ ៖

–" មកហើយ ! "

រួចនាងដើរបង្ហួសទៅបន្ទប់នាងខាងក្រោយទៅ ។ ស្រីកញ្ចាស់ចិនទោះហាក់ដឹងខ្លួន ក៏ប្រញាប់លាម្ចាស់គេហដ្ឋានយ៉ាងរួសរាន់ទៅ ។

www.elibraryofcambodia.org

ក្រោយពីដឹងថាមេរោគឧត្បាតចេញផុត កញ្ញា វណ្ណដារ៉ា ចេញមកជួបម្ដាយទាំងមុខស្លុតស្ងប់ ៖

-" ម៉ាក់, ម៉ាក់ម៉េចក៏ចូលចិត្តទទួលភក់ទាក់មកញាស់ហ្នឹងម៉្លេះ ? "

អ្នកស្រីតបមួយៗ ដោយភាពជាមនុស្សស្គាល់ការពិសោធន៍ជ្រៅជ្រះ ៖

-" តាមពិត ម៉ាក់មិនចង់ឃើញមុខវាទេ តែវាចេះតែមក, ដល់លើផ្ទះហើយម៉ាក់មិនដឹងជាធ្វើម៉េច... "

កញ្ញា វណ្ណដារ៉ា សង្រ្កឹតធ្មេញ ៖

-" មានប្រយោជន៍អ្វី ដែលទំលើបញ្ចុះបញ្ចូលគេយ៉ាងនេះ, គឺជាមធ្យោបាយរបស់សត្រូវហើយម៉ាក់ ! គួរផ្ដល់ពិតមានឲ្យវផ្ដការក្ខាមៗ ទៅទើបគ្មានវិបត្តិ... កូនឃើញមុខវាកាលណាចង់ដាក់ឲ្យវាអុកគូថមួយកន្ទែង តែកូនខ្លាចពាក្យដំនៀល ថាទុំក្មេងអត់ពូជ... "

-" អើម៉ាក់ដាក់ឲ្យប៉ុន្មានម៉ាត់ដែរ ! " អ្នកស្រីបន្ថែម ។

មួយរយៈក្រោយមកទៀត, អ្នកស្រីក៏លើកយករឿងផ្សេងមកបកស្រាយវិញ ៖

-" ម៉េចទៅហើយមាយ, រឿងកុម្ម៉ង់ផ្កានោះ ដល់ណាហើយ ? "

តួចតន់ាវយការញញឹមស្រស់ស្រាយ ៖

-" ម៉ាក់, ដំណើរកូនប្រសើរណាស់ ! មាយចង់សម្រេចគោលបំណងអ្វីមួយនៅពេលណាដែលមាយយល់ថាគួរតែធ្វើ... ម៉ាក់... ថ្ងៃអាទិត្យនេះ, ពួកកូនត្រូវធ្វើកម្រងផ្កាទៅប្រសិទ្ធពរឲ្យកងទ័ពស្ម័គ្រចិត្តខែត្រសៀមរាបយើង លើកទៅប្រយុទ្ធនៅស្ពាន ។ កងទ័ពនោះដឹកនាំដោយលោកមេបញ្ជាការ ឯម-សាន ណាំម៉ាក់, ហើយគេតម្រូវឲ្យមាយជាអ្នកជូនពរជ័យ... "

នាងញញឹមតាមនិស្ស័យល្អម្ដងទៀតបញ្ជាក់នូវការគ្រេកអររបស់នាង, រួចបន្ត៖

-" ម៉ាក់ ! ចាំមើលមាយរើសរកពរណាដែលត្រជាក់ត្រជុំ អាចឲ្យកងទ័ពយើងមានជ័យជំនះគ្រប់សមរភូមិប្រយុទ្ធ " ។

អ្នកស្រីញញឹមពេញចិត្តជាក្រៃលែង ៖

-" ម៉ាក់ជួយត្រេកអរផងចុះចំពោះកិត្តិយសនេះ ! "

ប៉ុន្មានថ្ងៃក្រោយមក, ពិធីប្រសិទ្ធិពរជ័យសិរីមង្គលមហាប្រសើរចំពោះកងទ័ពស្ម័គ្រចិត្តនៃខែត្រសៀមរាប ក៏បានចាប់ប្រព្រឹត្តឡើងនៅសាលាខែត្រយ៉ាងអឹកធឹក, មានពិធីបួងសួងដល់អស់អារក្ខារក្សទេវតារក្សាទឹកដី ដល់អស់វិញ្ញាណក្ខន្ធបុព្វបុរស

www.elibraryofcambodia.org

ស្នេហាជាតិទាំងឡាយ ដើម្បីញ៉ាំងទ័ពនេះឲ្យមានជ័យជំនះជាស្ថាពរ ក្នុងការចេញទៅប្រតិបត្តិការកំចាត់ពួកខ្មាំងសត្រូវ ។ ព្រះសង្ឃក៏បានសូត្រជយន្តោរប្រោសព្រំប្រសិទ្ធិឲ្យកងទ័ពផងដែរ ។

ជាបន្ទាប់, កញ្ញា ឡៀប-វណ្ណដារ៉ា ក៏ឡើងថ្លែងជូនពរដែលមានន័យដ៏ប្រសើរឧត្ដម ។ នាងពុំអាចជឿជាក់ថាខ្លួននាងអាចជូនពរបានល្អដូច្នេះសោះ ។

លុះដល់នាងត្រឡប់ទៅផ្ទះវិញ, ហេតុភេទទាំងឡាយហាក់ដូចមានកើតឡើងសំរាប់រូបនាង ជាការចម្លែក ។ ហេតុភេទទាំងនោះឧបត្តិកតាំងពីនាងចូលហាត់កុម្ម៉ង់ដូម៉េះ ។ ព្រោះតាំងពីដើមមក នាងជានារីស្រគត់ស្រគំម្នាក់ ។ ចាប់តាំងពីចូលហាត់កុម្ម៉ង់ដូភ្លាម, នាងហាក់មានការសប្បាយប្លែក ធ្វើឲ្យម្ដាយចាប់អារម្មណ៍ក្រៃលែង ។ ប៉ុន្តែគាត់ពុំបានចាប់ពិរុទ្ធទៅលើហេតុការណ៍អកុសលអ្វីដល់កូនគាត់ឡើយ ។

មកដល់លំនៅ, នាងសម្លឹងមើលរូបថត ហើយទ្រហោយំឡើង ។ ម្ដាយឃើញដូច្នោះ ក៏សួរ ៖

–" មានរឿងអីកើតឡើងឬ មាឃ ?"

ស្រស់ស្រីជូតជម្រះទឹកនេត្រា បែរមករកមាតាឆ្លើយតបដោយសុភាព ៖

–" ម៉ាក់ ! មាឃសប្បាយចិត្តពេក, សប្បាយទាល់តែយំ... ព្រោះមាឃទៅជូនពរដល់កងទ័ពយើង កូនមានពាក្យល្អៗប្រសើរណាស់ដោយកូនបានជូនពរដោយផ្ទាល់ចំពោះទ័ពចេញច្បាំង... ម៉ាក់ ! កូនមានជំនឿថាទ័ពដែលកូនជូនពរនោះ មុខជាមានជ័យជំនះគ្រប់ពេលមិនខាន ! "

អ្នកស្រីមុនដំបូងទំរង់បារម្ភបន្តិចដែរ ក្រែងកូនមានវិបត្តិអ្វីកើតឡើង, ប៉ុន្តែលុះឮនាងពោលដូច្នោះក៏ស្រាកទៅវិញ ប្រែទឹកមុខជាសោមនស្សធម្មតា ៖

–" មាឃ, ម៉ាក់ជួយត្រេកអរដែរ ! " គាត់លើកដៃសំពះ, " សូមឲ្យពរកូនបានសក្តិសិទ្ធដូចប្រាថ្នាចុះ ! "

វណ្ណដារ៉ា សំពះតបទទួលថា " សាធុ ! "

លំដាប់ក្រោយមក, ទ័ពចេញទៅច្បាំងនៅស្រុកស្គួន បានទទួលជ័យជំនះដ៏គួរឲ្យសរសើរ ហើយទ័ពនេះក្រោមកិច្ចបញ្ជាការដ៏ឈ្លាសវៃនិងអង់អាចស្វិតស្វាញរបស់លោកវរសេនិយទោ ឯម-សាន ក៏បានជម្រុលក្បាលរហូតដល់ខែត្រស្វាយរៀងតែម្ដង ។ ស្រុកស្គួនក៏ត្រូវខាងទ័ពជាតិយើងកាន់កាប់ជាស្ថាពរ ...

www.elibraryofcambodia.org

ព័ត៌មាននេះ បានផ្សព្វផ្សាយពេញផ្ទៃប្រទេសកម្ពុជា តាមសារព័ត៌មានផង តាមវិទ្យុជាតិផង ធ្វើឲ្យខេមរជាតិរីករាយនិងកោតសរសើរគ្រប់គ្នា ។ គឺជាកិត្តិយសមួយ !

លោក ឌៀប-ស៊ុម បានអានកាសែតពីព័ត៌មានស្ដីពីការប្រយុទ្ធរបស់ទ័ពជាតិដែលមកពីខេត្តសៀមរាប ជាផ្លូវផ្លែ ហើយតែងនាំព័ត៌មាននេះទៅប្រាប់កូនស្រីសម្លាញ់ចិត្តពុំដែលខកខាន ។

–"មាឃ, ទ័ពដែលកូនជូនពរនោះ មានជ័យជំនះរហូត គួរឲ្យសរសើរណាស់!" លោកប្រុសមានប្រសាសន៍ប្រាប់នាង ។

ឌៀប-វណ្ណដារ៉ា ញញឹមតបវិញទាំងសោមនស្ស ៖

–" ប៉ាឃើញទេ, ពរកូនត្រជាក់ត្រជុំណាស់ ! "

ដំណឹងនេះឯងហើយ កាន់តែធ្វើឲ្យនាងរីករាយសប្បាយចិត្តជាទ្វេឡើង ជាហេតុបណ្ដុះនូវសេចក្ដីអង់អាចក្លាហាន ជាវីរភាពល្អតលាស់ខ្ពស់ជាលំដាប់ទៅទៀត ក្នុងសន្ដានចិត្តនៃនាង ។ មិត្តភក្តិនាងទាំងអស់ឃើញនាងសប្បាយដូច្នោះ, ក៏នាំគ្នាសប្បាយទៅតាមនោះដែរ ញុំាងបរិយាកាសក្នុងកងវរសេនាតូចយុវជនសៀមរាបឲ្យមានវិសាលភាពក្រៃលែង ។

** **

**

www.elibraryofcambodia.org

វគ្គទីប្រាំមួយ

## រាត្រីទីប្រាំមិថុនា

សម្លេងរហាត់ទឹកវិលវល់ធ្វើឲ្យខេត្តសៀមរាបទាំងមូលស្ថិតក្នុងសភាពស្រងេះស្រងោចអណោចអធ័មពន់ពេក ។ ស្ទឹងសៀមរាបទឹកឡើងបន្តិច ហើយរហាត់ទឹកប្រកបដោយកូនលោករត់រមេញ ។ អ្នកធ្លាប់បានស្គាល់ខេត្តសៀមរាប រមែងចងចាំមិនភ្លេចនូវស្ទឹងមួយពោរពេញដោយរហាត់ទឹក ជាសម្ផស្សគួរចាប់ចិត្ត ។ គេទាំងឡាយតែងដើរកំសាន្តទស្សនារហាត់ទឹក, មើលនារីខ្មែរចង់ពុងទូលក្អមឡើងពីកំពង់... ក្រៅពីនេះ, គេអាចឃើញទំនៀមទម្លាប់ប្រពៃណីយដ៏ត្រចះត្រចង់នៃអ្នករស់នៅក្នុងខេត្តសៀមរាបយ៉ាងសុភាពរមទម្យ...

ប៉ុន្តែ ពួកយៀកកុងឈ្លានពានបានសម្ងំដៅទុកជាស្រេចនូវគោលបំណងវាយដណ្តើមយកខេត្តដ៏ប្រណីតនេះ ហើយដល់ទិវានោះវាក៏លូកដៃក្រខ្វក់វាយសម្រុកចូលទីខេត្តតែម្តង ។

ប៉ុម ! ប៉ុម ! ... ផាំង ! ផាំង ! .......

សម្លេងកាំភ្លើងគ្រប់ធុនបានចាប់ប្រគុំឡើង លើសមរភូមិនៃខេត្តសៀមរាប ។ ពេលនេះ, អ្នកស្នេហាជាតិគ្រប់ប្រភេទនៃពលរដ្ឋខ្មែរក្រោកឡើងវាយប្រយុទ្ធយ៉ាងអង់អាច ។ កងពលថ្មើរជើងលេខ ១២ ក៏បញ្ចេញឥទ្ធិពលកំឡាំងក្លាវាយរុញច្រានពួកសត្រូវឈ្លានពានយ៉ាងចាស់ដៃ ។ គ្រប់ទីតាំងការពារក្នុងខេត្តទាំងអស់បានប្រុងប្រយ័ត្នយ៉ាងខ្ជាប់ខ្ជួន ឥតហ៊ានប្រហែសធ្វេសសូម្បីមួយដង្ហើមសោះឡើយ ។

ចំណែកនៅខាងវិទ្យាល័យសៀមរាប ដែលមានក្រុមសិស្សកងវរសេនាតូចយុវជន ក៏បានត្រៀមខ្លួនគ្រប់ពេលព្រមទាំងធ្វើការឃាមល្បាតដោយមធ្យត់ថែមទៀត ។ គេទាំងអស់គ្នាស្ថិតក្នុងស្ថានភាពប្រុងជានិច្ច ប្រុងដោយអង់អាចក្លាហាន គ្មានតក់ស្លុតគ្មានញញើតសូម្បីបន្តិចឡើយ ។ ...

នៅថ្ងៃទី ៣ មិថុនា ១៩៧០ នោះ ដោយលោកអនុសេនិយឯក ជួប-វ៉ាន់ឌី ត្រូវទទួលបញ្ជាឲ្យទៅកាន់ប៉ុស្តិ៍ថ្មីទៀត ទើបមេបញ្ជាការជាន់ខ្ពស់ខាងកងទ័ពនៅសៀមរាប

www.elibraryofcambodia.org

តែងតាំងលោកវរសេនិយត្រី អ៊ា-ជូរតិមមេង ជាមេបញ្ជាការនៃកងវរសេនាតូចយុវជនវៀងវហួតមក ។

នាថ្ងៃលោក ជួប-ភ័ទ្ទនី ផ្លាស់ចេញទៅ, យុវមិត្តទាំងអស់បានធ្វើការជប់លៀងជាកិត្តិយសមួយ ដោយរៀបធ្វើបាញ់ហយយ៉ាងឆ្ងាញ់ប្រណីត ។ កញ្ញា ឡៀប-វណ្ណដារ៉ា ជាអ្នកចាត់ចែងរឿងទៅផ្សារទិញគ្រឿងគ្រៅ និងជាអ្នកចាត់ចែងរៀបចំទូរចង្ក្រានព្រោះនាងធ្លាប់មានកិត្តិយសក្នុងមុខងារនេះ ។ ការជប់លៀងប្រព្រឹត្តទៅយ៉ាងត្រកុំត្រកាល ប្រកបដោយមិត្តភាពជិតស្និទ្ធក្រៃលែង ។

គេនៅចាំច្បាស់ថាពេលយប់ដែលពួកនាងយាម, នាង ឡៀប-វណ្ណដារ៉ា តែងនិយាយយាមចាប់ពីអធ្រាត្ររហូតភ្លឺ ដើម្បីឲ្យមិត្តភក្តិរបស់នាង ជាអ្នកខ្លាចញញើតបន្តិចបន្តួចយាមពីក្បាលព្រលប់ឡើងទៅ ។ គឺប៉ុន្តែការយាមនេះទៀតសោត ប្រសិនបើមិត្តនាងមិនស្រួលខ្លួន ឬអត់ងងុយ, នាងតែងទទួលខ្លួនកាប់រងយាមជំនួស ។ ក្រៅពីការយាមល្បាត, នាងជាអ្នកចូលចិត្តជួយធុរៈគេណាស់ ទោះបីក្នុងករណីណាក៏ដោយឲ្យតែនាងអាចធ្វើទៅបាន ហើយក្នុងបន្ទាយនៃវិទ្យាល័យទាំងមូលបាននាងម្នាក់ ជាអ្នកធ្វើឲ្យមានសភាពអ៊ូអរឡើង ។ ម្ល៉ោះហើយ, គេទាំងឡាយក៏ពុំសូវជាស្ងាត់ប៉ុន្មាន ព្រោះមានមិត្រជំប្រសើរម្នាក់ចេះធ្វើមិនឲ្យគេអផ្សុក ។

រាត្រីនៃថ្ងៃទី ៤ មិថុនា គួរឲ្យខ្លាច ! ......

សម្លេងកាំភ្លើងខ្ទរខ្ទារគម្រាមខែត្រសៀមរាបទាំងមូល។ ប៉ុន្តែស្មារតីតស៊ូនៃកុលបុត្រកុលធីតាខ្មែរគ្រប់រូបបានស្ថិតក្នុងសភាពអង់អាចមុះមុតឥតស្លុត ។ ក្អែកសម៉្ទីងផ្ដោះទៅកាន់ទិសសត្រូវ ហាក់ដូចជាចង់កាត់កហុតឈាម ឲ្យសមនឹងកំហឹងចិត្ត ។

លោកសង្គ្រាមបានបោកកញ្ជ្រោលយ៉ាងសាហាវបំផុត ។ រាត្រីនោះ, ទើសភ្លឺ, គេឮសូរខ្ទរប្រេបពីនៃគ្រាប់កាំភ្លើង ជារាត្រីនាំមកនូវសេចក្ដីក្ដៅក្រហាយរបស់ខេមរបុត្រ ។ យុវសិស្សនៅវិទ្យាល័យបានទទួលបញ្ជាត្រៀមចាំជាស្រេច តាមទីតាំងរបស់ខ្លួន ។ គ្មាននរណាបានដេកពេញភ្នែកម្នាក់បានឡើយ ប៉ុន្តែ បន្ទាយនៃកងវរសេនាតូចយុវជនយើង មិនទាន់បានទទួលការវាយប្រហារពីសត្រូវឡើយ ។

កញ្ញា ឡៀប-វណ្ណដារ៉ា និងមិត្តទាំង ៣ នៅតាមកន្លែងដូចធម្មតា ។ នាងពោលទៅកាន់មិត្តនារី ៖

-" អើ, ពួកឯងទាំងបីនាក់ប្រកគ្រាប់អស់ហើយឬនៅ ? "

ទាំងអស់គ្នាឆ្លើយ ៖

www.elibraryofcambodia.org

-" ស្រេចបាច់អស់ហើយ មាយ ! "

-" ពួកយើងប្រុងឲ្យមែនទែនណា៎ ! " វណ្ណដារ៉ានិយាយ, "កុំបាញ់លេងផ្ដេសផ្ដាស់, តាំងស្មារតីឲ្យនឹងនំ ឃើញវាសឹមបាញ់ បើមិនឃើញកុំបាញ់ ណា៎ ! "

-" មិនអីទេ, ទុកចិត្តចុះមាយ ! " មិត្តនាងតប ។

កញ្ញា ជា-សាវេត មិនស្រួលខ្លួនតាំងពីថ្ងៃម្សិល ។ នាងរុំខ្លួននឹងភួយជិតស្កុងក្រាបពីក្រោមដើមចំបក់យ៉ាងស្ងៀមស្ងាត់ ។

មួយសន្ទុះ, វណ្ណដារ៉ា សួរទៅភួយ ៖

-" ម៉េចអាវេត គ្រាន់បើហើយឬនៅអ្វី ? "

ជា-សាវេត ឆ្លើយឡើង ៖

-" ដូចជាមិនទាន់ស្រួលទេមាយ ! កាន់តែរងាឡើងហើយ ! "

កញ្ញា ជាមិត្តដើរត្តមក្រោកដើរនេនៗ មកជិត ហើយស្ទាបខ្លួនអ្នកឈឺដោយពោល ៖

-" ឯងមិនស្រួលខ្លួនអីចឹង គួរសុំលោកគ្រូដេកក្នុងថ្នាក់ទៅណា៎ ! "

-" មិនអីទេ មាយ ! "

-" ឯងមិនទាន់បាយផង, មកទៅរកបបរញុំាំសិនទៅ កុំឲ្យវាឃ្លានទារិតតែឈឺធ្ងន់ឡើង ! "

រួច, នាងក៏ជូនភួយទៅឯកន្លែងដាំស្លរៀបចំបបរឲ្យនាង ជា-សាវេត ញុំាំទាល់តែឆ្អែត ។

លុះព្រឹកឡើង, កញ្ញា ឡៅ-វណ្ណដារ៉ា ចេញទៅផ្សាររកទិញម្ហូបអាហារផ្សេងៗតាមនាទីរបស់នាង ។ នាងបានឆ្លៀតទៅលេងផ្ទះមួយកែ្ងតសួរសុខទុក្ខម្ដាយ និងរៀបចំសៀវភៅខ្លះទៀតដើម្បីឆ្លៀតរៀននៅពេលយាម ។

នាងបានសួរម្ដាយ ៖

-" ម៉ាក់ ! យប់មិញ ម៉ាក់ភ័យទេ ? "

អ្នកស្រីបែរឡាំងបើកភ្នែកធំៗ សួរវិញ ៖

-" ភ័យអីទៅ មាយ កូន ? "

-" ម៉ាក់មានឮសូរកាំភ្លើងទេ ? " នាងសួរ ។

-" បីមិនឮ ! "

-" ពួកអាយៀកកុងវាចូលមកវាយប្រហារនៅភ្នំគូលេននោះអីម៉ាក់ ! "

www.elibraryofcambodia.org

-" ម៉ាក់ក័យខ្លះដែរ ។ ជាពិសេសម៉ាក់បារម្ភដល់មាយានៅឯសាលាមិនដឹងយ៉ាងណា... " គាត់មានប្រសាសន៍ទាំងមុខស្លុត ។

នាង វណ្ណដារ៉ា សម្លឹងទឹកមុខគ្មានស្លុត ទន្ទឹមនឹងវាចា ៖

-" យប់មិញ, ពួកកូនរៀបចំជាស្រេច ព្រោះគេឲ្យដំណឹងមកថា ឲ្យប្រុងប្រយ័ត្ន ក្រែងលោវាយប្រហារវិទ្យាល័យទៀត... ម៉ាក់, យប់មិញ មាយាគ្មានក័យបន្តិចទេ, ពួកកូនដូចជាក្លាហាន ចង់ឲ្យតែបានជួបអាយៀកកុងលេងឲ្យវាស្គាល់ដៃតែម្តង ! "

ធីតាទៅអង្អែលថ្ពាល់ម្តាយ ទាំងបន្ថែមយ៉ាងទន់ភ្លន់ ៖

-" ម៉ាក់កុំក័យអីនឹងមាយាណាំ, មាយាមិនអីទេ ! "

អ្នកស្រីពុសម្តីកូនសែនរីករាយបានធូរទ្រូងបន្តិច តែគ្មានចាប់អារម្មណ៍អ្វីសោះ។

នាងនិយាយលេងជាមួយម្តាយនិងប្អូនតូចៗ រួចហើយទើបលាម្តាយទៅផ្សារបំពេញភារៈរបស់នាង ។

ថ្ងៃនោះ, វិទ្យាល័យសៀមរាប ស្ថិតក្នុងសភាពប្រុងប្រយ័ត្នជានិច្ចឥតហ៊ានប្រហែសបន្តិចឡើយ ព្រោះតាមពិតមានបានឲ្យដឹងថា ពួកយៀកកុងប្រមាណប្រាំរយនាក់កំពុងវាយប្រហារនៅកំពង់ក្តី ស្រុកជីក្រែង ។ សិស្សកុម្ម៉ង់ដូទាំងអស់រៀបចំខ្លួនជាស្រេចប្រុងប្រយុទ្ធជាមួយខ្មាំង ដោយគ្មាននរណាម្នាក់ឃ្លាតចេញពីស្ថានទីរបស់ខ្លួនឡើយ ។ ប៉ុន្តែ, សិស្សមួយផ្នែកទៀតត្រូវវេនចេញទៅយាមនៃកនេរ កំបំពេញនាទីរបស់ខ្លួនតាមប្រក្រតី ធ្វើឲ្យផ្នែកខាងត្បូងវិទ្យាល័យមានសភាពរង្វើលការយាមល្បាតខ្លះ ។

ម៉ោង ១៤ និង ៣០ នាទីរសៀល ។

មិត្តនារី ជា-សារ៉េត កាន់តែមិនស្រួលខ្លួនខ្លាំង។ កញ្ញា ឡៅ-វណ្ណដារ៉ាឃើញដូច្នោះ ក៏សុំអនុញ្ញាតលោកមេបញ្ជាការជូននាងទៅផ្ទះ ។ ដោយហេតុនោះហើយ ទើបកញ្ញា ជា-សារ៉េត និងឡៅ-វណ្ណដារ៉ា ត្រូវបែកគ្នា, នៅសល់តែមិត្តពីរនាក់ប៉ុណ្ណោះ។

ចូលដល់ព្រលប់នៃថ្ងៃទី ៥មិថុនា១៩៧០, ជានិការសមួយដែលប្រកបទៅដោយសេចក្តីសប្បាយរីករាយជាពិសេស ។ កៃកណ្តឹងយំសំរាត្រចៀកទម្លាក់សម្លេងពីចុងចំបក់ ។ ខ្យល់បក់ផ្លាក់មក នាំទាំងក្លិនផ្កាព្រៃគ្រប់ប្រភេទក្រអូបល្ហិងល្ហែងអប់អាកាសឲ្យឈ្ងុយឈ្ងប់ ។ ស្ទឹងសៀមរាបហូរនាំសរសៃទឹកក្តួចយ៉ាងសុភាពរមទម្យ ក្រោមរស្មីនៃព្រះសុរិយារៀបអស្តង្គត ។

www.elibraryofcambodia.org

នាបរិវេណវិទ្យាល័យ ដែលជាបន្ទាយនៃកងវរសេនាតូចយុវជនសៀមរាប មានសភាពអ៊ូអរជាអនេក ។ ភាពនេះកើតឡើងដោយលោកមេបញ្ជាការថ្មី រៀបចំចែកខោអាវកាគី ១ កំប្លេម្នាក់ និង ប៉េរ៉េពណ៌កាគី ១ ម្នាក់ផង ។ ការចែកចាយនេះ គឺធ្វើឡើងបន្ទាប់ពីពេលបាយល្ងាចមួយស្របក់ធំមកទាំងយប់ងងឹត ។ មិត្រយើងទាំងអស់គ្នាស្លៀកពាក់ខោអាវកាគី និងពាក់ប៉េរ៉េថ្មីទាំងយប់ ហើយចូលទៅក្នុងលោណដ្ឋានទាំងទឹកមុខញញឹមពព្រាយ ។

ខ្លះទៀតមិនទាន់ចូលលោណដ្ឋានភ្លាមទេ នាំគ្នាច្រៀងបទ "មហាសាមគ្គី " នៅត្រង់ទីលានលេងបាល់ទោះ ។ សម្លេងបទមហាសាមគ្គី បានលាន់ឮឡើងអណ្តែតតាមខ្យល់ធ្វើឲ្យទឹកចិត្តយុវជនយើងកាន់តែផុះផុលឡើង នូវសេចក្តីក្លាហានអង់អាច ។ បន្ទាប់មកគេច្រៀងបទផ្សេងៗ ទៀត ដោយមានខ្លះឡើងរាំ ជាហេតុធ្វើឲ្យបរិយាកាសនៃវិទ្យាល័យប្រាសចាកនូវសភាពស្ងប់ស្ងាត់អស់មួយរយៈ ។ ការនេះអាចបញ្ជាក់ឲ្យយើងយល់កាន់តែច្បាស់ថា គេទាំងឡាយគ្មានញញើត គ្មានរួញរា ឬតក់ស្លុតសូម្បីបន្តិចឡើយ ។ ទន្ទឹមគ្នានឹងបរិយាកាសសប្បាយនៃយុវជនខេត្តសៀមរាប, ស្នូរកាំភ្លើងក៏លាន់ខ្ទរគ្រឹកមេឃ នៅឆ្ងាយពីនេះបន្តិចប៉ុណ្ណោះ ។ ប៉ុន្តែ គ្មាននរណាក៏យកតក់ស្លុតបន្តិចឡើយ ។ ផ្ទុយទៅវិញ, គេនាំគ្នាស្រែកបន្ទរឡើងយ៉ាងអង់អាចថា " ជយោ! "

យុវជនម្នាក់ឈរចំកណ្តាលវង់ លើកដៃឡើងប្រកាសយ៉ាងស្វិតស្វាញ ៖

–" ពួកយើងទាំងអស់គ្នា, បើអាយៀកកុងមក, ត្រូវតែប្រយុទ្ធដោយអង់អាច កុំខ្លាច ! កុំរថយ ! សុខចិត្តស្លាប់ប្រសើរជាង កុំឲ្យពួកវាមកយកទឹកដីខ្មែរបានមួយចំអៀកសក់ឲ្យសោះ... យើងជាកូនខ្មែរពូជអ្នកចម្បាំង, យើងមិនត្រូវខ្លាចស្លាប់ទេ... "

ស្នូរទះដៃលាន់រំពងឡើងជ្រែកអាកាសនៃរាត្រីសម័យ ជាសញ្ញានៃការប្តូរផ្តាច់របស់គេ ។ បន្តពីសេចក្តីខ្ទរខ្ទារនេះ, យុវជនម្នាក់ទៀតក៏ងាកបន្តិច បន្ទឺជាបន្ទាន់យ៉ាងក្លៀវក្លា ៖

–" ដីខ្មែរត្រូវតែខ្មែរនៅ, ដូច្នេះយើងជាកូនខ្មែរត្រូវតែរួមដៃគ្នាប្រយុទ្ធកុំឲ្យបាត់ទឹកដីដូចនគរចម្ប៉ាទៀត ... "

ម្នាក់ទៀត, លើកកាំភ្លើងស្រែកខ្លាំងៗ ដោយសន្ទុះចិត្តអង់អាច ៖

–" ពួកយើង, កាំភ្លើងនៅដៃត្រូវតែប្រយុទ្ធលុះត្រាអវសាន, បើឈាមខ្មែរហូរសូមឲ្យហូរលិចប្រទេសយើង កុំឲ្យពួកអាយៀកកុងយកទឹកដីខ្មែរយើងបានឲ្យសោះ, ពួកយើងក្រោកឡើង... ជយោ ! កងវរសេនាតូចយុវជនសៀមរាប ! "

www.elibraryofcambodia.org

សម្រែកជយឃោសទំបន្ទឺឡើងករញ្ជៀវពីក្រោយ ។

លោក អ៊ា-ផូរតិមមេង ឃើញទឹកចិត្តយុវជនអង់អាចដូច្នេះ សែនរីករាយជាអនេក ។ គាត់ដើរទៅកាន់កណ្តាលវង់ ដោយមានយុវជនម្នាក់ក្លាហានជាងគេ ឈ្មោះ ធួយ-សារឿន ជាអង្គរក្សជូនដំណើរផង ។ លោកបានមានប្រសាសន៍ដោយសភាពស្ងប់ ។ យុវជនទាំងអស់នៅស្ងៀមស្ងាត់ត្រងត្រាប់ប្រសាសន៍របស់គាត់យ៉ាងយកចិត្តទុកដាក់ ៖

–" អរគុណប្អូនទាំងអស់គ្នា! បងត្រេកអរណាស់ដោយបានឃើញទឹកចិត្តរបស់ប្អូនប្រកបដោយវីរភាពគួរឲ្យសរសើរ !... ក្នុងកាលៈទេសៈនេះ ប្អូនបានប្តូជាជីវិតដើម្បីជាតិ គឺជាកាយវិការមួយរកគ្មាន... ប្អូនទាំងអស់គ្នាមានចិត្តដូចបងដែរ គឺមិនព្រមថយជាដាច់ខាត ឲ្យសត្រូវយកទឹកដីខ្មែរដ៏ជាទីស្រឡាញ់របស់យើងបានឡើយ។ យើងត្រូវតែប្រយុទ្ធ !...ម្យ៉ាងវិញទៀត, បងសូមផ្តាំប្អូនទាំងអស់គ្នាថា ស្ថានការណ៍ក្នុងប្រទេសយើងកាន់តែធ្ងន់ហើយ, ដូច្នេះគប្បីយើងប្រុងប្រៀបខ្លួនឲ្យបានម៉ត់ចត់គ្រប់ពេលទាំងអស់ ឃ្លាំមើលសត្រូវឲ្យច្បាស់ ឃើញហើយស៊ីមបាញ់ ... "

បន្ទាប់មក, គាត់សង្កត់សម្លេងធ្ងន់ៗ ក្នុងន័យសម្តីថា ៖

–" ប្អូនទាំងអស់គ្នាស្តាប់បញ្ជាខ្ញុំ, ទោះបីយ៉ាងណាក៏ដោយគឺត្រូវស្ថិតនៅក្នុងវិន័យកុំជ្រួលច្របល់ ។ បើត្រូវស្លាប់យើងស្ម័គ្រចិត្តស្លាប់ទាំងអស់គ្នា, ប្រយុទ្ធទៅ ! ... បងនៅជាមួយប្អូនជានិច្ច, បងសុខចិត្តស្លាប់រស់ដើម្បីការពារជាតិយើងឲ្យស្ថិតក្នុងវង្វង់នៃបូរណភាពទឹកដីជាស្ថាពរ ... "

គាត់បន្ថែមជាចុងក្រោយទៀតថា ៖

–" បងសូមទុកចិត្តទាំងស្រុងលើស្មារតីតស៊ូរបស់ប្អូន ! "

ក្រោយមក, អ្នកទាំងអស់ក៏បែកគ្នាទៅកាន់លេណដ្ឋានតាមដោយរៀងខ្លួន ។ គេម្នាក់ៗ ប្រុងជានិច្ច, កាំភ្លើងនៅដៃដោយឥតភ័យតក់ស្លុតឡើយ ។

យើងងាកទៅមើល ឡៅ-វណ្ណដារ៉ា វិញ ។ កត្រីនោះ, នាងមិនទាន់ចូលដំណេកភ្លាមទេ ។ ពីតានាំមិត្តភក្តិសំណេះសំណាលរឿងផ្សេងៗ ។ នាងមានវាចាជាអាទិ៍ ៖

–" ទឹកដីខ្មែរយើងមិនត្រូវឲ្យរលាយសាបសូន្យ ឬធ្លាក់ទៅក្នុងដៃបរទេសណាឡើយ ។ យើងត្រូវតែប្រយុទ្ធលុះត្រាអវសានជីវិត... មិត្តទាំងអស់គ្នាជាអ្នករួមអាវុធ

ត្រូវតែប្រយុទ្ធឲ្យដល់តំណក់ឈាមចុងក្រោយ... យើងកុំខ្លាចពួកវាឲ្យសោះ ទោះបីធ្លាក់ក្នុងស្ថានភាពបែបណាក៏ដោយ, កូនខ្មែរត្រូវសាមគ្គីប្រយុទ្ធកុំភ័យ ... "

ខ្យល់រាត្រីធ្វើបរិយាកាសឲ្យត្រជាក់ព្រឺព្រួច ។ សម្លេងស្លឹកឈើត្រូវខ្យល់កួចពួសូរគួរលន់ទោចចិត្ត ។ នាងបន្តដោយម៉ឺងម៉ាត់ ៖

-" យើងត្រូវមានជំនឿជាចាំបាច់ថា ខ្មែរត្រូវតែឈ្នះ ត្រូវតែជាម្ចាស់នៃទឹកដីកេរ្តិ៍មរតកដូនតារបស់យើង... ទឹកដីដ៏ថ្លៃថ្លានេះជារបស់ខ្មែរ... ដូច្នេះ, កូនខ្មែរត្រូវតែការពារទូវទឹកដីដ៏ជាទីស្រឡាញ់របស់យើងជាដាច់ខាត " ។

កញ្ញា លឿង-កុំផា, ខ្នងផ្អែកគល់ចំបក់, ដៃកាន់កាំភ្លើង ក្លែកវរពែក្នុងស្បែអន្ធការយ៉ាងយកចិត្តទុកដាក់ ។ នាងបញ្ចេញសម្លេងមួយៗ មានទម្ងន់គួរឲ្យរំភើប ៖

-" មាយ ទុកចិត្តចុះ ពួកយើងមិនរត់ទៅណាឡើយ ដរាបណាពួកអាយៀកកុងមិនដកខ្លួនចេញពីទឹកដីយើងទេ ។ ខ្ញុំត្រូវតែតស៊ូជាមួយមិត្តយើងទាំងអស់គ្នា ទាល់តែបានជ័យជំនះ " ។

ឯកញ្ញា ផល្លីន, នៅអង្គុយក្បែរបងស្រី, ផ្ទៀងរណ្តំផ្ទាមនឹងកាំភ្លើងដោយស្ងិតស្ងាញ ៖

-" យប់នេះអីក៏ងងឹតម្ល៉េះទេ... ស្នូរកាំភ្លើងក៏ពុកាន់តែខ្លាំងសន្ធាប់ឡើងគួរឲ្យបារម្ភណាស់ ! ... "

ព្រួយប្រយោគមិត្តនារីរបស់នាង, កញ្ញា ខៀប-វណ្ណដារ៉ា ងាកទៅសួរ ៖

-" អាលីន ឯងខ្លាចឬ ? "

លឿង-ផល្លីន គ្រវីក្បាលយឺតៗ តបរួសរាន់ ៖

-" គួរឲ្យខ្លាចដែរ ព្រោះមិនធ្លាប់ចុះស្លាមសោះ ! "

ខៀប-វណ្ណដារ៉ា រកពាក្យមកពន្យល់មិត្ត ដោយក្បោះក្បាយ ៖

-" មិនត្រូវខ្លាចអីទេជាលីន, បើស្លាប់ក៏ស្លាប់ទៅចុះ គឺយើងស្លាប់ក្នុងន័យការពារទឹកដី... អាលីនឯងត្រូវយល់ថា មួយជាតិនេះគ្មាននរណាស្លាប់ពីវេងទេ ហើយក៏មិនអាចជៀសពីសេចក្តីស្លាប់នោះបានផង... បើបំណាច់នឹងស្លាប់... គួរស្លាប់នៅក្នុងកិត្តិយសសាងកេរ្តិ៍ឈ្មោះ ... "

នាងបំភ្លឺទៅទៀត ៖

-" មនុស្សយើងម្នាក់ៗ កើតមកសុទ្ធតែស្នេហាទូវសិទ្ធិសេរីភាពជាអមតៈ ដូច្នេះយើងត្រូវប្រយុទ្ធដើម្បីសេរីភាពរបស់យើង ! "

www.elibraryofcambodia.org

*រាត្រីកាន់តែទន់ទោរទៅមុខជាលំដាប់ ។ ព្រះចន្ទមួយចំណិតតូចប៉ុនសរសៃសក់នៃរាត្រីមួយកើតនៃខែជេស្ឋ ព្យាយាមជ្រែកពន្លឺប្រណាំងប្រជែងជាមួយនឹងហ្វូងតារារាប់រយពាន់ ។ សម្លេងលលកខ្មោចយំឯឆ្ងាយលាន់ត្រលួច ហែកបរិយាកាសដ៏ស្ងប់នេះឲ្យកាន់តែលន្លង់លន្លោចណាស់ទៀត ហាក់ដូចជួយពង្រឹងទឹកចិត្តមិត្តយុវជនទាំងអស់ ឲ្យកាន់តែក្លាហានឡើង ។ គេនាំគ្នាយាមដោយសភាពស្ងប់ស្ងៀមនិងប្រុងប្រយ័ត្នគ្មានធ្វេសប្រហែសឡើយ ។*

*មិត្តរបស់យើងម្នាក់ឈ្មោះ នួយ-សារឿន ជាមនុស្សមាននិស្ស័យកំប្លែងតាំងពីដើម, គេនាំមិត្តភក្តិប្រុសៗ និយាយសើចលេងកំដរបរិយាកាស ទាល់តែលោកមេបញ្ជាការប្រាប់ឲ្យស្ងាត់ទើបនាំគ្នារកកន្លែងដេក ។ គេបានសម្តីគ្រាន់បើដែរ ។*

*-" តស់, ពួកយើងរកដេកយកអាចម៍ខ្លួកចាំបាញ់ក្បាលអាយៀកកុង ! " នាយបន្ទីឡើងទាំងបោសដីក្បែររបងសាលាប្រាស់ខ្លួនដេកទៅ ។*

*ឯនាង វណ្ណដារ៉ា ក៏មិនទាន់គេងនៅឡើយ ។ នាងនិយាយបន្តទៅកាន់មិត្តនាងទៀតដោយសេចក្តីសង្ឃឹម ៖*

*-" ការស្លាប់ក្នុងសមរភូមិ ជាកិត្តិយសខ្ពស់បំផុតរបស់យុទ្ធជន ។ ឈ្មោះថាយុទ្ធជន គេមិនដែលនឹកឃើញដល់ការស្លាប់ទេ, យើងត្រូវសង្ឃឹមជានិច្ចលើការរស់នៅ... ស្លាប់ដើម្បីជាតិ ជាធម្មតាដែលយើងកើតមកជាខ្មែរ... "*

*ពេលបានប៉ុណ្ណោះស្រាប់តែនាងភ្ញាក់ព្រើត ក្រឡេកមើលទៅឃើញស្រមោលខ្មៅមួយដើរសំដៅមកនាង ។ ធីតាទាញកាំភ្លើងកូនទៅស្រមោលខ្មៅទាំងស្រែកសួរ ៖*

*-" នរណាហ្នឹង ? "*

*សម្លេងមួយតបយ៉ាងសុភាព ៖*

*-" គឺខ្ញុំ, ខ្ញុំទេ ..."*

*-" នរណា ? " នាងសួរបញ្ជាក់ ។*

*-" ខ្ញុំណ៎ា, គឺប៉ូ ... " សម្លេងឆ្លើយ ។*

*រំពេចនោះ, នាងច្របាច់ពិលតូចរបស់នាងដូចស៊ីឡូ បញ្ចាំងទៅរកម្ចាស់ស្រមោល រួចឧទាន ៖*

*-" អូ ! លោកគ្រូទេឬ ?... ខ្ញុំស្មានតែនរណា ! ... "*

*លោកគ្រូប៉ូសើចតិចៗ រួចមានប្រសាសន៍ ៖*

*-" គឺខ្ញុំ ... ពួកនាងមិនទាន់គេងទេឬ ? ... ម៉ោង ១២ អាធ្រាត្រទៅហើយ !... "*

ពូលោកគ្រូប្រាប់ដូច្នោះ, នាងក៏ប្រញាប់ពិលមើលនាឡិកាដៃ ឃើញម៉ោងថ្លៃប្អូនគត់ទៅហើយ ។

–" ឆាប់រកគេងទៅ ... បើមានការអីមិនស្រួលចាំលោកគ្រូមកដាស់ពួកឯងឲ្យភ្ញាក់ ... "

–" ចាំះ លោកគ្រូ ! ... "

ហើយ, លោកគ្រូ ប៉ូ ក៏បង្ហួសដំណើរទៅកាន់កន្លែងគាត់វិញ ។ ចំណែកនាងឡៀប វណ្ណដារ៉ា ក៏ប្រាស់ខ្លួនក្បែរគល់ចំបក់ជាមួយមិត្តនារីរបស់នាងដោយដាក់កាំភ្លើងផ្តេកក្បែរខ្លួនផង ។

មន្តានុភាពនៃរាត្រី បានសណ្តំមិត្តនារីនិងនាង ឡៀប-វណ្ណដារ៉ា ឲ្យលង់លក់អស់មួយស្របក់ធំ ។

** **

**

www.elibraryofcambodia.org

វគ្គទីប្រាំបី

## ព្រលឹងនាង ឡៀប-វណ្ណដារ៉ា

**ស្នូរ**កាំភ្លើងមិនទាន់បន្ថយអានុភាពនៅឡើយទេ ។ ព្រះអាទិត្យរះព្រាងៗ ហើយៗ រហូតដល់ម៉ោងដាំងប្រាំ, មិត្តកងកុម្មុយស៊ូសិស្សយើង នៅតែបន្តសកម្មភាពក្លៀវក្លាក្លាហាន ទប់ទល់បច្ចាមិត្តឈ្លានពានឥតបន្ធូរដៃ ។ ភ្លឺច្បាស់ល្អម, យើងអាចមើលឃើញពួក សត្រូវច្បាស់គ្រប់គ្រាន់ ។

ម៉ោងប្រាំនិងសាមសិបនាទី ។

ហុងដារបស់អាយៀកកុងពីរ, មួយជិះគ្នាបីនាក់នៅខាងមុខ និងមួយទៀតជិះពីរ នាក់ពីខាងក្រោយ, បើកយ៉ាងលឿនកាត់តាមផ្លូវមុខវិទ្យាល័យ ។ មូតូហុងដាជិះបីនាក់, អាម្នាក់អង្គុយកណ្តាលបែរមុខមកក្រោយ ដោយដាក់កាំភ្លើងរ៉ុក្កែតពីលើស្មាអាម្នាក់ នៅអង្គុយក្រោយគេ ហើយបាញ់បណ្តើរ ប៉ុង ! ប៉ុង ! ... សំដៅវិទ្យាល័យយើង ។

ថៃជន្យអាក្រក់អ្វី ! គ្រាប់រ៉ុក្កែតមួយគ្រាប់ហើរតើវ ! មករកមិត្តដែលស្ថិតនៅម្តុំ ក្លោងទ្វារខាងមុខ ។ ប៉ុន្តែមិត្តឯទៀតរហ័សក្រាបចុះទាន់, គ្រាប់នោះហើរវៀទៅបុកមែក ចំបក់មួយបាក់ប្រាវ... ហើយខ្ទាតបំណែកប៉ើងទៅធ្លាក់ចំកណ្តាលខ្នងយុវមិត្តនារី ឡៀប វណ្ណដារ៉ា កំលាហានរបស់យើង កំពុងលុតជង្គង់បាញ់ប្រហារសត្រូវ បណ្តាលឲ្យនាង ទោរខ្លួនទៅមុខបន្តិច ។

នាងបុកចាប់ខ្ទាំង ព្យាយាមទប់ស្មារតីឲ្យបាននឹងន ស្រែកឧទានយ៉ាងម៉ឺងម៉ាត់ ៖

–" មុននឹងអញស្លាប់, អញត្រូវតែសម្លាប់ពួកអាអស់ឯងឲ្យបានយ៉ាងតិច ៣០ នាក់ ! "

ចាប៉ុណ្ណោះ, កាំភ្លើងរបស់នាងក៏ព្រួសគ្រាប់ ប៉ុង ! ប៉ុង ! ទាល់តែអស់ ៤ គ្រាប់ ជាលំដាប់លំដោយ ...

ប្រហែលដោយមកពីចុកខ្ទាំងពេកទ្រាំមិនបាន ទើបនាងក្រោកឡើងទ្រេតទ្រោត រត់សំដៅទៅរកលោកគ្រូ សារុន ហើយស្រែកប្រាប់គាត់ដោយគ្មានតក់ស្លុត ៖

–" លោកគ្រូ ! លោកគ្រូ ! ខ្ញុំត្រូវគ្រាប់ហើយ... "

www.elibraryofcambodia.org

លោកគ្រូ សារុន ភ្ញាក់ព្រើតក្រឡេកមើលឃើញនាងមានសភាពស្ញាំងប្រញាប់សួរ ៖

-" ត្រូវត្រង់ណា មាយ ? "

នាងគ្រវីក្បាល ៖

-" មិនដឹងត្រង់ណាទេលោកគ្រូ, មាយចុកណាស់ ! "

លោកគ្រូ សារុន ភ័យស្លុត, ដាក់កាំភ្លើងចុះចាប់បង្វិលខ្លួននាងឡើងឃើញខោចអាវហើយខ្លួនចូលទៅក្នុងសាច់ជ្រៅមានទំហំប៉ុនកំប៉ុងទឹកដោះគោ ព្រមទាំងឈាមហូរហោចហើម ។ ឃើញភ្លាម, គាត់ប្រហោងពោះធ្លុងប្រញាប់លើកនាងដាក់ចូលក្នុងលេណដ្ឋានទាំងប្រាប់ ៖

-" មាយដេកទៅ, ឯងត្រូវរបួសធ្ងន់ណាស់ ! មិនអីទេចាំលោកគ្រូទៅជម្រាបលោកមេបញ្ជាការ ឲ្យទូរស័ព្ទទៅហៅអំប៊ុយឡង់មក ! "

នាង ឡៀប-វណ្ណដារ៉ា ញញឹមយ៉ាងស្លូតបាត់ ៖

-" លោកគ្រូ... កុំឲ្យលំបាកអី ! ... មាយមិនអីទេ កុំគិតពីខ្ញុំ ទុកខ្ញុំនៅទីនេះហើយ, លោកគ្រូ ... "

-" ឯងកុំនិយាយច្រើន ! .. ឯងទំរប់ស្មារតីឡើង ... "

មានតែវាចាតែប៉ុណ្ណោះ, គាត់ស្ទុះកញ្ឆក់កាំភ្លើងរត់ទាំងនៃកាត់គ្រាប់កាំភ្លើងដែលហើរប្រសាចចូលទៅការិយាល័យ ដើម្បីទូរស័ព្ទទៅកាន់មន្ទីរពេទ្យ ឲ្យគេយករថយន្តមកដឹកអ្នកជម្ងឺ ។

នៅកន្លែងប្រយុទ្ធ, ស្នូរកាំភ្លើងនៅតែផ្ទុះខ្ទាំងក្ទាវដដែល ។ ក្នុងខណៈ កញ្ញា ឡៀប វណ្ណដារ៉ា ត្រូវគ្រាប់រ៉ុក្កែតនោះ លោកសក្តិមួយម្នាក់ក្រឡេកទៅឃើញអាយៀកកុងទាំងប្រាំ កំពុងកាក់បីនរបស់គាត់រៈមួយប្រាវ... ត្រូវម៉ូតូខាងក្រោយមានធ្លាក់ពីរនាក់ដិះដួលប្រួសស្លាប់ទៅ ។ អាបីនាក់ខាងមុខឃើញគូកនវាស្លាប់ ក៏បញ្ឈប់ជនិះរត់កាត់គ្រាប់យកទៀបដែក (Grenade) បម្រុងទៅដាក់ពីក្រោមខ្នោចធ្លាក់ ។ តែលោកសក្តិមួយរៈមួយប្រាវទៀតត្រូវអាពីរនាក់ ដែលមានអាម្នាក់ជាអ្នកបាញ់រ៉ុក្កែតត្រូវនាង ឡៀប វណ្ណដារ៉ា បណ្តាលឲ្យវាស្លាប់មួយរំពេចនៅកណ្តាលថ្នូកឈាមដ៏ល្អចល្អឹម ។

អាម្នាក់ទៀតត្រូវមួយគ្រាប់ចំភ្លៅ ក្រាបចុះទាំងត្រចៀកស ទំលូនស្រប៉ាបទាំងរកអាចម៍ដាក់ទោ ទៅខាងចិញ្ចើមថ្នល់បាត់ទៅ ។ លោកសក្តិមួយច្រកគ្រាប់សាជាថ្មីផ្គងរង់ចាំប្រហារសត្រូវម្តងទៀត ។

ល្បឿន-កុំផា និង ល្បឿន-ផល្ល៊ីន ដឹងថាមិត្តនារីរបស់នាងត្រូវគ្រាប់ ក៏បាញ់ដក ខ្លួនថយលូនសំដៅទៅកាន់លេណដ្ឋានដែលមិត្តនាងគេង ។

ល្បឿន-កុំផា ត្រកងអ្នករបួសឡើងក្នុងហត្ថា ទាំងសួរដោយក្ដីបារម្ភ ៖

-" យ៉ាងម៉េចហើយ មាយ ? "

កញ្ញា ឡៅ-វណ្ណដារ៉ា គ្មានថ្ងូរមួយហ៊ឺះឡើយ ។ នាងព្យាយាមទប់ទល់នឹងការ ឈឺចាប់ទាំងពោល ៖

-" បងមិនដឹងត្រូវត្រង់ណាទេ, តែបងចុកខ្លួនណាស់ ! "

នាងដកដង្ហើមមួយៗ យ៉ាងវែងមានសភាពតឹងតែងពន់ពេក, រួចបន្ត ៖

-" បងហាក់ដូចជាគ្មានសង្ឃឹមថា បងបានជួបមិត្តកក្កិទាំងអស់ទៀតឡើយ... បងចុកណាស់... មិត្តយើងទាំងអស់គេមិនអីទេឬ ? "

ល្បឿន-កុំផា ឆ្លើយរួសរាន់ ៖

-" មិត្តយើងអត់មានអីទេ... តែពួកអាយៀកកុងស្លាប់ច្រើនណាស់, ពួកវាមិន អាចវាយបំបែកពួកយើងបានទេ ! "

ឮប្រយោគនេះ, នាង វណ្ណដារ៉ា ហាក់ដូចជាមានដង្ហើមធូរស្រាល, ទំញញឹម ដែលជាស្នើញញឹមដ៏អស់សង្ឃឹមក្នុងជីវិតរបស់នាង ។

-" បងអរណាស់ ! " នាងពោល ។ "ពួកយើងប្រយុទ្ធឡើងកុំដកខ្លួនថយឲ្យ សោះ, កុំឲ្យពួកវាមកយកទឹកដីយើងបានឡើយ... អាផា ! អាលីន !... ឯងត្រូវតែមាន សេចក្ដីក្លាហានជាចាំបាច់... ត្រូវតាំងស្មារតីឲ្យរឹងប៉ឹង ទើបសមជាកូនខ្មែរ... "

ល្បឿន-កុំផា ជួយតែទ្រង់មិត្តនារីយើង ព្រមទាំងបន្ទឺ ៖

-" មាយ កុំទំនិយាយច្រើនពេក ! "

មិត្តនារីញញឹមបន្តិច ជាមួយសម្ដីយ៉ាងខ្សោះខ្សាយ ៖

-"យើងត្រូវស្រឡាញ់ទឹកដីយើងជាដាច់ខាត... ទឹកដីដ៏មានតម្លៃមិនស្មើនឹងជីវិត បងម្នាក់ទេ ហើយក៏មិនស្មើជីវិតនរណាម្នាក់ឡើយ យើងជាអ្នករស់នៅក្នុងសម័យនេះ ត្រូវធ្វើយ៉ាងណាដើម្បីរក្សាបូរណភាពទឹកដីយើងកុំឲ្យបាត់បង់សូម្បីបន្តិចឡើយ... "

ស្នូរគ្រាប់រ៉ុក្កែតផ្ទុះមួយគ្រាប់នៅក្បែរវាលបាល់ទោះ ក្នុង ធ្វើឲ្យដាច់សម្ដីនាងតែ ប៉ុណ្ណោះ ។

កញ្ញាឡៅ-វណ្ណដារ៉ា, ថ្វីបើមានរបួសធ្ងន់យ៉ាងនេះហើយ ក៏ប៉ុន្តែចិត្តគំនិតរបស់ នាងគួចវិលវល់នឹងបញ្ហាជាតិជានិច្ច ។ ក្រៅពីនេះ នាងគួចនឹកទៅគ្រួសារ, ចំពោះម្ដាយ

www.elibraryofcambodia.org

ដែលកំពុងមានជំងឺ, ចំពោះឪពុកដ៏ជាទីគោរព និងចំពោះប្អូនតូចៗ មិនទាន់ដឹងក្តី ។ ដូច្នេះហើយបានជានាងយកប៊ិចចុចមួយហុចទៅឲ្យមិត្តនារីរបស់នាង និងពិលតូចមានសណ្ឋានដូចស៊ីឡូ ដោយផ្តាំថា ៖

-" អាផា... ឯងយកប៊ិចចុចនិងពិលនេះចែកប្អូនទី១ និងទី២បងម្នាក់មួយ... ជាពិសេសផ្តាំវាថា អត់ពីបងទៅឲ្យវាថែរក្សាប្អូនតូចៗ ផង... ម្យ៉ាងទៀតឲ្យវាមើលម៉ាក់ផង... "

លឿង-វ៉ាផា ងក់ក្បាលឆ្លើយ ៖

-" មិនអីទេមាយចាំខ្ញុំយកទៅឲ្យ.. មាយ... "

ឡៀប-វណ្ណដារ៉ា បន្ថែមទៅទៀត ៖

-" អាផា ឯងជម្រាបម៉ាក់បងថា បើ មាយ ស្លាប់ទៅ សូមឲ្យម៉ាក់ធ្វើបុណ្យបញ្ជូនកុសលឲ្យមាយផង ! ... ហើយផ្តាំគាត់ថា មាយលាម៉ាក់ហើយ ! ...

នាងនិយាយទាំងទឹកមុខស្រពាប់ស្រពោនជាហេតុធ្វើឲ្យមិត្តនាងខ្វាចផ្សាពន់ប្រមាណ ។

លឿង-វ៉ាផា ពោលទាំងបារម្ភ ៖

-" មាយ កុំនិយាយដូច្នោះ, មាយមិនស្លាប់ទេ បន្តិចទៀតឡានពេទ្យមកដល់ហើយ ! ... "

-" ជម្រាបម៉ាក់ផងថាកុំឲ្យសោកស្តាយកូនពេក, កូនស្លាប់នេះ គឺស្លាប់ដើម្បីជាតិ ។ មាយ ពេញចិត្តស្លាប់ណាស់ ស្លាប់ដោយរបៀបនេះមានន័យថា ខ្មែរមិនព្រមចុះចាញ់អាយៀកកុងមួយជំហានឡើយ ! "

លោកសក្តិមួយលូនមកជិតលេណដ្ឋាន អើតក្បាលមកប្រុងនិយាយ ស្រាប់តែ ... គាត់ ! គាត់ ! គាត់ !....

គ្រាប់រះប្រសាចក្បែរៗ ខ្លួនគាត់ បណ្តាលឲ្យគាត់ប្រមៀលខ្លួនទៅអែបក្រាបគល់ចំបក់ លើកកាំភ្លើងបាញ់រះប្រាវ ! ប្រាវ !... តបទៅវិញ ទាល់តែស្ងាត់ស្ងៀម ។ គាត់អ៊ើ ៖

-" យើ, ពួកអាចោលម្សៀត ទាល់តែអស់មួយបង់ទើបស្ងាត់ ! "

គាត់លូនមកកើម! ទៀត ។ គ្រាប់ហើរបញ្ឆិតៗ ក្បាលរហើយសក់ ។ តែគាត់ព្យាយាមលូនរហូតដល់លេណដ្ឋានមិត្តនារីកំសត់យើងដោយពោលសួរ ៖

-" យ៉ាងម៉េចហើយមាយ ? "

www.elibraryofcambodia.org

លឿង-កុំផា នៅទីនោះឆ្លើយជំនួស ៖

-" គាត់ត្រូវរបួសធ្ងន់ណាស់លោកគ្រូ ! ត្រូវអេក្វារ៉ុក្កតចំខ្លួនតែម្តង ! "

លោកសក្តិមួយចុះទៅពិនិត្យមើលហើយសួរ ៖

-" មាននរណាគេឡូហួនទៅហៅឡានពេទ្យហើយឬនៅ? "

-" ចាំ៎ ! លោកគ្រូ សារុន ទៅហើយ ! " កុំផា ឆ្លើយ, "តែមិនទាន់ឃើញមកវិញនៅឡើយ ! "

-" លោកគ្រូមិនដឹងសោះ, " លោកសក្តិមួយនិយាយ, "អត់ដឹងថាមាយត្រូវគ្រាប់គេ... តែអាដែលបាញ់មាយនោះ លោកគ្រូសងសឹកឲ្យហើយ សូមមាយកុំកយអី!

អ្នករងគ្រោះពុងផ្លោះ ហាក់ដូចជាមានសេចក្តីក្លាហានទ្វេឡើង ។ នាងឮថាអ្នកដែលបាញ់នាងត្រូវបានអ្នករួមអាវុធប្រហារ, ស្រស់នារីបានស្ងប់មួយរយៈ ។ នាងញញឹមតបទៅលោកសក្តិមួយ ៖

-"អរគុណលោកគ្រូហើយ! សូមឲ្យពួកយើងឈ្នះលើពួកសត្រូវជាស្ថាពរចុះ!"

លោកសក្តិមួយលូនថយក្រោយ រត់សំដៅទៅការិយាល័យ ឃើញលោកគ្រូសារុន កំពុងតែរវៃទូរស័ព្ទញាប់ដៃទាំងញ័រខ្លួន ។ លោកអនុសេនិយត្រីសួរស្មោជាបន្ទាន់ ៖

-" យ៉ាងម៉េចហើយលោកគ្រូ ? "

លោកគ្រូ សារុន ដាក់ទូរស័ព្ទចុះវិញហើយងាកមកឆ្លើយទាំងសភាពអស់សង្ឃឹម៖

-" លោកវរសេនិយត្រី ទៀប បែន មានប្រសាសន៍ថា អំពីយឡង់និងរថយន្តបានចេញទៅឯកាលកបាល់ហោះអស់ហើយ ព្រោះពួកអាយៀកកុងវាយប្រហារនៅទីនោះខ្លាំងក្លាណាស់... ប៉ុន្តែលោកចិត្តបានដែរបានឲ្យរថយន្តហ្ស៊ីបផ្ទាល់ខ្លួនរបស់លោកមក ។ ខ្ញុំចាំយូរណាស់ហើយជិតមួយម៉ោងកន្លះទៅហើយមិនទាន់ឃើញមក ខ្ញុំក៏ទូរ-ស័ព្ទម្តងទៀត ស្រាប់តែអត់ឮសោះតែម្តង ! "

លោកសក្តិមួយស្ទុះទៅលើកទូរស័ព្ទរវៃម្តងវិញ ។ តែជាមួយគ្នានោះសម្លេងមួយបន្លឺឡើង ៖

-" ឡានពួកយើងទេ ! ៗ ! .... "

អ្នកទាំងពីរស្ទុះចេញទៅ ឃើញរថយន្តហ្ស៊ីបបើកយ៉ាងលឿនចូលមក ដែលមានឃើញគ្រាប់របស់សត្រូវហើរស្រោចពីក្រោយ ។

សូមបញ្ជាក់បន្ថែមថា ពួកអាយៀកកុងពេលវាយប្រហារនោះ បានយករថយន្តទេសចរមកបន្ទំ ដែលវាលួចពីបឹងហ្គាលូរមក ។ តែមិត្តយើងវាងវៃណាស់មិនចាញ់បញ្ឆោតពួកវាឡើយ បាញ់ប្រហារមិនឲ្យវាឆ្មក់ចូលមកវិទ្យាល័យបានតាមអំពើចិត្ត ។

អ្នកបើកបររថយន្តហ្ស៊ីប ចុះពីរថយន្តហើយទៅគំនាប់លោកមេបញ្ជាការព្រមទាំងបន្ថី ៖

–" លោកវរសេនិយត្រីបានបញ្ជាឲ្យខ្ញុំដឹកអ្នករបួសទៅមន្ទីរពេទ្យទាន ! "

អ្នកបើកបរបានបញ្ជាក់ថាហេតុដែលយឺតយូរដូច្នេះ មកពីពួកយៀកកុងវាយដកទ័ពពីវាលកបាល់ហោះ មកបំបែកជាពីរក្រុម, វាយប្រហារទៅលើសាលសន្និសីទគ្រងពាក់កណ្តាលផ្លូវផង និងមកវិទ្យាល័យផង ។ ដូច្នេះហើយបានជាមានការលំបាកបំផុត ។ ការដែលគាត់បើកឡានមកនេះ គឺប្រថុយប្រហានរត់កាត់មុខគ្រាប់ស្រោចដូចគ្រាប់ភ្លៀង ។

ម៉ោងប្រាំមួយនិងសាមសិបនាទីព្រឹក ។ ព្រះអាទិត្យរះផុតពីបន្ទាត់ជើងមេឃហោលស្មើប្រាលប្រវ៉ាត់ ធ្វើឲ្យពិភពលោកទាំងមូលប្រាសចាកនូវសភាពងងឹត ជ្រះស្រឡះស្មើ ។

រថយន្តបានដឹកកញ្ញា ឡៀប-វណ្ណដារ៉ា ត្រូវរបួសធ្ងន់និងយុវជន ឆួយ-សារឿនដែលមានរបួសស្រាលទៅកាន់មន្ទីរពេទ្យ, ក្រោមស្នាក់ភ្លើងលាន់ព្ញុំខ្ទរខ្ទាតួរឲ្យស្លុត...

... ចាប់ពីនាងត្រូវរបួសរហូតទៅដល់មន្ទីរពេទ្យ, កញ្ញាឡៀប-វណ្ណដារ៉ានិយាយប៉ប៉ាច់ប៉ប៉ោច ផ្តែផ្តាំគេពីនេះពីនោះគ្មានតក់ស្លុតនឹងមរណភ័យរបស់នាងសោះឡើយ។ នាងកាន់តែបុកចាប់យ៉ាងខ្លាំង, ឈាមហូរកាន់តែច្រើន ទាល់តែខ្សោះអស់ពីខ្លួន ។

នៅមន្ទីរពេទ្យ, លោកវេជ្ជបណ្ឌិតទំនុះខ្នែងព្យាបាលដែរ តែមុខរបួសនាងធ្ងន់ពេក ធ្វើឲ្យអ្នកជំងឺអស់សង្ឃឹមលើងចេង ។ នាងដោះចិញ្ចៀនដែលពាក់នៅដៃ, ខ្សែកមួយខ្សែ និងកូនកន្សែងមួយ ព្រមទាំងរូបថតមួយសន្លឹក (រូបភាពកាលនាងថតរួមជាមួយមិត្តភក្តិដទៃទៀត ស្លៀកសារុងនៅក្នុងវិទ្យាល័យក្រោយពេលរៀបចំដណ្តាំស្វា នៅក្នុងកន្សែងមានប្រាក់ចំនួនបីរយខ្ទម្ភមួយរៀល ។ នាងប្រគល់វត្ថុទាំងអស់នេះទៅលោកគ្រូដោយផ្តាំថា ៖

–" សូមលោកគ្រូទុករបស់នេះជូនម៉ាក់ខ្ញុំផង ហើយផ្ដាំគាត់ថា មាយជម្រាបលាម៉ាក់ប៉ាហើយ ... មាយមិនអាចរស់ទេព្រោះចុកណាស់ ... សូមឲ្យម៉ាក់ប៉ាធ្វើបុណ្យបញ្ជូនកុសលឲ្យមាយ ... "

ផ្ដាំផ្ញើចប់ស្រួលបួលហើយ, គឺនៅវេលាម៉ោងប្រាំបួនព្រឹកគត់, វិញ្ញាណក្ខន្ធដ៏អភ័ព្វរបស់នាង ឡៀប-វណ្ណដារ៉ា ក៏លាចាកលោកនេះទាំងសោកស្ដាយ ។ នាងស្លាប់ហើយ ! ស្លាប់ក្រោមស្នូរកាំភ្លើងយ៉ាងខ្ទ័រខ្ទា !... ជាស្ត្រីខ្មែរទីមួយដែលបានស្លាប់នៅលើសមរភូមិ ។

ថ្វីត្បិតតែជីវិតនាងផុតរលត់ទៅមែន តែកេរ្តិ៍ឈ្មោះនាងនៅគង់វង្សដដែល... ឈ្មោះនាងស្ថិតក្នុងអារម្មណ៍នៃកូនខ្មែរគ្រប់រូប ។

ព្រះទិនករចែងចាំងមកលើមន្ទីរពេទ្យសៀមរាបអស់កាលដ៏យូរ ទើបមេឃមីរស្រទុំប្រកបដោយពពកក្រាស់ៗ ហាក់បីដូចជាជួយស្រណោះជីវិតដ៏ថ្លៃថ្លានៃកុលធីតាខ្មែរ ដែលបានបាត់បង់ទៅដោយសារសេចក្ដីស្នេហាទឹកដីមាតុភូមិ ។

ខណៈនោះ, សភាពនារីម្នាក់បើកទ្វារបន្ទប់ពេទ្យចូលទៅ ។ សពនាង ឡៀប-វណ្ណដារ៉ា ត្រូវគេគ្របសំពត់សជាស្រេច ។ នាងនោះឃើញភ្លាម ស្ទុះចូលទៅឱបសាកសពទ្រហោយំយ៉ាងខ្លោចផ្សា ។ ស្រីនេះមិនគឺនរណាក្រៅពីនាង វិទ្ធី-យុទ្ធី ឡើយ ។ នាងនៅដេកពេទ្យ, ដល់ឮដំណឹងថាមិត្តនារីនាងស្លាប់ដោយស្នាដៃយៀកកុងក្ដៅក្រហាយជាខ្លាំង, ស្ទុះចូលទៅបន្ទប់ទាំងស្លុតចិត្ត ៖

–" វណ្ណដារ៉ា... វណ្ណដារ៉ាមិត្រសម្លាញ់ ! មិត្តស្លាប់ហើយ... មិត្តស្លាប់យ៉ាងសែនវេទនា... ស្លាប់ដោយស្នាដៃយៀកកុង... មិត្តអើយ, ខ្ញុំចុកចាប់ណាស់ ! ខ្ញុំចុកចាប់ណាស់ !... មិត្តស្លាប់ហើយ កេរ្តិ៍ឈ្មោះមិត្តនៅក្រអូបដដែល... មិត្ត... ខ្ញុំមិនអាចបំភ្លេចមិត្តបានទេ... យើងរស់នៅ, យើងនៅតស៊ូសងឈាមមិត្ត... សូមឲ្យព្រលឹងមិត្តទៅកាន់សុគតិភពចុះ ហើយវិញ្ញាណក្ខន្ធមិត្តដែលមានដួងចិត្តស្នេហាទឹកដីដ៏ជាក់ច្បាស់នោះ ថែរក្សាយើងរាល់គ្នាដែលសងឈាមឲ្យមិត្តផង ព្រមទាំងសូមឲ្យបំផ្លាញអាយៀកកុងឲ្យវិនាសហិនហោចទៅ ... "

វិទ្ធី-យុទ្ធី យំបោកខ្លួនគ្រេងៗ នៅក្បែរសាកសពអត់វិញ្ញាណនៃកល្យាណមិត្តនារីរបស់នាង ។ ចំណែកអ្នកនៅក្នុងបន្ទប់នោះទាំងប៉ុន្មានក៏ពុំអាចទប់ទឹកនេត្រាបានឡើយ ។

www.elibraryofcambodia.org

បរិយាកាសក្នុងបន្ទប់ធ្លាក់ក្នុងសភាពខ្មោចស្ងាត់យ៉ាងខ្លាំង ។ គេទាំងឡាយមានវិយោគទុក្ខផង មានសេចក្ដីក្ដៅក្រហាយចំពោះអំពើព្រៃផ្សៃរបស់អាចោរយៀកកុងផង....

* *

*

ដំណឹងមរណភាពនៃនាង ឡេង-វណ្ណដាក់ បានលេចឮទៅដល់អ្នកស្រី ប៉ិន-បូប៉ែឡាំង ជាម្ដាយ ធ្វើឲ្យគាត់មិនអាចទប់ទល់នឹងវិប្បយោគបានឡើយ ។ គាត់ស្រែកទ្រហោយំខ្លាំងៗ គួរឲ្យអាណោចអធម្ម ។ ជាការធម្មតាទេ, ម្ដាយនិងកូនតែងមានការស្រលាញ់អាណិតសោកស្ដាយយ៉ាងនេះឯងហើយ ។

អ្នកស្រីក៏ធ្វើដំណើរទៅមន្ទីរពេទ្យជាបន្ទាន់ ហើយសុំលោកវេជ្ជបណ្ឌិតចូលមើលសពកូន ។ តែលោកវេជ្ជបណ្ឌិតឃាត់ ព្រមទាំងពោលពាក្យទន់ភ្លន់មកកាន់គាត់៖

-" អ្នកគ្រូ !.. ស្ដាយណាស់, ខ្ញុំស្គាល់ទំហំទុក្ខអ្នកគ្រូហើយ ប៉ុន្តែខ្ញុំមិនអាចជូនអ្នកគ្រូតាមសេចក្ដីសុំបានទេ ព្រោះកូនស្រីអ្នកគ្រូគេបញ្ចូលក្នុងសាលតម្កល់សពផុតហើយ ។ នៅទីនោះមិនមែនមានតែកូនអ្នកគ្រូម្នាក់ប៉ុណ្ណោះទេ មានយុទ្ធជនយើងច្រើនដែរ ដែលបានស្លាប់ដោយវេទនាបំផុត ជឺមានឈាមគួរឲ្យអាណោចអធម្ម... ខ្ញុំដឹងថាអ្នកគ្រូមានរោគខ្សោយបេះដូង មិនអាចទប់ទល់នៅចំពោះភាពដ៏សែនវេទនានោះបានឡើយ !"

គាត់បង្អង់បន្តិច ទើបបន្តទៅទៀត ៖

-" ចាំដល់គេយកសពចេញទៅបូជា អ្នកគ្រូអាចមើលមុខកូនបាន ! "

អ្នកគ្រូ ប៉ែឡាំងទ្រហោយំឡើង ៖

-" លោកដុកទ័រអើយ ! ខ្ញុំស្ដាយណាស់ ដោយមិនបានទាន់ជង្គ្រឹមកូន... ខ្ញុំចង់ឃើញមុខកូនខ្ញុំណាស់ !... កូនម្ដាយ ! មាយកូនម្ដាយ, កូនស្លាប់ចោលម្ដាយហើយ !"

ទឹកនេត្រាហូរចេញច្រោកមកគួរលន្លោចចិត្តក្រៃលែង ។ លោកវេជ្ជបណ្ឌិតបានប្រគល់វត្ថុដែលកញ្ញា ឡេង-វណ្ណដាក់ បានផ្ញើទៅឲ្យម្ដាយនាងព្រមទាំងពាក្យបណ្ដាំផ្សេងៗ ផង ។

នៅពេលគេដឹកសាកសពវីរនារី ឡេង-វណ្ណដាក់ ទៅដាក់លើគំនរឧសដើម្បីបូជា, អ្នកស្រីប៉ែឡាំង ជាមាតាស្ទុះបោកខ្លួននឹងបក្តារមឈូសបុត្រីសម្លាញ់ចិត្ត ទ្រហោរ

www.elibraryofcambodia.org

យំគួរឲ្យអាណិតអាសូរក្រៃលែង ។ គាត់លើកសាកសពកូនឱបហើយថើបព្រមទាំងបន្ទីទំនួញខ្លោចផ្សា ៖

-" កូនម្ដាយ !... មុខកូននៅស្រស់ញញឹម !... ក្លិនទឹកអប់របស់កូននៅក្រអូបនៅឡើយ... មិនគួរកូនស្លាប់ចោលម្ដាយសោះ... មាយកូនម្ដាយ... កូនស្លាប់ដោយវេទនា... មាយ ! ... "

លោកគ្រូអាចារ្យអញ្ជើញមកជិត មានប្រសាសន៍លួងលោម ៖

-"អ្នកស្រី កុំសោយសោកពេក... ខ្ញុំឃើញអ្នកស្រីស្រឡាញ់កូនណាស់... អ្នកស្រីអើយ! ជីវិតអនត្តមិនទៀងទាត់ កើតហើយរមែងស្លាប់ទៅវិញមិនអាចជៀសផុត... នាងស្លាប់ទៅហើយគឺបានសេចក្ដីថាទួងផុតនូវទុក្ខកង្វល់ទាំងពួង...

អ្នកស្រីជាភរិយាលោក ឡៀប-ស៊ីម ងើបក្រឡួដក់ដាមដោយទឹកភ្នែករហាមបន្ទីម៉ឹងម៉ាត់ ៖

-" គ្រូអាចារ្យ, ខ្ញុំមិនស្ដាយប៉ុន្មានទេ ព្រោះកូនខ្ញុំស្លាប់ដើម្បីជាតិ ដើម្បីទឹកដី... ខ្ញុំអត់តូចចិត្តទេលោកគ្រូអាចារ្យ, កូនខ្ញុំស្លាប់ដោយគន្លងធម៌ ស្លាប់នៅលើសមរភូមិផុយពីសកាពស្ដ្រីខ្វះ ដែលស្លាប់ព្រោះសេចក្ដីស្នេហា ! ខ្ញុំរីករាយណាស់ដោយកូនខ្ញុំស្លាប់ដើម្បីជាតិ... តែលោកគ្រូអាចារ្យអើយ, កូនខ្ញុំមិនដែលធ្វើអ្វីឲ្យខ្ញុំឈ្លើសចិត្តឡើយ គេស្លាប់ទៅហាក់ដូចជាមិនទាន់ស្លាប់សោះ... "

គាត់យំកាន់តែខ្លាំង ធ្វើឲ្យបរិយាកាសធ្លាក់ចុះផុនដាបជាស្ពាពរ ។ គាត់បន្ទីបន្ថែម ៖

-" មាយ, កូនធ្លាប់និយាយប្រាប់ម្ដាយថា កូនសុខចិត្តស្លាប់កាំភ្លើងនៅដៃ, ឥឡូវកូនស្លាប់កាំភ្លើងនៅដៃមែន, ស្លាប់ក្រោមទង់ជាតិ !... ក្លិនទឹកអប់កូននៅក្រអូបកាយ... នៅថ្មីៗ ស្រស់ៗ... "

អ្នកទាំងអស់ គ្មាននរណាម្នាក់អាចទប់ទឹកភ្នែកមិនឲ្យហូរបានឡើយ ។

ស្នូរកាំភ្លើងនៅតែឮលាន់ឡើងគួរឲ្យព្រឺក្បាល ។ ជាបទភ្លេងខ្លងខែកដែលជន្ដូនព្រលឹងនាង ឡៀប-វណ្ណដាក់ វីរនារីស្នេហាជាតិទៅកាន់បរលោកដោយស្ងប់ស្ងៀម...

... ថ្ងៃនោះ, គ្រាប់ហើរប្រសាចចុះប្រសាចឡើងដូចគ្រាប់ភ្លៀង ស្រោចសន្ធាប់ពេញទាំងទីក្រុងសៀមរាប ។ គ្មាននរណាម្នាក់ហ៊ានអើតចេញមកក្រៅឡើយ ។

លោក ឡៀប-ស៊ីម កំជាប់រវល់នៅយាមឯការិយាល័យ ។ អ្នកគ្រូបែរឡាំងនឹងក្រសោបកូនតូចៗ ក្នុងផ្ទះ ។ ស្នាមទឹកភ្នែកសោកសង្រេងនៅតែហូរឥតទាន់ឈប់នៅ

www.elibraryofcambodia.org

ឡើយ ។ មានតែគាត់ម្នាក់ប៉ុណ្ណោះទេដែលបានឃើញមុខកូន ឯលោកប្រុសមិនទាន់ដឹងថាកូនស្លាប់ផង ។

ពេលនោះ, សពនាង វណ្ណដារ៉ា ហៅ មាយ ទម្រាំតែនឹងបានបូជាទាល់តែល្ងាច ព្រោះគ្រាប់បាញ់រះ តាត់ ! តាត់ ! តាត់.... ត្រឹមៗ ចង្កេះ មិនមាននរណាហ៊ានទៅជូនភ្លើងនាងឡើយ ។ លោក ជា-ឆាង, លេខាធិការសាលាខេត្តសៀមរាប, ត្រូវជាបងថ្លៃជីដូនមួយរបស់សពនាង វណ្ណដារ៉ា ហើយត្រូវជាក្មួយអ្នកស្រី បានដាច់ចិត្តលួចគាត់គ្រាប់យកភ្លើងទៅបូជាសពប្អូន ក្រោមស្នូរកាំភ្លើងលាន់គួរឲ្យខ្លាច ។

ហេតុតែស្រឡាញ់កូនខ្លាំងពេក, អ្នកស្រីបែរឡាំងនៅផ្ទះមិនសុខឡើយ ស៊ុះរត់ទាំងសារុងទៅកាន់ទីវត្តម្តងទៀត ដើម្បីមើលមុខកូនឲ្យច្បាស់ជាចុងក្រោយ ។ គាត់មិនអស់ចិត្តទេ ហាក់ដូចជាកូនគាត់មិនទាន់ស្លាប់ដូច្នោះ ។ គ្រាន់តែចូលផុតផ្លូវថ្នល់បន្តិច, កងពលខាងយើងដែលចេញអន្តរាគមន៍ភ័យបណ្តាញខ្លាំង ឃាត់គាត់ដោយប្រាប់ថា៖

-" អ្នកស្រីទៅមិនបានទេ, គ្រាប់ច្រើនណាស់ក្រែងមានគ្រោះថ្នាក់ សូមអ្នកស្រីថយក្រោយរកទីជម្រកទៅ !... "

តែគាត់បានកាត់ចិត្តថា ប្រសិនត្រូវគ្រាប់ស្លាប់ក៏ស្លាប់ទៅចុះឲ្យតែបានឃើញមុខបុត្រីពន្លកចិត្ត ។ គាត់ក៏ប្រថុយរត់ទៅមុខទៀតក្រោមសរសៃគ្រាប់ហោះ វីវ ! វីវ !..

ពុទ្ធោ !... ទៅដល់ក្បាលស្ពាន, លោក ជា-ឆាង រត់ឱនៗ កាន់កោដិមកជាមួយប្រគល់ទៅជូនអ្នកស្រីជាម្តាយមីងព្រមទាំងជម្រាបថា ៖

-" មីង, ខ្ញុំបានបូជាសពមាយហើយ ! នេះ, ធាតុមាយ ! "

អ្នកស្រីស្ទុតស្មារតីស្ទើរទប់ជន្លង់ដួល យកកោដិមកឱបនឹងដើមទ្រូងទាំងស្រែកទ្រហោយំ....

ស្នូរកាំភ្លើង នៅតែលាន់ឮពេញទាំងផ្ទៃខេត្តសៀមរាបទាំងមូលឥតទាន់ស្ងប់នៅឡើយ ។

* *
*

រំលងប៉ុន្មានថ្ងៃក្រោយមកទៀត, ភ្លៀងធ្លាក់ខ្លោកខ្លាំប្រថពីៗ រិទ្ធិ-យុទ្ធារី អង្គុកពេកកន្ទង ។ នាងអន្ទះសារនៅមិនសុខ បានសុំលោកវេជ្ជបណ្ឌិតចេញពីមន្ទីរពេទ្យ

www.elibraryofcambodia.org

បំណងចូលធ្វើកុម្ម៉ង់ផ្កាតែម្ដង ។ លោកវេជ្ជបណ្ឌិតមិនអាចឃាត់នាងបានឡើយ ហើយនាងក៏ជាសះស្បើយដែរ, ទើបលោកឲ្យនាងចេញទៅ...

កញ្ញា យុទ្ធារី ទើបឈានផុតពីក្លោងទ្វារ, ស្រាប់តែសម្លេងមួយស្រែកឃាត់ដំណើរនាង ៖

-" អារី... អារីឈប់សិន... ឈប់សិនខ្ញុំមានការមួយ.... "

យុទ្ធារីងាកទៅឃើញអ្នកគ្រូពេទ្យម្នាក់ត្រូវជាមិត្តនឹងនាង រត់ត្រហបមករកទាំងសួរបន្ត ៖

-" ឯងគិតទៅណាហ្នឹង ? "

-" គ្នាគិតទៅរកសុំគេធ្វើកុម្ម៉ង់ផ្កាហើយ ! "

អ្នកគ្រូពេទ្យញញឹមទាំងទឹកមុខអាថ៌កំបាំង ៖

-" គ្នាបានទទួលបណ្ដាំពីវណ្ណដារ៉ា ជាមិត្តរបស់ឯងជាចុងក្រោយមុននឹងនាងស្លាប់ទៅ ... "

ពុទ្ធោះ វិទ្ធិ-យុទ្ធារី សួរប្រញាប់ ៖

-" វណ្ណដារ៉ា ផ្ដាំខ្ញុំថាម៉េច ?"

សំណួរមិនទាន់ចប់ស្រួលបួលផង ស្រាប់តែសម្លេងកាំភ្លើងលាន់ឮ តាត់! តាត់! តាត់!.... ឡើងរន្ថើង ។ វិទ្ធិ-យុទ្ធារី និងអ្នកគ្រូពេទ្យនាំគ្នាក្រាបព្រើប ហើយលូនយ៉ាងលឿនចូលទៅទាំងក្នុងបរិវេណមន្ទីរពេទ្យវិញ ។ ស្នូរកាំភ្លើងលាន់ជាប់គ្នាស្ទើររកពេលទំនេរគ្មាន មិនអាចឲ្យអ្នកទាំងពីររកឱកាសជជែកគ្នាបានឡើយ ។

គ្រានោះ, សម្លេងលោកវេជ្ជបណ្ឌិតស្រែកហៅអ្នកគ្រូពេទ្យ ដើម្បីឲ្យចូលទៅជួយធ្វើការវះកាត់អ្នកជំងឺទើបមកដល់ថ្មីៗ អ្នកគ្រូទៅជិតយុទ្ធារីពោលប្រាប់ ៖

-" វណ្ណដារ៉ា ប្រាប់ឲ្យឯងសងឈាមឲ្យនាងផង... នាងផ្ដាំច្រើនណាស់, ពេលខ្លីពេកមិនអាចឲ្យគ្នានិយាយពីបណ្ដាំនាងឲ្យចប់បាន... ណ្ហើយ, ចាំថ្ងៃក្រោយយើងជួបគ្នាទៀត សឹមគ្នាប្រាប់ពីបណ្ដាំ ឡៀប-វណ្ណដារ៉ា ដល់ឯង... គ្នាលាសិនហើយ !... "

រួចនាងលូនចេញទៅ ។ វិទ្ធិ-យុទ្ធារី រំភើបក្នុងចិត្តជាខ្លាំង ។ នាងបានបន្លឺក្នុងបំពង់កថា ៖

-" ខ្ញុំនឹងសងឈាមមិត្ត... សងឈាមមិត្តខ្ញុំ... ជាដាច់ខាត !... "

ពេលនោះ, វិទ្ធិ-យុទ្ធារី ហាក់ដូចបានឃើញស្រមោលនាង ឡៀប-វណ្ណដារ៉ា ផុសឡើងមានទឹកមុខញញឹមប៉ប្រិមព្រមទាំងបន្លឺសម្លេងឡាវៗ ៖

-" សង្ឃឹមឲ្យខ្ញុំផងមិត្ត ! សង្ឃឹមឲ្យខ្ញុំផង ! "

រិទ្ធិ-យុទ្ធារី ភ្ញាក់ព្រើត ស្រែកឧទាន ៖

-" វណ្ណដារ៉ា !... វណ្ណដារ៉ា !... មិត្តអើយ !... មិត្តស្លាប់មែនពិត ... តែខ្ញុំមិនអាចបំភ្លេចមិត្តបានទេ ... ខ្ញុំនឹងសង្ឃឹមចំពោះមិត្ត... មិត្តចាំចុះ !... "

ទឹកភ្នែកហូរហៀរ... ភ្លៀងក៏បង្អុរមកយ៉ាងខ្លាំង លាយជាមួយស្នូរគ្រាប់គគ្រឹកគគ្រេង ...

សង្ឃឹមមិត្តខ្ញុំ !!! ... សង្ឃឹមមិត្តខ្ញុំ !... ជាសក្ខីភាពនៃទឹកចិត្តយុទ្ធនារីខ្មែរតាមបណ្តាំនាង ឌៀប-វណ្ណដារ៉ា ... សង្ឃឹមមិត្តខ្ញុំ នឹងបង្ហាញពីសកម្មភាពនាង រិទ្ធិ-យុទ្ធារី បំពេញតាមបណ្តាំនាង ឌៀប-វណ្ណដារ៉ា យ៉ាងដាក់ស្តែង... តើបណ្តាំនាង ឌៀប-វណ្ណដារ៉ា មានន័យយ៉ាងណាខ្លះ ? សូមកុំភ្លេច ! សង្ឃឹមមិត្តខ្ញុំ ...

តើមិត្តនារី រិទ្ធិ-យុទ្ធារី មានល្បិចកលយ៉ាងណាក្នុងការសងសឹកសត្រូវជំនួសនាង ឌៀប-វណ្ណដារ៉ា, សូមមិត្តអ្នកអានតាមដានជាមួយអ្នកនិពន្ធ ក្នុងរឿង សង្ឃឹមមិត្តខ្ញុំ នឹងចេញផ្សាយនៅពេលឆាប់ៗ នេះ ...

" **សង្ឃឹមមិត្តខ្ញុំ !!!...** "

**　　**

**

www.elibraryofcambodia.org

## អនុស្សាវរីយ៍ (១)

ដោយសារគ្រាប់រ៉ុក្កែតរបស់ខ្មាំង ធ្លាក់មកចំកន្លែងពួកយើងច្រើនពេកបានជាមានបំណែកខ្លះខ្ទាតទៅត្រូវមិត្តយើងរបួសស្រាលចំនួន ១៧ នាក់ ។

.... ថ្វីត្បិតតែព្រះអាទិត្យបំភ្លឺលោកឡាស់ហើយក៏ដោយ ខ្មាំងក៏នៅតែបាញ់សម្រុកមករកយើងគ្រប់ទិសទី ។ ចំណែកមិត្តយើងនៅតែមានសេចក្តីក្លាហានបាញ់តទល់ខ្មាំងឥតទន់ដៃឡើយ ។ អ្នកខ្លះបាញ់, អ្នកខ្លះលូនទៅយកទឹកមកដាំបាយក្បែរលេណដ្ឋាន ។ ពេលបាយឆ្អិនគេទទួលទានបាយបណ្ដើរ ឃ្លាំចាំបាញ់ខ្មាំងបណ្ដើរ ឥតប្រហែសឡើយ ។

មេឃពេលនោះចួនរាំងចួនភ្លៀងខ្លោកខ្លាំ ។ ទឹកហូរចូលលេណដ្ឋានធ្វើឲ្យក្រុមយើងលំបាកក្រៃលែង ។ តែដោយទឹកចិត្តស្នេហាជាតិ ដោយស្អប់ខ្ពើមកម្ទេចខ្មាំងចេញពីទឹកដីមានឥទ្ធិពលខ្លាំងក្លាជាង ទើបក្រុមយើងនៅតែបន្តសេចក្ដីក្លាហានបាញ់ទប់ទល់ខ្មាំង យ៉ាងអង់អាចជានិច្ច ។ ជាសំណាងល្អ មានកងវរសេនាតូចប្រដេញទី ១១៥ នៃកងពលធ្មើងលេខ ១២ បានមកធ្វើអន្តរាគមន៍ជួយពួកយើងពីខាងមុខវិទ្យាល័យចាប់ពីម៉ោង ១១ ថ្ងៃត្រង់រហូតដល់ម៉ោង ១៧:០០ ។ ខ្មាំងបាញ់សម្រុកមកវិទ្យាល័យយើងពេញមួយថ្ងៃម្ដងទៀត តែឥតសំរេចចូលមិនចុះសោះ ។ នៅឱកាសនោះ, លោកវរសេនីយមេបញ្ជាការបញ្ជាឲ្យកងអនុសេនាធំលេខ ១ ក្នុងកងវរសេនាតូចយុវជនដែលត្រូវទៅធ្វើបាំងភាំងផ្លូវឲ្យចូលមកកាន់វិទ្យាល័យវិញ ដើម្បីជួយការពារឲ្យបានមុតមាំ ។

ខ្មាំងចង្រៃ ត្រូវបាញ់ពួកយើងពេញមួយយប់ទៀត ឥតឈប់ឈរឡើយ ។ ដោយអកុសលនៅរាត្រីនោះ, លោក ណុប-សារ៉ូវ សាស្ត្រាចារ្យនៅវិទ្យាល័យអង្គរ ជាមេបញ្ជាការនៃកងវរសេនាធំទី ៥, បានទទួលមរណភាពគួរឲ្យអាណិត និងលោក ណន-តាន់ មេបញ្ជាការរងនៃកងអនុសេនាធំទី ១ បានត្រូវរបួសធ្ងន់នៅឱកាសមិត្តយើងទាំងពីរនាក់នេះកំពុងបាញ់និងបញ្ជាក្រុមយ៉ាងក្លាហានបំផុត ។ ក្រៅពីនេះមានមិត្តយើងរបួសស្រាលបួននាក់ទៀត ។

---

*(១) ស្រង់ពីសេចក្តីរាយការណ៍ របស់កងវរសេនាតូចយុវជនសៀមរាប ។*

www.elibraryofcambodia.org

## ៧៧

ព្រឹកថ្ងៃទី ៧ មិថុនា ១៩៧០, ពួកទមិឡយៀកកុងនៅតែបាញ់យើងទៀតរហូតដល់ម៉ោង ១២:០០ ថ្ងៃត្រង់ ។

ដោយក្រុមយើងកាន់តែអស់កម្លាំង ព្រោះត្រូវជាប់ដៃជាមួយខ្មាំងអស់រយៈពេល ៣២ ម៉ោង ហើយដោយគ្រាប់យើងនៅសល់ស្ដួចស្ដើងពេក និងដោយកាំភ្លើងមិនទាន់សម័យផង ព្រមទាំងទីតាំងទ័ពយើងក៏នៅឆ្ងាយដាច់ស្រយាលពីទីក្រុង «ខ្សែការពារ» ទើបឧត្តមសេនីយទោ សូ ផាំងឃ មេបញ្ជាការភូមិភាគទី ៤ បានចេញបញ្ជាឲ្យកងវរសេនាតូចយើង ដកថយចេញពីវិទ្យាល័យ មកតាំងទ័ពជួយការពារទីក្រុងសៀមរាប «សាលាបឋមសិក្សាសៀមរាបក្រុង-ម៉ាស៊ីនទឹក ដំណាក់ បន្ទាយកងវរសេនាតូចប្រដេញទី ៧, ពេទ្យទាហាននិងសាលាកំបូង» វិញ ចាប់ពីម៉ោង ១២និង៣០ នាទី នៃថ្ងៃទី៧-៦-៧០ រៀងរហូតមក ។

សូមបញ្ជាក់ថា :

ក- ក្រុមសង្គ្រោះនាងកងទ័ពនៅមេភូមិភាគទី ៤ បានធ្វើដំណើរដល់កងវរសេនាតូចយើងនូវម្ហូបប្រមប់ខ្លះ ហើយបានបើកប្រាក់ស្បៀងប្រចាំថ្ងៃដល់សិស្សានុសិស្សជាយោធាក្នុងម្នាក់ៗ ៣០ រៀល ក្នុង ១ ថ្ងៃ ។

ខ- នៅឱកាសប្រយុទ្ធនោះ សត្រូវក៏ត្រូវខូចខាតដូចតទៅ :

- ស្លាប់ ៣ នាក់នៅនឹងកន្លែង
- ស្លាប់និងរបួសដែលគ្នាវានាំយកទៅ ៤០ នាក់
- យើងប្រមូលបានកាំភ្លើងធី (ប៉េរ៉ា) ចិន ១ ដើម ប៉េរ៉ិមចិន ១ ដើម, ប៉េរ៉ិមស្នូកបត់ ១ ដើម, គ្រាប់បែកពីរគ្រាប់, គ្រាប់ម៉ិកធេទ់ហ៍ ៦០ ម.ម. ១២ គ្រាប់, គ្រាប់កាំភ្លើង ៦០០ គ្រាប់, ស្បែកជើង ១ សម្រាប់ និងមួកកាស ១ ។

**ចប់**

---

តម្កល់ទុកតាមលេខ ៥០ ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ១៩៧១

www.elibraryofcambodia.org

# វិញ្ញាណកូន ខៀវវណ្ណដារ៉ា

បទភ្លេង ស៊ិន-ស៊ីសាមុត
ទំនុកច្រៀង ម៉ា-ឡៅពី
ច្រៀងដោយ ស៊ិន-ស៊ីសាមុត និង ហួយ-មាស

១- ក្នុងសង្គមមនុស្សមានឈ្មោះជាស្រី ស្រឡាញ់ទឹកដីដូចខៀវវណ្ណដារា
វិញ្ញាណកូននាងស្រែកថ្កាខ្មែរតា សូមជាតិខេមរាសងពលកម្មឲ្យផង ។

២- រូបនាងស្លាប់ទៅសល់នៅត្រឹមឈ្មោះ ល្បីល្បាញពីរោះខ្ទរខ្ទាររំពង
ទុកជាគំរូដល់ញាតិប្អូនបង ដើរតាមគន្លងអ្នកស្នេហាជាតិ ។

បន្ទរ- ទឹកចិត្តយុទ្ធជនជាន់ទៅមុខ ប្រាថ្នាក្ដីសុខទុកត្រើយឲ្យញាតិ
យៀកកុងឈ្លានពានកូនខ្មែរពិឃាត ឲ្យវាបាក់ស្បាតដោយដៃកូនខ្មែរ ។

៣- រូបនាងស្លាប់ពិតតែចិត្តនាងនៅ ជួយប្រៀនប្រដៅឲ្យខ្លាំងពូកែ
អង្គផ្ចុំផ្ចិតដួងចិត្តចាក់ខ្សែ សូមវិលសាកបរជួយថែទឹកដី ។

------ បទនេះជាអំណោយរបស់លោក ម៉ា-ឡៅពី ------

វាយអក្សរឡើងវិញ : ហេងពិស៊ុទ
ពិនិត្យ : ម៉ិច-ពិសិដ្ឋ
ស.រ.អា., ២៦មករា២០០៩

www.elibraryofcambodia.org